៤

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៨ ខែ មេសា

ព.ស. ២៥០៨ គ.ស. ១៩៦៦

– ភ្នំពេញ –

ទំហំ 160×240
350 ទំព័រ ... ទំព័រ
៧-5-270

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

១– ទុក្ខធម្មកថា ការសម្ដែងអំពីទុក្ខធម៌ (ធម៌ក្រ) ៩ យ៉ាង ព្រះសាសនមុនី កិម-តួរ រៀបរៀង ៣៤៩
២– ការចម្រើន និង ការវិនាស នៃចំនួនមនុស្ស លោក ផល-ទិត រៀបរៀង . . . ៣៧២

*ផ្នែកអក្សរសាស្ត្រ*

៣– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . ៣៧៧
៤– កាព្យនិទានរំលឹកដល់អក្សរសាស្ត្រ សម័យអង្គរ . . . . . ៣៨០
៥– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឱ. តាម ស្រាវជ្រាវ (ត) . . . . . ៣៨១
៦ អធិប្បាយភាសិត ពាក្យកាព្យ បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ (ត) . ៣៩៧
៧– ឯកសារ សាស្ត្រស៊ីករីតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . ៤០៩
៨– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ–កន ប្រែរៀបរៀង(ត) . . ៤១៣
៩– ឯកសារ កម្ពុជសុរិយា លោក ឱ-តាម ប្រមូលរៀបរៀង (ត) . . . ៤៣១

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០៛០០ ។

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក, ឲ្យធ្វើល្អទៅ,
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

## ទុក្ខធម្មកថា

### ការសម្តែងអំពីទុក្ខធម៌(ធម៌ក្រ)៥យ៉ាង

ព្រះសាសនមុនី កិម-តួរ រៀបរៀង

ធម៌នេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែង ចំពោះភិក្ខុមួយរូបឈ្មោះ វជ្ជីបុត្តកៈ នៅក្នុងក្រុងវេសាលី ។ ភិក្ខុនោះជាព្រះរាជបុត្តរបស់ព្រះមហាក្សត្រិយ៍ក្នុងដែនវជ្ជី, លះបង់រាជសម្បត្តិដែលខ្លួនត្រូវទទួលសោយរាជ្យ ហើយចេញទៅបួសនៅក្នុងព្រៃមួយ មិនឆ្ងាយប៉ុន្មានអំពីក្រុងវេសាលី ។ គ្រានោះ អ្នកក្រុងវេសាលី រៀបចំតាក់តែងទីក្រុងទាំងមូលដោយគ្រឿងលំអផ្សេងៗ មានទង់ជ័យនិងបដាជាដើម, នាំគ្នាលេងមហោស្រពប្រគំដូរ្យតន្ត្រីផ្សេងៗ មានស្គរស័ព្ទលាន់ឮទ្រហឹងអឹងអាប់ អស់វេលាពេញមួយរាត្រី មុខគួរឲ្យរីករាយសប្បាយយ៉ាងក្រៃលែង ។ ភិក្ខុនោះ កំពុងតែដើរចង្ក្រមក្នុងទីចង្ក្រម បានឮស្គរស័ព្ទភ្លេងដូរ្យតន្ត្រីផ្សេងៗដូច្នោះ, ហើយក្រឡេកមើលអត្តភាពរបស់ខ្លួន ដែលប្រាសចាក

គ្រឿងអលង្ការ ហាក់ដូចជាកំណាត់ឈើដែលគេបោះចោលក្នុងព្រៃ , ក៏កើតសេចក្ដីសង្វេគស្រងេះស្រងោចលទ្ធល់លន្ទោចក្នុងចិត្តគិតថា ធម្មតាមនុស្សក្នុងលោក គ្មាននរណាលាមកអន់ជាងអាត្មាអញទៅទៀតទេ, ម្នោះហើយក៏ត្រូវសេចក្ដីអផ្សុកបៀតបៀនក្នុងខណៈនោះ ៗ ទេវតាដែលនៅក្នុងព្រៃនោះ មានបំណងនឹងញ៉ាំងភិក្ខុនោះឲ្យកើតសង្វេគ ទើបនិយាយទៅរកភិក្ខុនោះថា នែលោកម្ចាស់! លោកម្ចាស់នៅក្នុងព្រៃម្នាក់ឯង ហាក់ដូចជាជាកំណាត់ឈើ ដែលគេបោះចោលក្នុងព្រៃក៏ពិតមែន ប៉ុន្តែមនុស្សទាំងទេវតាភាគច្រើន គេស្រឡាញ់រាប់អានចំពោះលោកម្ចាស់, ដូចសត្វនរក តែងស្រឡាញ់ចំពោះអ្នកដែលបាននៅកើតក្នុងឋានសួគ៌ដូច្នោះដែរ ៗ ភិក្ខុនោះ ឮពាក្យទេវតាថាដូច្នោះហើយ, វេលាព្រឹកឡើង ក៏ចូលទៅគាល់ព្រះបរមសាស្ដា ក្រាបទូលសេចក្ដីនោះដោយសព្វគ្រប់ ៗ ព្រះសម្ពុទ្ធ ទ្រង់ព្រះសណ្ដាប់ពាក្យភិក្ខុនោះក្រាបទូលដូច្នោះហើយ ទើបទ្រង់ប្រជុំទុក្ខ ( ការក្រ ) ៥ យ៉ាង ត្រាស់សម្ដែងដោយបទគាថាថា :

ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុខា
ទុក្ខោ សមានសំវាសោ ទុក្ខានុបតិតទ្ធគូ
តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា ៗ

( ប្រែថា ) ការបួសបានដោយក្រឬថាក្រនឹងបានបួស, ការត្រេក

អរត្រូវ បានដោយក្រ ឬជាក្រនឹងបានត្រេកអរត្រូវ, ការនៅគ្រប់គ្រងផ្ទះជាការក្រ, កា នៅរួមជាមួយនឹងមនុស្សមិនស្មើគ្នាជាការក្រ,(១) អ្នកដើរទៅកាន់ផ្លូវឆ្ងាយ រមែងត្រូវទុក្ខជាប់តាម, ព្រោះហេតុនោះ បុគ្គលមិនត្រូវដើរទៅកាន់ផ្លូវឆ្ងាយ ទាំងមិនត្រូវឲ្យទុក្ខជាប់តាមឡើយ ។

ក្នុងផ្នែកនៃគាថានេះ មានសេចក្តីសង្ខេបពេក អស់លោកអ្នកអានមុខជាពិបាកពិចារណាសេចក្តីនៃពុទ្ធភាសិតនេះ ឬ យល់សព្វគ្រប់បាន ព្រោះហេតុនោះ សូមលើកយកគោលនៃពុទ្ធភាសិតមួយ ៗ ក្នុងផ្នែកគាថានេះមកតាំងជាមាតិកា ដើម្បីអធិប្បាយពង្រីកសេចក្តី ឲ្យបានទូលាយ ងាយស្តាប់ដូចតទៅនេះ

## ១– ការបួសបានដោយក្រឬជាក្រនឹងបានបួស

ការចេញទៅបួសរបស់បុគ្គលទីមួយ ៗ បានដោយក្រ គឺកម្រនឹងមានបុគ្គល លះបង់ភោគសម្បត្តិទោះមានតិចឬច្រើន កម្រនឹងលះបង់នូវក្រុមញាតិមានមាតាបិតាជាដើម ហើយចេញទៅបួសអស់មួយជីវិតក្នុងពុទ្ធសាសនានេះ ដោយហេតុថា មានបុគ្គលទីមួយ ៗ ដែលចេញទៅបួសក្នុងពុទ្ធសាសនាដោយមានដំណើរផ្សេង ៗ គ្នា គឺបុគ្គលខ្លះមានគំនិតយល់ត្រូវល្អ បុគ្គលខ្លះមានគំនិតទាស់ខុសពុំសមរម្យ បានលើកយកមកជាឧទាហរណ៍ខ្លះដូចតទៅនេះ

បុគ្គលខ្លះ ឃើញទោសឃរាវាស ( ការនៅគ្រប់គ្រងផ្ទះ ) ថាសុទ្ធ

១- សម័យពីមុន លោកអ្នកប្រាជ្ញខ្លះ យល់ថា ត្រូវកាត់បទជា ទុក្ខា អសមានសំវាសោ ។

តែប្រកបដោយទុក្ខទោសច្រើនប្រការ ពុំអាចនឹងធ្វើខ្លួនឲ្យបរិសុទ្ធផុតចាកទុក្ខទាំងពួង មានជាតិទុក្ខជាដើមបានឡើយ លុះគិតឃើញដូច្នោះហើយ ក៏នឿយណាយធុញទ្រាន់នឹងគេហវាស ហើយចូលមកបួសក្នុងពុទ្ធសាសនា ដោយហេតុនេះក៏មាន ។

បុគ្គលខ្លះ ឃើញទោសនៃការកើត ចាស់ ឈឺ ស្លាប់ ក្នុងវដ្ដសង្សារគេចរួចផុតគ្មាន, កើតសេចក្ដីនឿយណាយនឹងខន្ធ ៥ របស់ខ្លួនក៏គិតថា ការនៅក្នុងកណ្ដាលផ្ទះគឺកាមគុណ ៥ យ៉ាងនេះ ពុំអាចនឹងបំពេញសមណធម៌ឲ្យហ្មត់ចត់បានឡើយ លុះតែបួសទើបនឹងបំពេញវត្តប្រតិបត្តិឲ្យគ្រប់គ្រាន់បាន កាលបើគិតឃើញដូច្នេះហើយ ក៏ចូលមកបួសក្នុងពុទ្ធសាសនា ដោយហេតុនេះក៏មាន ។

បុគ្គលខ្លះ គិតឃើញថា ក្នុងពុទ្ធសាសនានេះ សម្បូរដោយវិជ្ជាទិងទពទល្អៗ មានច្រើនប្រការណាស់ បើអាត្មាអញនៅជាគេហស្ថដូច្នេះ ពុំអាចនឹងសិក្សាឲ្យសព្វគ្រប់បានឡើយ លុះតែបួសហើយតាំងព្យាយាមសិក្សាវិជ្ជាទិងទពទល្អ ៗ ទាំងនោះឲ្យបានច្បាស់លាស់ ទើបអាចក្រេបយករសជាតិនៃពុទ្ធសាសនា រកធ្វើជាវត្តប្រតិបត្តិឲ្យត្រឹមត្រូវតាមលំអាននៃពុទ្ធសាសនាទៅបាន កាលបើគិតឃើញដូច្នោះហើយ ក៏ចូលមកបួសក្នុងពុទ្ធសាសនា ដោយហេតុនេះក៏មាន ។

បុគ្គលខ្លះ គិតឃើញថា ការនៅធ្វើជាគ្រហស្ថនេះ ពិបាកប្រកប

ការងាររកទ្រព្យសម្បត្តិសម្រាប់ចិញ្ចឹមជីវិតណាស់ ទោះបីខំប្រឹងប្រែងយ៉ាងណា ក៏នៅតែត្រដាបត្រដួស ស្ទើរតែពុំរស់ជាមនុស្ស បើទៅធ្វើជាអ្នកបួសវិញ ទើបងាយស្រួលនឹងចិញ្ចឹមជីវិត ក៏ចូលមកបួសក្នុងពុទ្ធ-សាសនា ដោយហេតុនេះក៏មាន ។

បុគ្គលខ្លះ គិតឃើញថា អាត្មាអញជាមនុស្សកំព្រាតែលតោល គ្មានទ្រព្យសម្បត្តិជាទីពឹង ថែមទាំងរាងកាយក៏ពុំសូវរឹងប៉ឹង ច្រើនមានជម្ងឺឈឺចាប់ជានិច្ចកាលផង បើនឹងទ្រាំនៅជាគេហស្ថដូច្នេះរហូតទៅ ជីវិតរបស់អាត្មាអញ ប្រាកដជាពុំបានតាំងនៅយឺនយូរឡើយ លុះតែបួស ទើបអាចនឹងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅបានដោយស្រួល ក៏ចូលមកបួសក្នុងពុទ្ធសាសនា ដោយហេតុនេះក៏មាន ។

បុគ្គលខ្លះ ជាមនុស្សខិលខូច ងប់ចិត្តទៅក្នុងអំពើពាលផ្សេងៗ មានស្រី ស្រា និងល្បែងភ្នាល់ជាដើម, ក្រុមញាតិមានមាតាបិតាជាដើម ស្តីប្រដៅមិនបាន ហើយគេក៏គិតគ្នាថា យើងទាល់ប្រាជ្ញហើយ មិនដឹងជានឹងធ្វើដូចម្តេចទៀតទេ មានតែនាំវាទៅឲ្យបួស ក្រែងលោលោកគ្រូប្រៀនប្រដៅវាបាន ក៏និយាយល្បួងលួងលោមដឹកនាំឲ្យចូលមកបួសក្នុងសាសនា ដោយហេតុនេះក៏មាន ។

បុគ្គលខ្លះ គិតឃើញថា អាត្មាអញមានវ័យល្មមបួសជាសាមណេរ ឬជាភិក្ខុហើយ ព្រោះអ្នកដទៃគេបួសពល់គ្នា យើងឯងមិនបួសទេ ក្រែង

អ្នកផងគេនិន្ទាថាឲ្យយ៉ាងនេះឬយ៉ាងនោះពុំខាន ហើយចូលមកបួសក្នុងពុទ្ធសាសនា ដោយហេតុនេះក៏មាន ។ល។

បណ្ដាអ្នកបួសទាំងឡាយ ដែលបានពណ៌នាមកហើយខាងលើនេះ អ្នកបួសពួកខាងដើមទើបប្រសើរជាងគេ ព្រោះមានគំនិតយល់ត្រូវល្អ ។ បុគ្គលនីមួយ ៗ ដែលបានចូលមកបួសក្នុងពុទ្ធសាសនា ទោះបីខាងដើមមានគំនិតយល់ឃើញផ្សេងគ្នាយ៉ាងណាក៏ដោយចុះ ឈ្មោះថាកម្រមានបុគ្គលចូលមកបួសបានដោយងាយដែរ ព្រោះហេតុនោះបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ទុប្បព្វជ្ជំ ក្រនឹងបានបួស គឺកម្រមានបុគ្គលគិតឃើញត្រូវ ហើយលះបង់ទ្រព្យសម្បត្តិ និងពួកញាតិមានមាតាបិតាឬប្រពន្ធកូនជាដើម ចូលមកបួសអស់មួយជីវិតក្នុងពុទ្ធសាសនា ។

## ២- ការត្រេកអរត្រូវបានដោយក្រ ឬ ជាក្រនឹងបានត្រេកអរត្រូវ

ការដែលបានបួសរួចហើយ ក្រនឹងត្រេកអរពេញចិត្តប្រព្រឹត្តត្រូវ គឺកម្រនឹងមានព្យាយាមប្រព្រឹត្តចិញ្ចឹមជីវិត ដោយការវៀរចាកអនេសនៈ ២១និងបាបធម៌៥ ហើយប្រព្រឹត្តចិញ្ចឹមជីវិតដោយភិក្ខាចារ គឺត្រាច់ដើរសូមដោយកម្លាំងស្មងជាប្រក្រតី, កម្រនឹងមានសេចក្ដីត្រេកអរពេញចិត្តក្នុងការរក្សាសីលក្ខន្ធ (កងសីល) គឺសិក្ខាបទទាំងឡាយជាពុទ្ធបញ្ញត្តិ និងពុទ្ធានុញ្ញាតទាំងប៉ុន្មានមិនឲ្យមានមោះហ្មង, កម្រនឹងបំពេញសេចក្ដីប្រតិបត្តិនូវធម៌ឲ្យសមគួរដល់ធម៌ ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធទ្រង់

ត្រាស់ថា ទុរកិរមំ បួសហើយកម្រនឹងមានចិត្តត្រេកអរត្រូវ ប្រព្រឹត្តត្រូវតាមធម៌វិន័យ ៗ ព្រោះហេតុថា បុគ្គលខ្លះ បួសហើយច្រើនភ្លេចវង្វេងកាន់ប្រឡំ ដោយអំណាចសេចក្ដីល្ងង់ខ្លៅ ឬដោយអំណាចលាភសក្ការៈកើតឡើងគ្របសង្កត់ បំបែរគំនិតឲ្យយល់ខុសផ្ទុយនឹងធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធទៅវិញ ជាហេតុនាំឲ្យមានរបៀបរបបនឹងការប្រព្រឹត្តផ្សេងៗគ្នា ម្ល៉ោះហើយក៏ក្លាយទៅជាអ្នកបួសមានអាកប្បកិរិយាច្រើនបែបគឺ

បែបទី ១. **ឧបជីវិកា បួសដើម្បីចិញ្ចឹមជីវិត** បានខាងមនុស្សអនាថាគ្មានទីពឹងជាអ្នកខ្សត់ក្រកំព្រាតែលតោល បួសពឹងសាសនាគ្រាន់នឹងចិញ្ចឹមជីវិត ដូចតូតបសាប រំពៃចាំតែទទួលគ្រឿងសំណែនដែលគេបន់ស្រន់, បួសហើយមិនអើពើនឹងការសិក្សារៀនសូត្រ រកការខុស-ត្រូវសម្រាប់ខ្លួនជាអ្នកបួសប៉ុន្មានឡើយ ជាអ្នកឥតអៀនខ្មាស លោភនឹងការរកចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ក្លៀវក្លាដូចជាសត្វក្អែក ៗ

បែបទី ២. **ឧបកីឡិកា បួសដើម្បីលេង** បានខាងអ្នកបួសដែលពេញចិត្តខាងល្បែងរបាំផ្សេង ៗ អាស្រ័យសាសនាជាបង្អែក អាស្រ័យភេទសមណៈជាគ្រឿងបញ្ឆោតមនុស្សល្ងង់ខ្លៅ ដែលជាអ្នកពេញចិត្តចំពោះល្បែងរបាំដូច្នេះ រាប់អានបូជាដោយអាមិសទានផ្សេងៗ , ពុំសូវអើពើនឹងការសិក្សារៀនសូត្រធម៌វិន័យ ពុំសូវគិតគូរយកចិត្តទុកដាក់ពីសេចក្ដីប្រតិបត្តិខុសត្រូវប៉ុន្មានឡើយ ៗ

វែបទី ៣- ឧបមុយ្ហិកា បួសហើយវង្វេង បានខាងអ្នកបួសខ្ជិលច្រអូស មិនសិក្សារៀនសូត្រធម៌វិន័យ ឲ្យចេះដឹងស្គាល់ផ្លូវនៃសេចក្ដីប្រតិបត្តិល្អ - អាក្រក់ឡើយ, បណ្ដោយខ្លួនឲ្យវង្វេងធ្លាក់ចុះក្នុងរណ្ដៅគឺសេចក្ដីល្ងង់ខ្លៅ មិនអាចទូន្មានប្រៀនប្រដៅដឹកនាំពាយកតាយិកាឲ្យស្គាល់ការខុសត្រូវ ចំពោះសេចក្ដីប្រតិបត្តិធម៌វិន័យពុទ្ធសាសនាបានឡើយ, ត្រូវលាភសក្ការៈនិងយសបរិវារគ្របសង្កត់ ក៏កើតអស្មិមានៈប្រកាន់រឹងត្អឹងស្រវឹងផងអោងក្អេងខ្លួន ដូចជាជ្រូកស្រុកដែលគេបំប៉នដោយចំណី ៗ សម័យដែលគេត្រូវសិក្សារៀនបរិយត្តិធម៌អាថ៌ ឬធ្វើអ្វីឲ្យចម្រើនព្រះពុទ្ធសាសនា ក៏មិនគិតរៀន មិនគិតធ្វើ, ទោះបីមានគេណែនាំរំឭកដាស់តឿនដូចម្ដេច ក៏មិនរវល់ស្ដាប់ មិនយកចិត្តទុកដាក់ធ្វើតាម, ពីដើមមកធ្លាប់ធ្វើយ៉ាងណា ក៏នៅតែរឹងចចេសធ្វើយ៉ាងនោះដដែល ៗ មិនព្រមលះបង់ចោល ៗ

វែបទី ៤- ឧបទូសិកា បួសហើយប្រទូស្តសាសនា បានខាងអ្នកបួសដែលមិនយកចិត្តទុកដាក់ប្រព្រឹត្តតាមធម៌វិន័យ គឺប្រព្រឹត្តខ្ជីខ្ជាប្រឡើសបើសតាមទំនើងចិត្ត ផ្ទុយពីពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត, អាស្រ័យកាសាវព័ស្ត្រជារនាំងបាំងភ្នែកនៃជនដទៃ ចាំតែចិតាស់ពាក់ងការសិក្សាធម៌វិន័យរបស់គេមិនឲ្យចំរើនលូតលាស់ឡើងបាន, លបប្រព្រឹត្តធ្វើអំពើទុច្ចរិតផ្សេងៗ ហាក់ដូចជាចោរប្លន់ បំផ្លិចបំផ្លាញ

ពង្រីកពង្រឹងសាសនាឲ្យពេយរៀវសាបសូន្យទៅតែប៉ុណ្ណោះ ។

បែបទី ៥· ឧបនិស្សរណិកា បួសដើម្បីរលាស់ខ្លួនចេញបាកទុក្ខ បានខាងអ្នកបួស, បួសហើយនឹកចាំមិនភ្លេចនូវពាក្យប្តេជ្ញារបស់ខ្លួនដែលពោលក្នុងទីចំពោះមុខឧបជ្ឈាយ៍ថា សព្វទុក្ខនិស្សរណនិព្វានសច្ឆិករណត្ថាយ .. (ប្រែថា អាត្មាអញដែលបួសនេះ ដើម្បីប្រយោជន៍នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាទីរលាស់ចេញនូវទុក្ខទាំងពួង) ហើយក៏ខំប្រឹងប្រែងរៀនសូត្របានចេះដឹងដោយខ្លួនឯងផង បានបង្ហាត់បង្រៀន-សម្តែងប្រាប់អ្នកដទៃឲ្យមានការចេះដឹងផង ហើយនាំគ្នាប្រតិបត្តិដោយសេចក្តីរៀបរយតាមធម៌វិន័យ គួរជាទីជ្រះថ្លាពេញចិត្តនៃជនដទៃ ។ បណ្តាអ្នកបួសទាំង ៥ បែបដូចបានពោលមកហើយនោះ អ្នកបួសបែបទី ១ ដល់ទី ៤ ទើបឈ្មោះថាអ្នកបួសញ៉ាំញីបំផ្លាញព្រះពុទ្ធសាសនាឲ្យវិនាសសាបសូន្យ ឯអ្នកបួសបែបទី ៥ ទើបឈ្មោះថាជាអ្នកបួសធ្វើព្រះពុទ្ធសាសនាឲ្យបានអាយុចំរើនរុងរឿងតាំងនៅអស់កាលជាយូរអង្វែង ។ ព្រោះហេតុនោះ កុលបុត្តណាមួយ ដែលមានគំនិតយល់ត្រូវល្អហើយ បានលះបង់ភេទឃរាវាស ព្រមទាំងវត្ថុកាមនិងកិលេសកាមហើយចូលមកបួសក្នុងព្រះពុទ្ធសាសនា, បានសិក្សារៀនបរិយត្តិធម៌ ហើយធ្វើសេចក្តីប្រតិបត្តិត្រឹមត្រូវតាមធម៌វិន័យ

របស់ព្រះសម្មាសម្ពុទ្ធ  កុលបុត្តនោះឯងរមែងបានទទួលនូវសមណសុខ (សេចក្ដីសុខរបស់សមណៈ) ៨ យ៉ាងគឺ

១. ធនធញ្ញានិបរិគ្គហាភាវោ  មិនមានសេចក្ដីហួងហែងនូវសម្បត្តិមានទ្រព្យនិងស្រូវអង្ករជាដើម ។

២. អនវជ្ជបិណ្ឌបរិយេសនភាវោ  ភាពនៃការស្វែងរកនូវបិណ្ឌបាតដែលឥតទោស ។

៣. និព្វុតបិណ្ឌបរិភុញ្ជនភាវោ  ភាពនៃការបរិភោគនូវបិណ្ឌបាតដ៏ត្រជាក់ ។

៤. រដ្ឋបីឡនាភាវោ  មិនមានការបៀតបៀនអំពីអ្នកដែន ។

៥. ឧបករណេសុ និច្ឆន្ទរាគភាវោ  ភាពនៃសមណៈមិនមានឆន្ទរាគ ក្នុងគ្រឿងឧបករណ៍ទាំងឡាយ ។

៦. ចោរវិលោបេ និព្ភយភាវោ  ភាពនៃសមណៈមិនមានភ័យក្នុងការលួចប្លន់នៃចោរ ។

៧. រាជរាជមហាមត្តេហិ អសំសដ្ឋភាវោ  ភាពនៃសមណៈមិនជាប់ចំពាក់ដោយស្ដេច និងមហាមាត្យនៃស្ដេចទាំងឡាយ ។

៨. ចតូសុ ទិសាសុ អប្បដិហតភាវោ  ភាពនៃសមណៈមិនទើសទាក់ក្នុងទិសទាំង ៤ ។

## អធិប្បាយសេចក្ដីនៃសមណសុខទាំង ៨ យ៉ាង

តាមលំដាប់មាតិកានីមួយៗ ដូចតទៅនេះ :

ពាក្យថា **មិនមានសេចក្ដីហួងហែងនូវសម្បត្តិមានទ្រព្យនិងស្រូវអង្ករជាដើម** ដោយហេតុថា សមណៈមុននឹងចូលមកបួសក្នុងព្រះពុទ្ធសាសនា បានលះបង់ទ្រព្យសម្បត្តិមានវិញ្ញាណនិងឥតវិញ្ញាណជារបស់ផ្ទាល់ខ្លួនអស់លើងជាស្រេចហើយ ជាអ្នកមានករណីយកិច្ចផ្សេងអំពីគ្រហស្ថ, បើទុកជាមានទ្រព្យសម្បត្តិជាសមណបរិក្ខារខ្លះ ក៏បានមកដោយសទ្ធាជ្រះថ្លារបស់គ្រហស្ថ, គ្រាន់តែថែរក្សាទុកថាជារបស់សង្ឃ ឬជារបស់វត្តប៉ុណ្ណោះ ហើយមិនមានការហួងហែងទុកដាក់លាក់រក្សា ប្រកបដោយមច្ឆរិយៈ គឺសេចក្ដីកំណាញ់ឡើយ ។ ការហួងហែង, ការលាក់លៀម, ការថែទាំទុកដាក់នេះ ទុកថាជាកង្វល់មួយដ៏ធំ ព្រោះជាហេតុនាំឲ្យមានទុក្ខព្រួយជានិច្ចចំពោះទ្រព្យសម្បត្តិ ភ័យខ្លាចក្រែងមានអន្តរាយដោយហេតុផ្សេងៗ មានចោរទុក្ខភ័យជាដើម ។ ត្រង់ការដែលគ្មានសេចក្ដីហួងហែងទុកដាក់នេះ ឈ្មោះថាជាសុខរបស់សមណៈទី ១ ។

ពាក្យថា **ភាពនៃការស្វែងរកនូវបិណ្ឌបាតដែលឥតទោស** ដោយហេតុថា សមណៈមានការស្វែងរកអាហារបិណ្ឌបាត ប្រកបដោយ

ផ្លូវដ៏បរិសុទ្ធ វៀរចាកការស្វែងរកដោយអនេសនធម៌និងបាបធម៌ ៗ ជីវ-ភាពរបស់សមណៈ តែងជាប់ទាក់ទងដោយគ្រហស្ថអ្នកមានសទ្ធាជ្រះថ្លាក៏ពិតមែន ប៉ុន្តែមិនមែនជាប់ទាក់ទងរួមជាមួយនឹងគ្រហស្ថ មានធ្វើពាណិជ្ជកម្ម កសិកម្ម ឬ វេជ្ជកម្មជាដើមឡើយ ៗ ការស្វែងរករបស់សមណៈ ដើម្បីជីវភាពរបស់ខ្លួន ត្រូវប្រកបដោយផ្លូវបរិសុទ្ធ តាមគន្លងនៃអាជីវបារិសុទ្ធិសីល ទើបសមគួរដល់ឋានៈនៃខ្លួនជាសមណៈ ជាបុញ្ញក្ខេត្តនៃទាយក-ទាយិកា មិនបណ្ដោយឲ្យជីវភាពរបស់ខ្លួនធ្លាក់ចុះក្នុងអាជីវវិបត្តិឡើយ ៗ ត្រង់ការស្វែងរកអាហារបិណ្ឌបាត ដែលប្រាសចាកទោស ដូចបានពោលមកហើយនេះ ឈ្មោះថា ជាសុខរបស់សមណៈទី២ ៗ

ពាក្យថា **ភាពនៃការបរិភោគបិណ្ឌបាតដ៏ត្រជាក់** ដោយហេតុថា សមណៈដែលស្ម័គ្រចិត្តចូលមកបួសក្នុងព្រះពុទ្ធសាសនា ត្រូវជាអ្នកព្រមទទួលអាហារបិណ្ឌបាតតាមតែប្រទះ គឺជួនកាលបានអាហារត្រ-ជាក់ ជួនកាលបានអាហារក្ដៅ ៗ អាហារបិណ្ឌបាតនោះសោតទៀត អាហារខ្លះក៏មានរសឆ្ងាញ់ អាហារខ្លះក៏ពុំសូវមានរសឆ្ងាញ់, ថ្ងៃខ្លះបានឆ្អែត ថ្ងៃខ្លះក៏ពុំសូវឆ្អែត ៗ ការដែលសមណៈព្រមសុខចិត្តបរិភោគអាហារបិណ្ឌបាតត្រជាក់តាមមានតាមបាននេះ ចាត់ថាជាតបធម៌មួយរបស់សមណៈសម្រាប់ញុំាងចិត្តឲ្យស្ងប់ មិនបណ្ដោយចិត្តឲ្យរះរាំមរលោរលាំ

សព្វបើគ្រាន់តែរស់អាហារនោះឡើយ ។ គ្រង់ការដែលសមណៈព្រមទទួលបរិភោគអាហារតាមតែប្រទះ ដូចបានពោលមកនេះ ឈ្មោះថា ជាសុខរបស់សមណៈទី ៣ ។

ពាក្យថា មិនមានការបៀតបៀនអំពីអ្នកដទៃ ដោយហេតុថា សមណៈជាបុគ្គលគ្មានទ្រព្យសម្បត្តិដូចជាគ្រហស្ថឡើយ មានត្រឹមតែបរិក្ខារ ៨ សម្រាប់អ្នកបួសប្រើប្រាស់ប៉ុណ្ណោះ. ជាអ្នកមានកាយវាចាចិត្តសុភាពរាបសាស្ងប់ស្ងៀមតាមក្រែសិក្ខា មិនមានអ្នករាជការបៀតបៀនឬប្រើអំណាចយសស័ក្តិ សង្កត់សង្កិន រឹបអូស លក់ក្តោឡបន៍ទ្រព្យសម្បត្តិដូចជនអ្នកនៅក្នុងដែនណាមួយទេ មិនមែនដូចជាជនក្នុងដែន ដែលត្រូវបង់ពន្ធដារជូនរាជការ ឬត្រូវគេកេណ្ឌបង្ខំឲ្យធ្វើការណាទេ ។ គ្រង់ការមិនប្រព្រឹត្តិបៀតបៀនអំពីអ្នករាជការក្នុងដែននេះ ឈ្មោះថាជាសុខរបស់សមណៈទី ៤ ។

ពាក្យថា មិនមានឆន្ទរាគក្នុងឧបករណ៍ទាំងឡាយ ដោយហេតុថា សមណៈមិនមានសេចក្តីប្រាថ្នាប៉ុនប៉ងត្រេកអរវេះវាម ចំពោះឧបករណ៍គឺគ្រឿងបរិក្ខារ សម្រាប់ប្រើប្រាស់មានចីវរជាដើមនោះពេកទេ។ គ្រឿងឧបករណ៍ផ្សេងៗ ទាំងនោះ ទោះជារបស់ល្អក្តី មិនល្អក្តី ដែលសមណៈបានទទួលមកប្រកបដោយធម៌ហើយ មិនត្រូវមានការរេះគន់

វែសអើនចំពោះគ្រឿងឧបករណ៍ទាំងឡាយនោះឡើយ ។ គ្រឿងឧបករណ៍ដែលមិនទាន់បានមក ក៏មិនត្រូវប្រាថ្នាវះវក់មហួសហេតុ ដែលបានមកហើយ ក៏មិនត្រូវត្រេកអរជាប់ចិត្តហួសហេតុឡើយ ត្រូវតាំងចិត្តជាឧបេក្ខាក្នុងគ្រឿងឧបករណ៍ទាំងនោះជាដរាប ដើម្បីរក្សានូវភាពនៃខ្លួនជាសមណៈ ឲ្យបានឋិតនៅនឹងធឹងល្អ ។ ត្រង់ការដែលមិនមានធុរៈគតិសេចក្តីប្រាថ្នាជាប់ចិត្តក្នុងគ្រឿងឧបករណ៍ទាំងឡាយ ឈ្មោះថា ជាសុខរបស់សមណៈទី ៥ ។

ពាក្យថា មិនមានភ័យក្នុងការលួចប្លន់នៃចោរ ដោយហេតុថា សមណៈមិនមានសេចក្តីភ័យព្រួយបារម្ភអំពីចោរដែលលួចប្លន់ ព្រោះសមណៈជាអ្នកមិនសន្សំទ្រព្យសម្បត្តិទុកដាក់ ដែលជាហេតុនាំឲ្យចោរមានបំណងមកលួចប្លន់បានទេ, ទីកន្លែងជាលំនៅនៃសមណៈ ពុំមានរបស់អ្វីល្អដែលគួរឲ្យចោរប៉ុនប៉ងឡើយ ។ អំពើលួចប្លន់នៃចោរនេះ ជាគ្រឿងទុក្ខភ័យមួយដ៏ធំក្រៃលែងរបស់មនុស្សអ្នកមានទ្រព្យសម្បត្តិទូទៅក្នុងលោក ។ ត្រង់ការដែលមិនមានទុក្ខភ័យ ព្រួយបារម្ភអំពីចោរលួចប្លន់នេះ ឈ្មោះថា ជាសុខរបស់សមណៈទី ៦ ។

ពាក្យថា ភាពនៃសមណៈមិនជាប់ចំពាក់ដោយស្តេចនិងមហាមាត្យនៃស្តេច ដោយហេតុថា សមណៈជាអ្នកមានគេឧបត្ថម្ភស្រេច

ទាំងករណីយកិច្ចក៏ផ្សេងអំពីគ្រហស្ថ មិនត្រូវបណ្តោយខ្លួនឲ្យមានការជាប់ទាក់ទងឡើងចុះញឹកញយជាមួយនឹងស្តេច ឬមហាមាត្យគឺអស់លោកអ្នករាជការឡើយ ព្រោះស្តេចនិងមហាមាត្យ តែងមានកិច្ចការរវល់ក្នុងប្រទេសច្រើនយ៉ាង ៗ ការជាប់ជំពាក់ទាក់ទងប្រឡូកច្របល់ដោយឥស្សរ-ជនមានស្តេចជាដើមនោះ ជាហេតុនាំឲ្យឥស្សរជនដែលមានកិច្ចការច្រើនរវល់នឹងបែរមកធ្វើបដិសណ្ឋារៈចំពោះខ្លួនជាសមណៈផង នាំឲ្យមានហេតុការណ៍ពុំសមរម្យដល់សមណៈភេទផង ៗ គ្រប់ការដែលមិនមានកិច្ចជាប់ជំពាក់ដោយឥស្សរជននេះ ឈ្មោះថា ជាសុខរបស់សមណៈទី៧ ៗ

ពាក្យថា **ភាពនៃសមណៈមិនរើសទាក់ក្នុងទិសទាំង ៤** ដោយហេតុថា សមណៈជាអ្នកស្លូតសុភាព ទោះបីត្រាច់ទៅកាន់ទិសទីណាមួយក្នុងបណ្តាទិសទាំង ៤ ក៏ចេះតែទៅបានទាំងអស់ មិនសូវមានចិត្តជាប់ជំពាក់ចំពោះទីកន្លែងមួយ ៗ ទេ ព្រោះសមណៈពុំមានទ្រព្យសម្បត្តិទុកជាកម្មសិទ្ធិរបស់ខ្លួនឡើយ បើនឹងចង់ទៅកាន់ទីណាមួយ ក៏អាចទៅបានដោយងាយ ៗ មួយយ៉ាងទៀតខ្លូលាយ អាចចេញដើរទៅកាន់ទីណាមួយ ក៏ចេះតែទៅបានដោយស្រួល ឥតមានការរើសទាក់ជាប់ជំពាក់ចង្អៀតចង្អល់ដូចគ្រហស្ថនោះឡើយ ៗ គ្រប់ការដែលមិនមាន

សេចក្តីបង្អៀតបង្អល់ទើសទាក់ក្នុងទិសទាំង ៤ នេះ ឈ្មោះថា ជាសុខរបស់សមណៈទី ៨ ។

## ៣- ការនៅគ្រប់គ្រងផ្ទះជាការក្រ

ព្រះពុទ្ធដីកានេះ ព្រះអង្គទ្រង់សម្តែងចំពោះឃរាវាសជន អ្នកនៅគ្រប់គ្រងផ្ទះសម្បែងជាប្រក្រតី ៗ ធម្មតាគ្រហស្ថដែលនៅគ្រប់គ្រងផ្ទះ មិនមែនបានទទួលសេចក្តីសុខស្រួល ដោយចំណែកមួយទេ តែងមានសេចក្តីទុក្ខព្រួយដោយច្រើន កាលបើប្រព្រឹត្តទុកដាក់ខ្លួនមិនល្អ មិនត្រូវទំនងហើយ រមែងឲ្យទុក្ខទោសប្រចាំនៅជានិច្ច ។ ឃរាវាសជន រមែងមានករណីយកិច្ច ដែលត្រូវបំពេញ ត្រូវធ្វើជាច្រើនយ៉ាងគឺ

- ដោយឋានៈជា កតញ្ញូកតវេទី ត្រូវបំរើលោកអ្នកមានគុណូបការៈមានមាតាបិតានិងគ្រូអាចារ្យរបស់ខ្លួនជាដើមផង ត្រូវចេញទ្រព្យសម្បត្តិតាមមុខការដើម្បីរាជការ មានបង់ពន្ធដារផ្សេង ៗ ជាដើមផង ។

- ដោយឋានៈជា បុព្វការី ត្រូវចិញ្ចឹមទំនុកបំរុងបុត្តធីតារបស់ខ្លួន តាមផ្លូវលោក និងតាមផ្លូវធម៌ផង ត្រូវសង្គ្រោះទំនុកបំរុងជនជាបរិវារដែលនៅក្នុងបន្ទុករបស់ខ្លួនផង ។

- ដោយឋានៈជា គហបតី ត្រូវយកចិត្តទុកដាក់ប្រព្រឹត្តឲ្យ

ស្មោះស្មើដល់គ្នានឹងគ្នា រវាងស្វាមីនឹងភរិយាផង ត្រូវសង្គ្រោះទំនុកបំរុងញាតិនិងមិត្រសំឡាញ់ផង ត្រូវសង្គ្រោះទំនុកបំរុងសមណព្រាហ្មណ៍ ( បព្វជិត ) ក្នុងពុទ្ធសាសនាដោយបច្ច័យ ៤ ផង ត្រូវជួយសង្គ្រោះជនទុគ៌តខ្សត់កំព្រា តាមការគួរផង ។ល។

កាលបើដូច្នោះ ឃរាវាស ( ការនៅគ្រប់គ្រងផ្ទះ ) មានផ្លូវឬមុខប្រឡាយ ដែលត្រូវចំណាយឬត្រូវបង្ហូរចេញនៃទ្រព្យសម្បត្តិជាច្រើនយ៉ាង ៗ ហេតុនេះ ជនជាគ្រហស្ថ មិនអាចនឹងបំពេញឲ្យពេញគ្រប់គ្រាន់បានដោយងាយឡើយ ដូចជាក្អមធ្លុះ ពុំនោះសោតដូចជាមហាសមុទ្រ មិនមានអ្នកណាមួយធ្វើឲ្យពេញប្រៀបដោយទឹកបានឡើយ ក៏ដូច្នោះដែរ ។ ព្រោះហេតុនោះ បានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ទុរាវាសា ឃរា ទុក្ខា ការនៅគ្រប់គ្រងផ្ទះជាការក្រ គឺកម្រមានជនជាគ្រហស្ថនៅគ្រប់គ្រងផ្ទះ អាចបំពេញករណីយកិច្ចរបស់ខ្លួនគ្រប់គ្រាន់បានឡើយ ។

## ៤– ការនៅរួមជាមួយមនុស្សមិនស្មើគ្នា ជាការក្រ

ព្រះពុទ្ធដីកានេះ ព្រះអង្គទ្រង់សម្ដែងចំពោះជនទាំងពីរប្រភេទគឺទាំងគ្រហស្ថទាំងបព្វជិត ។ ជនទាំងឡាយណាគឺបើខាងគ្រហស្ថ សូម្បីស្មើគ្នាដោយជាតិ គោត្រ ត្រកូលភោគៈក៏ដោយ ឬបើខាងបព្វជិត សូម្បី

ស្មើគ្នាដោយគុណធម៌មានសីល អាចារៈនិងពាហុសច្ចៈជាដើមក៏ដោយ ប៉ុន្តែបើចិត្តរបស់ជនទាំងឡាយនោះមិនស្មើគ្នា មិនរាប់រកគ្នា មិនគោរពគ្នាទៅវិញទៅមកទេ ដោយអាស្រ័យអស្មិមានៈរឹងត្អឹងតែរៀងខ្លួន ពោលអាងដោយពាក្យថា « គេម៉េច អញម៉េច » យ៉ាងនេះជាដើមហើយរមែងទៅជាអ្នកខ្វល់ខ្វាយបង្កើតរឿងអធិករណ៍ ឈ្មោះប្រកែកតាស់តែងគំនិតគ្នាឥតស្រាក, ជនទាំងឡាយនោះឈ្មោះថាមិនស្មើគ្នាទេ, ការនៅរួមជាមួយនឹងពួកបនមិនស្មើគ្នាដូច្នោះ រមែងនាំមកទុក្ខរឿយ ១ ។ សេចក្តីនេះសូមជ្រាបថា ព្រះអង្គទ្រង់សម្តែងសំដៅយកចិត្តជាប្រមាណព្រោះថាសង្គមនៃជននីមួយ ១ បើទុកជាមានសម្បត្តិ គឺ ជាតិ វ័យគោត្ត ត្រកូល និងទ្រព្យសម្បត្តិមានវិញ្ញាណឥតវិញ្ញាណស្មើគ្នាយ៉ាងណាក៏ដោយ តែបើចិត្តនៃជនក្នុងសង្គមនោះ មិនស្មើគ្នា មិនព្រមព្រៀងគ្នាមិនគោរពរាប់អានគ្នា ដោយស្មោះត្រង់ទៅវិញទៅមកទេ សង្គមនៃជននោះឯងឈ្មោះថាមិនស្មើគ្នាដោយពិត ១ ចំណែកខាងបព្វជិតវិញក៏ដូច្នោះដែរ បើបព្វជិតទាំងឡាយណាដែលនៅក្នុងកុដិនីមួយ ១ ឬក្នុងអាវាសនីមួយ ១ ទុកជាមានគុណធម៌ស្មើគ្នាដោយការសិក្សារៀនសូត្រក្តីសីលក្តី អាចារៈគឺការកាន់ប្រព្រឹត្តក្តី ពាហុសច្ចៈគឺភាពជាអ្នកចេះដឹងច្រើនក្តី ប៉ុន្តែបើខ្វះផ្លូវចិត្តគឺមិនមានសេចក្តីព្រមព្រៀងគ្នា មិនគោរពរាប់

BIBLIOTHEQUE NATIONALE DU CAMBODGE

អានគ្នាទៅវិញទៅមកតាមចាស់ក្មេងទេ បុគ្គលទាំងឡាយនោះឈ្មោះថាមិនស្មើគ្នាទេ ។ ព្រោះហេតុនោះ បានជាព្រះសមាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងថា ទុក្ខោ សមានសំវាសោ ការនៅរួមជាមួយនឹងមនុស្សស្មើគ្នាដោយសម្បត្តិនិងគុណធម៌ក៏ដោយ តែបើមិនស្មើគ្នាដោយផ្លូវចិត្តផងទេ ជាការក្រមែងនាំមកនូវទុក្ខរឿយ ៗ ។

## ៥- អ្នកដើរទៅកាន់ផ្លូវឆ្ងាយ រមែងត្រូវទុក្ខជាប់តាម

ផ្លូវឆ្ងាយមាន ២ យ៉ាងគឺ កន្តារទ្ធា ផ្លូវឆ្ងាយគឺកន្តារៈ ១ វដ្ដទ្ធា ផ្លូវឆ្ងាយគឺវដ្ដៈ ១ ។ បណ្ដាផ្លូវឆ្ងាយទាំងពីរយ៉ាងនោះ ផ្លូវឆ្ងាយគឺកន្តារៈ សំដៅយកផ្លូវដែលមាននៅក្នុងលោកនេះ ។ កន្តារៈ ប្រែថាផ្លូវលំបាក ផ្លូវដែលមានគ្រោះថ្នាក់ ឬផ្លូវឆ្ងាយដាច់ស្រយាលមាន ៥ យ៉ាងគឺ ១. ចោរកន្តារៈ ផ្លូវលំបាកព្រោះចោរ, ២. វាឡកន្តារៈ ផ្លូវលំបាកព្រោះសត្វកាចសាហាវ, ៣- អមនុស្សកន្តារៈ ផ្លូវលំបាកព្រោះអមនុស្សឬបិសាច, ៤- និរុទកកន្តារៈ ផ្លូវលំបាកព្រោះគ្មានទឹក, ៥- អប្បភក្ខកន្តារៈ ផ្លូវលំបាកព្រោះគ្មានអាហារ ។

មនុស្សក្នុងលោក ដែលធ្វើដំណើរពីដំបន់មួយទៅកាន់ដំបន់មួយ ឬពីប្រទេសមួយទៅកាន់ប្រទេសមួយ តាមផ្លូវកន្តារៈ បើមិនទាន់ដល់ទីដៅដែលខ្លួនប៉ងនោះដរាបណា ក៏នៅឈ្មោះថាជាអ្នកដំណើរដរាប.នោះ

លុះតែបានដល់ទីដែលខ្លួនប៉ងនោះហើយ ទើបឈ្មោះថាជាអ្នកមានផ្លូវឆ្ងាយដល់ហើយ ឬ មានដំណើរដល់ហើយ ។ ធម្មតាមនុស្សដែលដើរទៅកាន់ផ្លូវកន្តារៈ រមែងជួបប្រទះនឹងគ្រោះថ្នាក់គឺសេចក្តីទុក្ខលំបាកណាមួយ ជួនកាលត្រូវចោរកំហែងរំលោភបៀតបៀនក៏មាន ជួនកាលត្រូវសត្វសាហាវមានខ្លាជាដើមបៀតបៀនក៏មាន ជួនកាលត្រូវអមនុស្ស ឬភូតបិសាចធ្វើទុក្ខបំភ័យបៀតបៀនក៏មាន ។ល។ ការធ្វើដំណើររបស់មនុស្សទាំងឡាយក្នុងលោក រមែងជួបប្រទះនឹងទុក្ខលំបាកឬអន្តរាយណាមួយទោះតូចឬធំ ទឹងគេចចៀសវាងពុំរួចឡើយយ៉ាងណា, ឯសត្វទាំងឡាយ ដែលអាស្រ័យនៅក្នុងវដ្តសង្សារក៏ដូច្នោះដែរ ។ បើសត្វទាំងឡាយ អន្ទោលទៅមកនៅក្នុងវដ្តៈដរាបណា ក៏ឈ្មោះថាជាអ្នកដើរទៅកាន់ផ្លូវឆ្ងាយ ឬជាអ្នកដំណើរដរាបនោះ. ព្រោះហេតុអ្វី! ព្រោះហេតុថា វដ្តៈមិនទាន់អស់នៅឡើយ សូម្បីអរិយបុគ្គលទាំងឡាយមានសោតា-បន្នបុគ្គលជាដើម ក៏ឈ្មោះថាជាអ្នកដំណើរដែរ. លុះតែព្រះអរហន្តខី-ណាស្រពដែលធ្វើវដ្តៈឲ្យខូចអស់ហើយ ទើបឈ្មោះថាលោកមានផ្លូវឆ្ងាយដល់ហើយ ឬថាលោកមានដំណើរដល់ទីស្រេចហើយ ។

ពាក្យថា វដ្តៈ ប្រែថា គ្រឿងវិល ឬថា ធម៌ជាគ្រឿងបង្វិលសត្វ ។ វដ្តៈ មាន ៣ យ៉ាងគឺ កិលេសវដ្តៈ វដ្តៈគឺកិលេស ១ កម្មវដ្តៈ

វដ្តៈគឺកម្ម ១ វិបាកវដ្តៈ វដ្តៈគឺវិបាក ១ ។ បដិសន្ធិវិញ្ញាណរបស់សត្វ ដែលអន្ទោលវិលវល់ទៅមកក្នុងភពតូច ធំ មិនមានទីបំផុត ក៏ដោយអំណាចកិលេសជាបច្ច័យ ដូចតណ្ហាជាកិលេសជាតិ នាំសត្វឲ្យប្រាថ្នាជាប់ស្អិតក្នុងវត្ថុកាមនិងកិលេសកាម, កោធៈ សេចក្ដីក្រោធខឹងចំពោះសត្វនិងសង្ខារដទៃប៉ុណ្ណោះជាដើម ហៅថា កិលេសវដ្តៈ ។ កាលបើកិលេសមាន, កម្មគឺអំពើក៏មានដែរ គឺថាកិលេសជាហេតុដឹកនាំសត្វឲ្យមានការស្វះស្វែងធ្វើនូវកិច្ចការផ្សេងៗ, កម្មជាគ្រឿងញ៉ាំងសត្វឲ្យស្ទុះស្ទាឥតឈប់ឈរ ដូច្នេះទើបហៅថាកម្មវដ្តៈ ។ កាលបើកម្មវដ្តៈមាន, វិបាកវដ្តៈក៏មានដែរ ព្រោះវិបាកគឺផលរបស់កម្មជាកុសលឬអកុសលរមែងនាំសត្វឲ្យវិលវល់ជាប់នៅក្នុងលោកគ្មានទីបំផុត ទើបហៅថាវិបាកវដ្តៈ វដ្តៈទាំង៣នេះ ជាហេតុ ជាផលជាប់ទាក់ទងដល់គ្នានិងគ្នា គឺកាលបើកិលេសកើតមានឡើង ជាហេតុ ជាបច្ច័យនាំសត្វឲ្យធ្វើនូវកម្ម កាលបើកម្មកើតមានឡើង ជាហេតុ ជាបច្ច័យនាំសត្វឲ្យបានជួបប្រទះនូវវិបាកគឺផល កាលបើវិបាកគឺផលកើតមានឡើង ក៏ប្រែត្រឡប់ទៅជាហេតុនាំសត្វឲ្យជាប់ចិត្តញ៉ាមចំពោះអារម្មណ៍នោះៗទៀត រហូតទាល់តែចិត្តសៅហ្មងនាំឲ្យវង្វេងវង្វាន់វិលវល់ ប្រកបដោយកិលេសមានអវិជ្ជានិងតណ្ហាជាដើម ។ កាលបើវដ្តៈរបស់សត្វឋិតនៅមានដរាបណា, សត្វក៏រមែងស្ទុះស្ទាវិលវល់ទៅមក នៅក្នុងភពរកទីបំផុតគ្មានដរាបនោះ ។

ក្នុងផ្លូវអគ្គបទនេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងអំពីទុក្ខរបស់បុគ្គល អ្នកធ្វើដំណើរទៅកាន់ផ្លូវឆ្ងាយគឺវដ្ដៈ ។ បុគ្គលណា ដើរទៅកាន់ផ្លូវឆ្ងាយគឺវដ្ដៈ បុគ្គលនោះ ត្រូវទុក្ខជាប់តាមជានិច្ចគ្រប់ជាតិ ដូចជាកង់រទេះប្រកិតជាប់តាមជើងគោដែលគេទឹមក្នុងនឹម, ពុំនោះសោត ដូចស្រមោលដែលអន្ទោលជាប់តាមប្រាណរបស់បុគ្គល ព្រោះថាបុគ្គលដែលនៅមានពូជគឺកំណើតមិនទាន់អស់ ឬមិនទាន់ផុតរលត់នៅឡើយ តែងមានដំណើរវិលវល់នៅក្នុងភពគឺចេញចាកភពមួយ ទៅកាន់ភពមួយទៀត ឬចេញចាកកំណើតមួយ ទៅកាន់កំណើតមួយទៀតជាប់ត ៗ គ្មាមិនមានទីបំផុត គ្រាន់តែខ្ពស់ទីងទាប ល្អនិងអាក្រក់ប៉ុណ្ណោះ, ទោះបីទៅកើតក្នុងកំណើតណាឬក្នុងភពណា រមែងមានភ្លើងទុក្ខគឺ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ ជាដើម និងភ្លើងកិលេសមាន រាគៈ ទោសៈ មោហៈ ជាដើម ប្រកិតជាប់តាមដុតរោលកំដៅបៀតបៀនញាំញីបុគ្គលនោះ ឲ្យទទួលរងទុក្ខទោសគ្រោះថ្នាក់គ្រប់ជាតិក្នុងភពនោះៗ ឥតមានស្រាកស្រាន្តឡើយ ។ បុគ្គលដែលអន្ទោលទៅមកកើតស្លាប់វិលវល់ក្នុងវដ្ដៈនេះ ដរាបណា; ទុក្ខទាំងអស់ រមែងជាប់តាមបៀតបៀនបុគ្គលនោះដរាបនោះដែរ បើបុគ្គលមានវដ្ដៈអស់ត្រឹមណា ទុក្ខក៏អស់ត្រឹមនោះដែរ ។ ព្រោះហេតុនោះ បានជាព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងថា ទុក្ខានុបតិតទ្ធគូ បុគ្គល

អ្នកដើរទៅកាន់ផ្លូវឆ្ងាយគឺវដ្ដៈ រមែងត្រូវសេចក្ដីទុក្ខគ្រប់យ៉ាងជាប់តាម ហេតុនោះ បុគ្គលមិនត្រូវដើរទៅកាន់ផ្លូវឆ្ងាយគឺវដ្ដៈ ទាំងមិនត្រូវបណ្ដោយខ្លួនឲ្យសេចក្ដីទុក្ខជាប់តាមៈឡើយ ។

នៅទីអវសាននៃធម្មទេសនារបស់ព្រះមានព្រះភាគហើយ វឌ្ឍបុត្តក-ភិក្ខុនោះ ក៏នឿយណាយចំពោះទុក្ខទាំង ៥ យ៉ាង ដែលព្រះអង្គទ្រង់លើកឡើងសម្ដែងចំពោះខ្លួន, ហើយរំលាយផ្ដាច់នូវសំយោជនៈទាំងពីរចំណែក គឺចំណែកខាងក្រោម៥ និងចំណែកខាងលើ៥ ហើយបានឋិតនៅក្នុងអរហត្តផល ផុតបាកវដ្ដៈត្រឹមនេះឯង ។

ចប់ទុក្ខធម្មកថាដោយសង្ខេប

# ការបម្រើន និង ការវិនាស នៃបំនួនមនុស្ស

លោក ជល-ឌិន រៀបរៀង

សម័យមួយនោះ មានព្រាហ្មណ៍មហាសាលម្នាក់ បានចូលទៅសុំគាល់ព្រះមានព្រះភាគ ។ លុះចូលដល់ អង្គុយកន្លែងដ៏សមគួរហើយ, ព្រាហ្មណ៍នោះក៏បង្គំទូលសួរព្រះមានព្រះភាគថា(១)

បពិត្រព្រះគោតម ! ខ្ញុំបានឮពួកព្រាហ្មណ៍ជំនាន់មុន ដែលមានវ័យច្រើន ចាស់ៗ ហើយជាអាចារ្យតៗមក និយាយថា កាលពីដើម, ពិភពលោកយើងនេះ មានមនុស្សកុះករច្រើន ពាសពេញ ហាក់ដូចជានៅអវិចិមហានរក, ស្រុក និគម ជនបទ រាជធានី នៅជិតៗគ្នា ល្មមចម្ងាយមួយបង្ហើរមាន់ (មាន់ហើរដល់) ។ បពិត្រព្រះគោតម ចុះហេតុបច្ច័យដូចម្ដេច បានជាមនុស្សសម័យឥឡូវនេះ នៅតិចទៅវិញ, ត្រង់កន្លែងធ្លាប់ជាស្រុក ទៅជាលែងមានស្រុក , កន្លែងនិគមទៅជាមិនមែននិគម, កន្លែងទីក្រុង ទៅជាមិនមែនទីក្រុង , កន្លែងជនបទ ទៅជាមិនមែនជនបទវិញ ?

ព្រះមានព្រះភាគទ្រង់ឆ្លើយថា

ម្នាលព្រាហ្មណ៍ ! មកតែពីពួកមនុស្សសម័យនេះ ចូលចិត្តតែនឹង

---

១ សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ទុតិយភាគ ៤១ ទំព័រ ១៤៤

អធម្មរាគៈ, ត្រូវ វិសមលោភៈ សង្កត់សង្កិន, ទាំងត្រូវមិច្ឆាធម៌ របរិត ។ ព្រោះថា ពួកមនុស្ស កាលបើចូលចិត្តតែទីង អធម្មរាគៈ, ត្រូវ វិសមលោភៈ សង្កត់សង្កិន, ត្រូវមិច្ឆាធម៌ រឹតរួតហើយ តែងតែចាប់គ្រឿងសាស្ត្រាវុធធ្វើសង្គ្រាមកាប់សម្លាប់គ្នា, តែងតែស្លាប់ដោយអត់ឃ្លាន ព្រោះពាំងភ្លៀង កើតទុរ្ភិក្ស សំទូងមិនល្អ ត្រូវក្រាស៊ី ស្កកស៊ីផង, តែងតែត្រូវស្លាប់វិនាសជាច្រើន ដោយពួកយក្សដែលលែងពួកអមនុស្សដ៏កាចសាហាវ ឲ្យមកចាប់ (បណ្តាលជម្ងឺគាំគាត់ រោគាព្យាធិ ចបទ្រពចង្រៃផ្សេង ៗ) ទៀតផង ។ ម្នាលព្រាហ្មណ៍នេះឯង ជាហេតុ ជាបច្ច័យ ដែលនាំឲ្យពួកមនុស្សសម័យនេះ ចេះតែលេសាទៅ ទៅសល់ចំនួនតិច ។

យោបល់បន្ថែម

បើតាមព្រះសូត្រខាងលើនេះ, យើងអាចស្រាវជ្រាវថយទៅក្រោយរហូតដល់សម័យមុនប្រវត្តិសាស្ត្រថា កាលដើមឡើយ មនុស្សយើងដែលទើបនឹងចាប់ផ្តើមកើតឡើង មានចំនួនតិចជាអប្បបរិមាណ, តែដោយសារមនុស្សចេះកសាងមនុស្ស ទើបចំនួនមនុស្ស រឹតតែកើនឡើងជាលំដាប់ ដែលគ្មានអ្វីអាចទប់ការចម្រើននេះបានឡើយ ។ លុះចំនួនមនុស្សរឹតតែច្រើនឡើង, ការបង្កៀតបង្អល់គានគឺងគ្រប់ផ្លូវ ក៏រឹតតែមានច្រើនឡើងដែរ ។ រឿងនេះ ក៏កើតទៅជាបញ្ហាសម្រាប់

មនុស្សដោះស្រាយ ៗ ប៉ុន្តែចំនួនមនុស្ស ដែលកើតឡើងដូច្នេះ គង់តែមានថ្ងៃណាមួយ ត្រូវថយទៅវិញដែរ ៗ ក្នុងព្រះសូត្រ បានប្រាប់យើងថា. មកពីមនុស្សប្រព្រឹត្តធម៌ ៣ ប្រការ គឺ អធម្មរាគៈ១ វិសមលោភៈ១ មិច្ឆាធម៌១ ៗ

១- អធម្មរាគៈ តម្រេកក្នុងអធម៌ គឺការចូលចិត្តធ្វើនូវអំពើ ដែលមិនត្រូវតាមច្បាប់ ៗ ដូចជា ឪពុកទៅស្នេហាដោយកាមៈ នឹងកូនក្រមុំខ្លួនឯង, បងប្អូនបង្កើតយកគ្នាជាប្តីប្រពន្ធ, ប្រុសធ្វើមេថុនជាមួយនឹងប្រុស, មនុស្សស្នេហានឹងសត្វ, អ្នកកាន់ឧបោសថសីលទៅជាហ៊ានមើលកំប្រៀង, បរិភោគអាហារល្ងាច, ដេកលើសេនាសនៈខ្ពស់ហួសប្រមាណនឹងសេនាសនៈប្រសើរជាដើម ៗ

១- វិសមលោភៈ ការលោភលន់មិនទេះសមល្មម គឺការលោភលន់មិនធួនចិត្ត មិនស្គាល់របស់គេរបស់ឯង ដូចជា អ្នកមានប្រពន្ធហើយ ទៅលបលួចប្រពន្ធអ្នកដទៃទៀត, អ្នកមានប្តីហើយ លួចផិតក្បត់នឹងប្រុសឯទៀត, អ្នកមានទ្រព្យហើយ ប្រើវិធីដញ្ជក់យកទ្រព្យពីអ្នកដទៃទៀត, អ្នកមានប្រាក់ខែរាជការហើយ លួចស៊ីសំណូកទៀត, អ្នកមានអំណាចយសស័ក្តិប៉ុណ្ណោះហើយ ប្រឹងធ្វៀតឈ្លបរកបុណ្យស័ក្តិអំណាចហួសមាឌប៉ុណ្ណោះទៅទៀត, អ្នកមានដីធ្លីហើយ ប្រឹងធ្វើល្បិចកលយកដីធ្លីអ្នកដទៃទៀត, អ្នកមានប្រទេសមួយហើយ ចង់ពង្រីក

យកប្រទេសដទៃទៀត, អ្នកមានអំណាចចក្រពត្តិលើប្រទេសមួយចំនួន ហើយ ចង់ពង្រីកអំណាចចក្រពត្តិទៅលើប្រទេសមួយចំនួនដទៃទៀត យ៉ាង នេះជាដើម ។

៣. មិច្ឆាធម៌ ធម៌ខុស គឺធម៌គ្រឡប់គ្រឡិន បានដល់ ការប្រព្រឹត្តិខាងធ្វើឲ្យខុសពីការពិត ដូចជា អ្នកកាត់ក្តីស៊ីសំណូក កាត់ ឲ្យអ្នកត្រូវទៅជាខុស, កាត់អ្នកខុសទៅជាត្រូវវិញ, អ្នកប្រព្រឹត្តធម៌ បែរជាប្រព្រឹត្តអធម៌ដោយគិតថាជាធម៌វិញ, អ្នកនិយាយ បែរជានិយាយ រឿងពិតថាពុំពិត, រឿងល្អថាអាក្រក់. រឿងខុសថាត្រូវវិញ ជាដើម ។

ដូច្នេះ បើយើងធ្លុះមើលស្រមោលធម៌ទាំង ៣ ប្រការ ដែលបាន អធិប្បាយសង្ខេបនេះ, ក៏ឃើញច្បាស់ថា ពិតជាធម៌បំផ្លាញចំនួនមនុស្ស ឲ្យតិចចុះទៅវិញមែន, ពីព្រោះមនុស្សយើង តែមានការបំពារបំពានលើ កូនប្រពន្ធគ្នា, លើទ្រព្យសម្បត្តិគ្នា, លើជីវិតគ្នា, លើកិច្ចការគ្នា, លើការខុសត្រូវរបស់គ្នា . . . ដូច្នេះហើយ ទើងតែពីមានការក្តៅ ក្រហាយ បៀតបៀន ប្រទូស្តរ៉ាយគ្នា រហូតដល់ប្រកាប់ប្រចាក់ ធ្វើ ចម្បាំងកាំងដល់ទីងគ្នា, កើតអត់ឃ្លាន. កើតជម្ងឺកាត់ស្លាប់ហិនហោច ពលដាលពុំខាន ។ យើងនឹកមកសម័យសព្វថ្ងៃនេះវិញ ពិភពលោក សព្វថ្ងៃ មានការកើតចំនួនមនុស្សរឹតតែច្រើនឡើងឥតអាក់យ៉ាងនេះ តើ មានថ្ងៃទីងថយទៅវិញឬទេ ? រឿងនេះបើតាមស្រមោលព្រឹត្តិការណ៍សព្វ

ថៃ ដូចជាគេចមិនរួចពីការវិនាសចំនួនមនុស្សទៅវិញ ពីព្រោះមនុស្សសព្វថ្ងៃនេះ ធ្ងន់ដោយធម៌ទាំង ៣ នេះណាស់ ស្ទើរតែនឹងក្រឡាប់ផ្កាប់ផ្កាទៅហើយ ។ ឯវិទ្យាសាស្ត្រ ពិតជារកឃើញនូវគុណប្រយោជន៍យ៉ាងខ្ពស់បំផុត មកជួយស្រោចស្រង់មនុស្សជាតិហើយ, ប៉ុន្តែវិទ្យាសាស្ត្រ ក៏នាំយកនូវទោសដ៏អាក្រក់មកបំផ្លាញមនុស្ស យ៉ាងធំបំផុត ប៉ុនគ្នានឹងគុណនោះដែរ ។

– ចប់ –

# ផ្នែកអក្សរសាស្ត្រ

| | |
|---|---|
| អក្សរសាស្ត្រខ្មែរ | ខ្មែរគួរថែថ្នម |
| ឲ្យបានខ្ជាប់ខ្ជួន | គង់វង្សគត់មត់ |
| ព្រោះអក្សរជាតិ | គោលជាតិប្រាកដ |
| អក្សររលត់ | ជាតិក៏រលាយ |

ប.ព.

## វិបគានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចាំង ខាត់ រៀបរៀង*

អនុតឞ៌ បុំ. សេចក្តីស្រេកឃ្លាន, ទឹកស្រវឹង ។

អនុតឞ៌ុល គុ. ដែលធ្វើឲ្យស្រេក ។

អនុតាប បុំ សេចក្តីក្តៅក្រហាយ, សេចក្តីទុក្ខ ។

អនុតាបន គុ. ដែលធ្វើឲ្យក្តៅក្រហាយ, ។

អនុត្ឫប៑ ណគុ. ឆ្អែត ។

អនុទ្ឃាត នបុំ. ដីមិនគ្រហូង, ដីរាប ។

អនុត្តម គុ. ដែលមិនមានអ្នកដទៃឧត្តមជាង, ឧត្តមលើស ។

អនុត្តរ គុ. ដែលមានអ្នកដទៃប្រសើរជាងមិនមាន, ប្រសើរលើស ។

អនុត្តរង្គ គុ. ដែលមិនមានរលក ។

អនុត្តាន គុ. ដែលមិនមានសំឡេងខ្លាំង ។

អនុត្តារ គុ. ដែលរត់ចេញមិនបាន ។

អនុត្ថាន គុ. ដែលមិនក្រោកឡើង, ដែលមិនព្យាយាម ។

អនុត្បាទ គុ. ដែលមិនលេចឡើង ។

អនុត្សាហ បុ. កិរិយាមិនឧស្សាហ៍, អនុត្សាហិន គុ. ដែលមិនមានឧស្សាហ៍, ខ្ជិល ។

អនុត្សុកតា ស្ត្រី. កិរិយាមិនមានបំណង់, កិរិយាមិនមានបំណង ។

អនុត្សូត្របទន្យាស គុ. ( អន+ឧត្សូត្រ+បទ+ន្យាស )
ដែលមានកិរិយាដាក់នូវបទក្រៅសូត្រ, ទំនាស់នយោបាយមិនមាន
ដែលមានកិរិយាប្រើនូវបទទុបវេយ្យាករណ៍មិនមាន ។

អនុត្សេក បុ. កិរិយាមិនមានបរិបុណ្ណភាព, កិរិយាមិនឡើងឫក ។
អនុត្សេកិន គុ. ដែលមិនវ៉ៃឫក ។

អនុទក គុ. ដែលមិនមានទឹក ។ នបុ. កិរិយាមិនមានទឹក, រដូវរាំងភ្លៀង ។

អនុទណ្ឌិ នបុ. ឆ្អឹងខ្នង ។

អនុទបាន នបុំ. កិរិយាមិនមានទឹកផឹក។

អនុទយ បុំ. អនុទ័យ. កិរិយាមិនរះឡើង ។ ភាជិ គុ. (ព្រះចន្ទ្រ) ដែលមិនរះឡើង ។

អនុទតិ នបុំ. កិរិយាយកចិត្តទុកដាក់ ។ អនុទតិន៍ គុ. ដែលយកចិត្តទុកដាក់។

អនុទហ៍ ធាតុ. ដេះរឿយៗ, ដេះតាម ។

អនុទា ធាតុ. ភាយ. ដាល់, តប់ ។

អនុទាត្ត គុ. (ពាន) ដែលមិនឡើងខ្ពស់ ។ បុំ. កិរិយាមិនមានពាន ។

អនុទារ គុ. (អន + ឧទារ) ដែលឥតអភិជនភាព ។

អនុទារ គុ. (អនុ + ទារ) អនុទារ ដែលនៅក្នុងអំណាចប្រពន្ធ. ដែលមានប្រពន្ធនៅក្នុងអំណាច ។

អនុទាសិន គុ. ដែលមិនព្រងើយកន្តើយ ។

(នៅមានត)

# កាព្យនិទាន

## រំលឹកដល់អក្សរសាស្ត្រសម័យអង្គរ

### បទភុជង្គ

ភុជង្គប្រុងមើលចុះហ្ម   នៅលើផ្ទាំងថ្ម   អក្សរខេមរ ៗ
តម្លៃស្នាដៃដូនតា   គួរឆ្លាក់បែងចារ   ច្រើនឆ្នាំកន្លង ៗ
ឲ្យដឹងដំណើរដើមទង   វប្បធម៌រៀមច្បង   រុងរឿងជាក់ច្បាស់ ៗ
អក្សរគឺអក្សរសាស្ត្រ   លូតលាស់រហ័ស   ពាសពេញកម្ពុជា ៗ
អក្សរលើថ្មនានា   បណ្ឌិតព្រឹទ្ធា   ចារិកមានន័យ ៗ
ជម្រៅជ្រាលជ្រៅប្រពៃ   បង្ហាញតម្លៃ   អក្សរសាស្ត្រខ្មែរ ៗ
ទស្សនវិជ្ជាពូកែ   កកើតហូរហែ   ជាប់ផែនសិលា ៗ
មែនពិតអតីតខេមរា   ហឫទ័យស្នេហា   អក្សរសាស្ត្រជាតិ ៗ
ហេតុផលលោកយល់ឥតឃ្លាត   មូលដ្ឋាននៃជាតិ   គឺអក្សរសាស្ត្រ ៗ
អក្សរប្រដូចពានថាស   ទ្រទ្រង់ឱភាស   ភាសាសំដី ៗ
នូវចិត្តគំនិតលោកិយ   ឲ្យមានមេត្រី   វប្បធម៌ជាតិឯង ៗ
កាន់តាមទំនៀមផ្សេងៗ   ជាគ្រឿងសម្តែង   ដល់ជាតិដទៃ ៗ
បានយល់ឫសគល់តម្លៃ   ដូចខ្មែរសម័យ   អង្គរវត្តថ្កើង ៗ
ឥឡូវពង្សផៅខ្មែរយើង   យល់រឿងនេះឡើង   ស្រណោះខ្លោចផ្សា ៗ
ប្រឹងគ្រាប់តម្រាប់ដូនតា   ករៀនតម្រា   អក្សរសាស្ត្រខ្មែរ ៗ
សង្ឃឹមញញឹមហូរហែ   ថ្ងៃមួយកែប្រែ   ប្រើអក្សរសាស្ត្រ(១) ៗ
ឲ្យបានថ្កើងថ្កានជាក់ច្បាស់   ដូចខ្មែរជាន់ចាស់   សម័យអង្គរ ៗ

១ គឺអក្សរសាស្ត្រខ្មែរ ។

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ភាគ ៩

( ត )

លោក ឌឹក-គាម

ស្រាវជ្រាវ និង រៀបរៀង

ខ្លះក៏តែស្លុងទៅរកមេមត់ពេទ្យហ្លួងក្រទាំងវាំងជ័យ ខ្លះក៏ភ័យតែទៅក្រាបទូលក្រុងទសកក្រាអសុរ ដល់ហើយ ក៏លើកហត្ថវន្ទាទូលសេចក្តីថា ព្រះអគ្គមហេសីប្រឈួនព្រះទទ្រាំងក្រៃ ៗ កាលណោះ ក្រុងទស-ភ័ក្ត្រវៀនជ័យបានស្តាប់ហើយក៏ភ័យរំជួលក្តួលក្រុកកែតក្តុល់ អសុរីកំហល់កំក្រោកស្ទុះទៅមួយរំពេចវៃ លុះដល់ហើយវៃ ក៏មានឧង្ការសួរទៅពួកជួនមបទាំងពួងតាមតូចធំ ថាវៃឆ្មបពល់គ្នា ចូរជួយទំនុកបំរុងនាងកល្យា-ណីកុំឲ្យដល់ក្តីអន្តរាយឡើយ ៗ កាលគ្រានោះ រីនាងមន្ទោទរីនោះលុះដល់សុកឫក្សវេលានាទីល្អហើយ នាងក៏ប្រសូតព្រះរាជកុមារីហោង ៗ រីរូបកុមារីនោះ ហ្មត់ហ្មង់ល្អល្អះឆើតឆោមឆវីវណ្ណសំខាន់លើសលើលោកទាំងបីត្រៃភព តែកាលគ្រានោះខុសពីពង្សសុរ្យវង្សយក្ស ក្នុងក្រុងលង្កាទ្វីបហើយនាងកុមារីនោះលុះស្រែកយំឡើងកាលណា ថាលាញលង្កាហើយនឹងបំផ្លាញពពណាសូរឲ្យសូន្យហោង ៗ នាងកុមារី ស្រែកយំនោះចំពោះតែបីមាត់ក៏បាត់យំស្ងៀមទៅ កាលនាងស្រែកយំនោះអ្នកទាំងគស់

នៅទីនទំនោះ ក៏បានឮប្រាស់តែគ្រប់ៗគ្នា តែមាតានិងបិតានោះពុំបាន ឮឡើយ ។ ហើយកាលណោះ ក្រុងទសមុខមារនោះ លុះទតយល់ ឃើញរូបឆោមនាងកុមារីរាជបុត្រីនោះល្អណាស់ អសុរក៏មានក្តីស្នេហា ស្រឡាញ់ពេញចិត្តក្រៃ ទើបមានឱង្ការបង្គាប់ពួកភ្នាក់ងារស្រី ៗ ថា ចូរឯងឃ្មាតខ្មីទៅហៅពិភេកអសុរ និងរាជហោរាធិបតីមកឆាប់ៗឥឡូវនេះហោង ។ គ្រានោះ ទើបអស់ស្រីបំរើនោះផង បានស្តាប់ព្រះតម្រាស់ត្រាស់ប្រើហើយ ពុំបង់ឡើយក៏ថ្វាយបង្គំលាទៅ លុះដល់លំនៅមន្ទីរប្រាសាទពិភេកអសុរ ក៏ទូលថា សម្តេចព្រះចមចក្រពង្សលង្កាឲ្យអញ្ជើញ ព្រះអង្គនិងពួកហោរាផង ទៅគាល់ក្នុងវេលាគ្រាឥឡូវនេះ ព្រោះដ្បិតនាងមន្ទោទរីប្រសូតរាជកុមារីសូមទ្រង់ជ្រាប ។ កាលណោះ ពិភេកសុរវង្សទ្រង់អានុភាពបានជ្រាបសេចក្តីហើយ ក៏នាំពួកហោរាយាត្រាទៅ លុះដល់ហើយក្បូវក៏ក្រាបថ្វាយបង្គំក្រុងទសមុខមារ ព្រមដោយពួកព្រឹទ្ធាចារ្យ តូចធំប្រជុំក្នុងទីមហាប្រាសាទជ័យ រង់គាល់ចាំស្តាប់នៃទេវឱង្ការ ។ ទើបក្រុងអសុរនោះ លុះឃើញពិភេកមកដូច្នោះហើយ ទើបស្តេចចំពោះមានព្រះរាជាថា ម្នាលពិភេកហោរាអនុជអើយ ប្អូនអើយឥឡូវនេះនាងមន្ទោទេវី ប្រសូតរាជធីតាជាក្មួយអ្នក នោះរូបឆោមឆាយាល្អដូចទេពកញ្ញា ចូរមកពិគ្រោះមើលជតារាសីតើល្អយ៉ាងណា ។ កាលណោះ ពិភេកអសុរក្រាបថ្វាយបង្គំហើយក៏ចាប់យកដីសនៅក្តារ

ឈ្មីន មួយរំពេចស្រេចទើបតាំងចុល្លសកពជ អាចទឹងគណនាមាសកេណ្ឌ កំណត់ហើយតាំងគុណហារបូកលុបចុះជាអវមាណ តាមស្ថានដេញក្នុងគម្ពីរ វៃសយ បាន។ច្បាវិលាសកពជយោគជាគកេណ្ឌ។ត្តមឯកពសី លក្ខណា មេសពសី សុវត្ថិ បុក្យពារនាទីល្អប្រសើរណាស់ នាងធីតានោះល្អព្រម ទាំងរូបទាំងអង្គលក្ខណាឆោមឆាយ ត្រូវជាគូសំពប់កាយបុនបរមចក្រ-ពត្តិ ទើបពិភេកក៏ត្រឡប់មើលពីជតាពសីសម្តេចព្រះជេដ្ឋាបមលង្កាវិញ នោះ លុះពិគ្រោះមើលទៅឃើញថា លក្ខណាព្រះច័ន្ទជាកាឡកណ្ណី ហើយពិភេកអសុរី ក៏រៃមើលសព្វជតាក្រុងអសុរទេសកគ្រ្ត ឲ្យល្អិតទៅ ឃើញថា ព្រះសៅរ៍ខាំលក្ខណាក្នុងពសីដូច្នោះហើយ ទើបក្រាបទូល ថា វព្រះរាជបុត្រីនេះនឹងកហេតុកើតកលិយុគក្នុងក្រុងលង្កាទ្វីប នឹង បំពាំមទុកទៅឃើញជាពុំបានឡើយ ដូចជាយកភ្លើងមកដុតបំផ្លាញព្រះ នគរលង្កាធេះជាផង់ធូលីវិនាសអស់ហោង ថាបើព្រះជេដ្ឋាអាល័យស្រ-ឡាញ់រាជធីតានឹងចិញ្ចឹមទុកមែនហើយ នឹងសាបសូន្យសុរ្យវង្សពង្សព្រហ្ម នឹងកើតចំបាំងច្បាំងគ្នា រណោមនោះ ប្រៀបបីដូចជារាវទកក្នុងសមុទ្រសាគរ សូមព្រះជេដ្ឋាយកធីតាទៅបោលក្នុងទឹកសមុទ្រចេញ ទើបនឹងបានផុតពន់ ពិពក្តីសៅហ្មង ៗ កាលណោះ វនាងមន្ទោទរល្អង បានស្តាប់ពិភេក អនុជាព្យាករណ៍ទំនាយដូច្នោះហើយ នាងក៏ស្មើរទឹងក្ស័យដីរ ទើប នាងមានវាទីថាពិភេកអើយ ឯងនេះពេញជាមានចិត្តឥច្ឆាព្យាបាទក្លៀងទាយ

ថា កូនអញនេះអាក្រក់ក្រៃង្រៃចង់បំផ្លាញជីវិតកូនអញ នាងថាតែម៉្លោះ ហើយ នាងក៏ទ្រង់ព្រះកន្សែងថា ឱពជធីតាមាសម្តាយអើយ កូនអើយ អ្នកកើតមកម្តាយសែនស្រឡាញ់ពេញចិត្តណាស់ មិនគួរឡើយអ្នកមកវិនាសប្រាសទៅគឺបុណ្យកូនពៅអ្នកតិចម៉្លេះ ក្នុងគ្រានេះបិតាអ្នកសោតក៏មានក្តីមេត្រីស្រឡាញ់កូនណាស់ដែរ ប៉ុន្តែថាបើកូនឯងនេះជាកាឡកណ្ណីពិតហើយ កូនអើយខ្ញុំម្តាយនេះគេនឹងល្អពីណាមក មានតែកាឡកណ្ណីដូចគ្នាដែរ ៗ ចូរអ្នកសម្លាប់ម្តាយឲ្យស្លាប់ជាមួយនឹងគ្នាទៅកុំទុកឲ្យនៅរស់ថ្វី ព្រះអង្គនឹងត្រូវការធ្វើអ្វីខ្ញុំម្ចាស់ជាប្រពន្ធសំឡាញ់ព្រះអង្គ ទ្រង់នឹងចិញ្ចឹមទុកនៅក្នុងនគរលង្កា នឹងជាពង្សវង្សាយក្សទាំងប៉ុន្មានឲ្យថោកទាបសក្តិយសទាំងអស់ហោង ៗ ថាហើយនាងក៏គគក់ព្រះឧរាសោកាទួញទំនួញទៅស្មើរនឹងក្ស័យព្រះជន្មា ៗ កាលណោះ ក្រុងទសក្រ្ពអសុរឃើញនាងមន្ទោទរីសោកាទួញយំរៀបរាប់សព្វគ្រប់ប្រការ ហើយក្រុង-មារក៏និយាយយាត់លួងលោមដោយទូវពាចាល្អថា ម្នាលកែវដើរនាងកុំថាដូច្នោះពុំខុសទេ មាសមេ ពិភេកនេះក៏ស្រឡាញ់ក្មួយដូចដួងជីវិតដែរ មាសស្នេហ៍កាលណានឹងក្លួងគែងចបាយចាយទៅនោះ បំពោះមិនមែនទេអ្នកមាសថ្លៃ អើថាបើអ្នកនៅសង្ស័យនៃអសុរពិភេកក្លែងចាយនោះ ពួកហោរាទាំងអស់នៅប្រជុំព្រមក្នុងទីនេះ ចូរឲ្យសមជេញមើលទៀតឲ្យដឹងជាកាចប្តូរអាក្រក់ប្តូរល្អ ក៏នឹងអស់មន្ទិលពិភាល់សង្ស័យ គ្រាស់ហើយ

កូនទ័យស្ដេចក៏មានព្រះឱង្ការប្រើឲ្យហោរាចារ្យ ទាំងអស់គ្នាតូចធំផ្គុំគ្នាជួយមើលឡើងជាអាក្រក់ល្អកុំឲ្យកោតញញើតអញឡើយ ឃើញដូចម្ដេចក្ដីចូរហោរអ្នកស្ដីទាយឲ្យប្រាកដច្បាស់ ។ កាលណោះ ពួកបុរោហិតហោរាសាស្ត្រទាំងពួងនោះ ក៏ក្រាបបង្គំទូលថា ទ្រង់កុំព្រួយព្រះទ័យឡើយ ហើយក៏តាំងពិចារណាមើលតាមអន្សានាងទេវីបុករ្មទិងបុរណិទ្ធទិន ចូលផងហើយក៏តាំងចេញដេញគុណហារ តាមតំរាសៃយសព្វគ្រប់ប្រការទៅក៏ត្រូវឃើញថា ជាកាឡកណ្ណីដល់បុរីនគរទាំងអង្គព្រះបិតាផង ទើបហោរាទាំងអស់ហោង ក៏ក្រាបបង្គំទូលព្រមគ្នាថា ដរាព្រះរាជធីតាទិវសនេះ ជាសត្រូវនឹងព្រះអង្គហើយ ដូចរាហូចូលចាប់ព្រះចន្ទ្រានឹងចិញ្ចឹមរក្សាទុកពុំបានគ្មានប្រយោជន៍ កូននោះនឹងបង្កើតឲ្យជាមានទោសប្រាកដពិតទំនាយថា ព្រះទ្រង់បុទ្ធិនឹងសូន្យសុរ្យវង្សពង្សពូជព្រហ្ម ត្រូវដូចជាស្ដេចព្រះអនុជទូលទ្រង់ព្រះករុណា ។ កាលណោះ ក្រុងទសក្រ្តយក្សបានស្ដាប់ពាក្យហោរាទាំងពួងក្រាបទូលហើយ ក៏ស្ដេចបែរព្រះភក្ត្រមកកាន់នាងមន្ទោ ហើយក៏មានឱង្ការថា ម្នាលនាងដ៏ចំរើនអើយកែវអើយ រាជធីតាកុមារីកូនយើងនេះ បងក៏មានចិត្តស្រឡាញ់អាល័យណាស់ដែរ តែថាឥឡូវនេះ បើកើតមកហើយត្រូវបំផ្លាញយកជីវិតយើងៗនឹងចិញ្ចឹមទុកនៅដូចម្ដេចបាន ណ្ហើយចុះ ចូរនាងកុំសោយសោកាយំអាល័យអាឡោះឡើយ កែវអើយទំកាត់ចិត្តថ្វើមទៅ ត្រាស់ហើយ

ទើបបង្គាប់ទៅនឹងពិភេកថា អនុជអ្នកយល់ការ កូនអញនេះជាកាឡ-
កណ្ណី តាមតែអសុរឯងចាត់ចែងតាមការ ឲ្យគួរនឹងវេណីពីបុរាណរាជ ។
កាលណោះ ពិភេកអសុរបានស្តាប់ព្រះឱង្ការហើយ ពុំលង់ឡើយក៏យក
ប្រអប់កែវមណីរតនាមកទឹងដាក់ព្រះរាជបុត្រី ។ កាលណោះ វិនាង
មន្ទោមហេសីនោះ លុះឃើញប្រអប់កែវហើយ នាងក៏សោយសោកគគក់
ព្រះឧរ ហើយក៏ពោកខ្លួនទួញថា ឱកូនអើយកូនស្រីសំឡាញ់ម្តាយៗ
ឱស្សាហ៍ថ្នមពពោះអ្នកមកពុំឲ្យសៅហ្មង ពោះដើរក្តី ដេកឬឈរអង្គុយ
ក្តី ម្តាយក៏ថ្នាក់ថ្នមតាមមិនដែលឲ្យមានហ្មងដោយហេតុអ្វីមួយឡើយ
អនិច្ចាកូនអើយ អ្នកកើតមកមិនទាន់បានប៉ុន្មានថ្ងៃ ម្តាយឬអាពុក
អ្នកថ្ងៃទៀត ក៏ពុំទាន់បានបញ្ចុកបាយ រាយចំណីផ្ទូតទឹកកូនស្រី តែម្តង
នោះក៏នៅឡើយ កូនអើយម៉្លេះហើយសមកូននឹងទៅជាចំណីអាហារត្រី
គឺជាកម្មពៀរវេរាអ្វី ក៏តាមមកផ្តល់ដល់កាយឲ្យកូនអ្នកឃ្លាតប្រាសចាកទៅ
នាងឆោមឆ្ងៅទួញហើយរីងទួញទំនួញរៀបរាប់សព្វគ្រប់ប្រការ កល្យាណ
ក៏សន្លប់បាត់ស្មារតីហោង ។ កាលគ្រានោះ វិពិភេកផងនោះ លុះឃើញ
នាងមន្ទោទេវីសោកសន្លប់បាត់ស្មារតីហើយ ពុំលង់ឡើយក៏ចូលទៅចាប់
យកធីតាក្មួយស្រីដាក់ទីក្នុងប្រអប់កែវហើយ ក៏ប្រាប់ទៅសេនីយ៍ថា ចូរ
អ្នកយាត្រាយកទៅបោះចោល ក្នុងព្រះគង្គាវារីមហាសាគរធំ ។
គ្រានោះ វិសុភៈសាននសេនានោះ ឱនកាយថ្វាយបង្គំទទួលប្រអប់ពី

ពិកេកអស្សុក ហើយក៏ហោះទៅដោយនូវឫទ្ធិហោង ។

លុះដល់កណ្ដាលមហាសាគរផង ដ៏មានឈ្មោះវឡ្យរនៅទីសមុទ្រនោះ ក៏ហោលហោះទំលាក់ចុះក្នុងវឡ្យរទីសមុទ្រដូចបង្គាប់ពិកេកហោក ។ ក្នុងគ្រានោះ ហេតុតែបុណ្យពជធីតាកុមារីនោះ ចំពោះឲ្យឃើញអស្ចារ្យបង្កើតជាមានដួងបទុមាធំប៉ុនកង់ចក្រ ផុសឡើងទទួលប្រអប់កែវស្សុវ្យ-កាន្តដែលដាក់កុមារី អស្សុពស្សុក:សានសោតក៏មើលទៅមិនឃើញជាផ្កាទ្រសោះឡើយ ហើយក៏ហោះត្រឡប់វិលមកភាពវិញហោង ។

នេះនឹងសម្ដែងពោលពណ៌នា ពីនាងមណីមេខលាទិងអស់ហ្វូងទេពទេពដែលនៅរក្សាមហាសាគរនោះ លុះឃើញកុម្ភណ្ឌស្សុក:សាននាំនាងលក្ស្មីមកបោះបោលក្នុងមហានទីធំដូច្នោះ ទាំងអស់គ្នាក៏ភ័យរំជួលច្រួលច្រក៏ស្ទុះទៅជាប្រញាប់ឆាប់ម្ល៉េះមា ។ លុះបានដល់ហើយទេពក៏ចូលទៅអង្គុយជុំវិញហើយ ក៏ច្រៀងបំពេទះដៃរាយភ្លេងតូរ្យតន្ត្រី គឹកកងរំពងឮលាន់ទេពទេវទនឹងទេពនារីខ្លះ ក៏ច្រៀងសៀងសព្ទសម្ញេងនោះ ពីរោះក្បោះក្បាយកាយទំនុកទំនង ទេពខ្លះក៏បាចសាចផងនូវមាលាដេរជាសពាស-ពេញទាំងផ្ទៃសមុទ្រផលសា ។ ទាំងពួកមច្ឆជាតិ ក៏ហែលដង្ហែនាងទេវីជាបរិវារ ដូចតាការះរាយរៀងពេមលោមលោកខែក្នុងព្រះគង្គារាវតាមនាងទៅ ។ គេជះផលនាងតោមឡៅនោះស្មុទ្ធតែទេពទេវក្សាបាលរក្សាសម្ដេចព្រះលក្ស្មីនោះ លុះអណ្ដែតដល់ទៅនេរញ្ញកនទី ក៏លឿន

អណ្ដែតរហ័សណាស់ ក្នុងមហាសាគរដូចព្រះពាយបក់មកត្រូវក្ដោង សុវណ្ណនាវា អណ្ដែតដោយផលផាកដល់វេបុញ្ញតិរក្ខសា ប្រអប់កែវវតនានោះហាក់ដូចមានវិញ្ញាណដឹង លុះអណ្ដែតមកដល់នៅទីនោះ ក៏ឈប់នឹងនៅទីកំពុងព្រះមហាឥសីនោះហោង ។

ឈប់ស្ងេះទឹងសម្ដែង ថ្ងៃពីព្រះជនកឥសីនោះ ធ្លាប់តែចុះទៅដងទឹកហើយទឹងទៅស្រង់ទឹកក្នុងទីកំពង់មហានទី មិនដែលលស់ថ្ងៃណាឡើយ ហើយលុះដល់ពេលពេលា ក៏មានវាចាស្រែកហៅទៅសិស្សឈ្មោះនាយសោម ឲ្យកាន់សំពត់ងូតហើយ ក៏នាំគ្នាលីលាទៅកាន់កំពង់ទឹកនទី លុះមកទល់កំពង់វារីហើយ អង្គព្រះអាចារ្យនេត្រាក៏ក្រឡេកមើលទៅឃើញប្រអប់កែវសុវណ្ណល្អដូចដួងតារា ដ៏ប្រាសចាកពពកនៅជាកណ្ដាលដួងបទុមមាស មានពន្លឺភ្លឺផ្លេកប្រះផ្ទះចាប់រស្មីផ្ទះលេចទៅក្នុងទឹកនព្វព្រះមហាសាគរេត ព្រះមុនីទ្រង់គេទនោះ ក៏ស្ទុះលោលោតចុះទៅក្នុងទឹកជាប្រញាប់ឆាប់ ៗ ឧបមាបីដូចជាក្រុងគ្រុឌហើរលើមេឃា ព្រះមុនីសិទ្ធាក៏ចាប់បានប្រអប់សុវណ្ណហើយ ក៏ទ្រលើកស្ពាយឡើងទឹងព្រះហត្ថា ព្រះអាចារ្យក៏ហែលវិលត្រឡប់មកវិញដល់មាត់ច្រាំងមហានទី លុះដល់ហើយព្រះមុនីក៏បើកប្រអប់មើលទៅឃើញជារូបកុមារីមានរូបឆោមលោមពណ៌ល្អល្អះ គ្រប់គ្រងដូចដួងព្រះច័ន្ទពេញបូណ៌មី ហើយមហាឥសីក៏មានព្រះទ័យនោះត្រេកអរសោមនស្សក្រៃឧបមេយ្យដូចបានកែវមណីចក្រពត្តិ រូបកុមារីនេះមិនមែនជាជាតិ

ពង្សវង្សត្រកូលតាបទោកថយទេ ឬមួយជាពូជពង្សវង្សក្សត្រណា ៗ ប្រហែលជាមានហេតុវិបរិតកើតកលិកាលបណ្ដាលក្នុងបុរីពជជាទីស្ថាន ទើបបានដាក់ទីងប្រអប់កែវសុវណ្ណ យកមកបណ្ដែតទោលបង់មុខគួរឲ្យអាណិតណាស់ ហើយរីរូបអញនេះសោត ក៏គ្មានពជជីតាបុត្រាបុត្រីទីងគេមួយសោះឡើយ ហើយហេតុតែបុញ្ញាពសីអញបានមកកពប្រសព្វប្រទះក្នុងថ្ងៃនេះ អញនឹងចិញ្ចឹមពជជីតានេះធ្វើជាកូនធម៌នឹងបានតពង្សវង្សាសោយពជសម្បត្តិតទៅ ៗ គិតហើយព្រះបមបៅក៏មានវាចាតាំងសច្ចាថាទុតេជតេជះព្រះកុសលរាស្នាសំណាងនាងយៅវិមានពជកុមារនេះ នឹងបានជាទឹមសារតទៅមុខមែនប្រាកដពិត សូមឲ្យម្រាមបន្ទុលដៃមានបុទ្ទិមងើតជាធាពប្រយោធរះហោង ៗ លុះព្រះមុនីផ្សងសច្ចារួចមួយរំពេចក៏បង្កើតជាទឹកដោះនោះហូរស្រក់ចេញពីម្រាមដៃឥសីហោង ៗ រីព្រះឥសីសោតក៏មានសេចក្ដីត្រេកអរណាស់ ក៏យកម្រាមបន្ទុលនោះដាក់ទៅក្នុងមាត់នាងកុមារី កុមារីនោះក៏ជញ្ជប់ជញ្ជក់បឺតថនធារា ហើយឥសីក៏ហុចឲ្យទៅនាយសោម កូនសិស្សលីប្រអប់សុវណ្ណដើរជាមុខមហាឥសីទៅកាន់ទីដំណាក់អាស្រមព្រៃ ៗ លុះដល់ហើយនែឥសីក៏ឲ្យបង្អង្រឹងខាងមាត់ទ្វារជាទិសខាងត្បូង ហើយក៏ដាក់នាងទៅក្នុងអង្រឹងហើយក៏យោលទៅយោលមកញយ ៗ ហើយក៏ប្រើឲ្យនាយសោមបំពេរប្រៀងយោលពជធីតា ៗ កាលណោះ រីនាយសោមជាសិស្សនោះ ត្រូវជាគីលៀង

ច្រៀងយោលបំពេព្រះរាជបុត្រី  ក៏មានសេចក្ដីស្រឡាញ់រាជធីតានោះពេក ពន់នឹងរកគណនាពុំបានឡើយ  ហើយក៏ឧស្សាហ៍ផ្ដុតទឹកបញ្ចុកបាយរាយ បំណាំមិនឲ្យមានក្ដីលំបាកឡើយ  ហើយលុះដល់ពេលវេលារាជកុមារី ដេកក៏ផ្ដេកដាក់ទៅក្នុងអង្រឹងយោលទៅយោលមក  ហើយក៏ច្រៀងបំពេ ក្នុងទីអាស្រមសាលា ៗ  កាលណោះ  ព្រះមហាឥសីនោះខំសាង សីលសិក្ខាបទកំណត់តាំងតែពីបាននាងមកចិញ្ចឹមធ្វើជាកូនធម៌  ថែទាំ គ្រប់ទិវារាត្រីជាវរវល់ខ្វល់ខ្វាយពិបាកណាស់  ទើបព្រះអាចារ្យមកគិតរំពឹង ថា  ឯខ្លួនអញនេះពីដើមជាក្សត្រ  លះសម្បត្តិមកបួសសាងជាឥសីដើម្បី ចិត្តប្រាថ្នាចង់បានឈានលោកិយ  ឥឡូវអញក៏នៅមិនទាន់បានសម្រេច ដូចក្ដីប្រាថ្នានោះក៏នៅឡើយ  ហើយអញនឹងលះគេចវិលទៅនគរវិញក៏ ពេញស្ដាយការពិធីកិច្ចណាស់  នឹងព្យាយាមនៅក្នុងភេទបព្វជិត  ក៏ជាប់ ធុរៈរវល់ខ្វល់នឹងរាជធីតា  ណ្ហើយចុះមានតែអញនេះនឹងយកទៅកប់ទុក ផ្ញើហ្លួងទេពទៃរុក្ខទេវ៉ានៅដោយជាន់ព្រៃព្រឹក្សាវិញ  ទើបអញនឹងបាន បំពេញឈានភាវនារក្សាសីលចម្រើនកិច្ចពិធីមាំមួន  គិតហើយទើបព្រះមុនី សិទ្ធិសាយស្រែកហៅទៅនាយសោមសិស្ស  ដែលចិញ្ចឹមនាងកុមារីនោះ ឲ្យយកនាងធីតានោះទៅដាក់ក្នុងប្រអប់កែវវិញ  ហើយក៏ឲ្យនាយសោម លីទៅ  ព្រះមហាមុនីឥសីក៏ខ្វីចាប់ចបកាន់ដើរទៅ  លុះដើរមកបានដល់ ជាយព្រៃរលោងមានភ្លចន្លោះរបោះដើមព្រេចព្រៃ  ហើយមានដើមព្រះ

ជ្រៃធំ ១ ហើយក៏ដាក់ប្រអប់សុវណ្ណនៅក្រោមម្លប់ជ្រៃ ក្នុងទីដើមជ្រៃនោះមានរុក្ខទេវា មានឫទ្ធាអានុភាពពូកែខ្លាំង ហើយព្រះមុនីក៏តាំងសច្ចាអធិដ្ឋានថា សូមផ្ញើព្រះកេដធីតាផង សុំឲ្យអ្នកគ្រប់គ្រងជួយអភិបាលរក្សានាំយៅមាន ឲ្យបានគង់សុខសប្បាយ សច្ចាស្រេចហើយទើបបង្គាប់ប្រាប់ប្រើទៅនាយសោមថា ចូរជីករណ្ដៅក្រោមដើមជ្រៃសាខាម្លប់គ្រជាក់ ហើយឥសីក៏ឲ្យជីកដីភក់ ៤ ជ្រុងទាំងជំរៅក៏ឲ្យស្មើគ្នាហោង ។ ទើបនាយសោមសិស្សនោះ ក៏ទទួលយកចបពីឥសីហើយ ក៏ជំរះស្មៅស្រេចតាំងជីកដីទៅជា ៤ ជ្រុងជំរៅ ៤ ហត្ថ បណ្ដោយទទឹងទទឹងស្មើគ្នាហើយក៏ជំរះមិនឲ្យមានឈើព្រៃ ឲ្យរាបទាបស្មើល្អ ហើយនាយសោមនោះចំពោះបែកញើសហោមហត់ហប ៗ ខំធ្វើទាល់តែស្រេចរួចតាមកំ-ណត់ព្រះឥសីស្ដីបង្គាប់នោះហោង ។ កាលណោះ ព្រះឥសីជនកនោះ លុះឃើញនាយសោមជីករណ្ដៅបានស្រេចហើយ ពុលង់ឡើយក៏តាំងសច្ចាវាចាថា បើនាងនេះនឹងបានសោយស្វេតឆត្រ ប្រតិបត្តិរួមរស់នឹងអង្គព្រះហរិរក្សចក្រពង្សកំពូលពិនគ្រិនលោកាធានី អាណាប្រ-ជាជនជីនឹងបានជាទីពឹងពំនាក់សុខក្សេមក្សាន្ត ចូរបណ្ដាលឲ្យមានដួងចិត្តបុប្ផាមាសជំនុកាសដោយក្លិនកេសរខ្ចរខ្ចាយ ផុសឡើងមកពីក្នុងដីទទួលប្រអប់សុវណ្ណ ដោយបុញ្ញាសភាព្ភារមីកន្លងគ្រានេះហោង ។ ហេតុតែតេជៈឥសីសច្ចាផ្សេងផង ហើយបុណ្យនាងលក្ស្មីឆើតឆោមឆាយ

ក៏បង្កើតជាផ្កាឈូកមាស ក្រអូបសាយផុសឡើងមក នៅកណ្ដាលរណ្ដៅ
មួយរំពេចដូចចិត្ត ក៏រីករាយសាយសុសដ៏មានក្លិននោះក្រអូបខ្ចរខ្ចាយ ទើប
ព្រះតាបសក៏ចាប់យកប្រអប់កែវសុវណ្ណដាក់ទៅក្នុងរណ្ដៅ ហើយឲ្យនាយ
សោមសិស្ស លុបដីកប់ទៅឲ្យរាបស្មើល្អហោង ។ គ្រានោះនាយ
សោមក៏ចាប់ចបលុបឲ្យស្មើរាបល្អដូចពាក្យព្រះឥសី ។ កាលណោះ ព្រះ
តាបសនោះ លុះកប់ស្រេចហើយ ក៏នាំគ្នាវិលមកអាស្រមដំណាក់ព្រៃ
វិញហោង ។ គ្រានោះ រីអស់ហ្វូងទេពទេវរុក្ខតូចធំ ដែលស្ថិតនៅ
ក្នុងដើមព្រះជ្រៃ ហើយអស់ពួកទេពជ័យនៅនៃកំឡុងនាវនោះ លុះ
បាន ស្ដាប់ពាក្យព្រះមុនីអាចារ្យអធិដ្ឋានកប់អង្គព្រះលក្ស្មី ក៏មានសេចក្ដី
ប្រណីមេត្តាអាណិតនាន់ណាស់ រុក្ខទេវខ្លះក៏ប្រជុំគ្នាវទីប្រាប់គ្នាជាកោ-
លាហលអឺងកងទៅវិញទៅមក ហើយពួកទេវលោកខ្លះក៏ទៅនាំអស់ហ្វូង
ទេពនារីទូវអស់ហ្វូងទេវីទាំងឡាយ ក៏ចេញចាកពីវិមានរតនសុវណ្ណមក
កាន់ទីរណ្ដៅដែលកប់នាងលក្ស្មី ។ លុះមកដល់ហើយទ្រី ក៏អង្គុយ
ជុំជិតថែទាំចាំរក្សា ប្រៀងបំពេកជជីតាមោះ សម្ដែងពីរោះក្បោះក្បាយ
ផ្អែមល្ហែមក្រៃពេក សែនរីរេកក្រោមដើមព្រះជ្រៃ មិនឲ្យមានភេទភ័យ
អ្វីមួយឡើយហោង ។ កាលណោះ ឯងសម្ដេចទីព្រះបាទទេវរដ្ឋ
ធិបតីចក្រក៏មានក្ដីស្នេហានឹងរាជឱរសទាំង ៤ អង្គនោះណាស់ដូចដួងជីវិត
ទ្រង់ឫទ្ធិក៏ប្រឡែងលេងគ្រប់ទិនទិវារាត្រី មិនឲ្យមានក្ដីរោគាព្យាធិឡើយ

ហើយព្រះរាជនុរសទាំងអស់នោះ លុះចម្រើនធំឡើងព្រះជន្មវស្សាបាន ១២ ឆ្នាំ កាលណា ក្សត្រក៏គិតនឹងឲ្យរាជកុមារនោះទៅរៀនសិល្បសាស្ត្រ សរជ័យ នឹងបានបង្ក្រាបពួកពៃរីក្នុងជាទីត្រៃលោក ឲ្យបានសុខស្ថាពរ ទើបព្រះរាជទានធ្នូឲ្យហាត់បាញ់លេងទាំង ៤ អង្គ ឲ្យបានត្រង់ដូចក្តីប្រាថ្នា រួចហើយសុំចិត្តានឹងឲ្យអ្នកទៅរៀនសិល្បហោង ។ កាលណោះ រាជនុរស ទាំង ៤ អង្គផង ក៏ក្រាបបង្គំទទួលយកធ្នូត្រេកអរ ហើយក៏ថ្វាយវន្ទាលា ចេញចាកពីព្រះរាជរោងជ័យ ក៏យាត្រាពៃទៅដល់មណ្ឌលទីមុខព្រះលាន ទាំង ៤ ប្រាណស្រេច ហើយស្តេចក៏ទ្រង់បាញ់ហាត់ដៃលេងជាកំសាន្ត សប្បាយចិត្ត ហើយក៏បាញ់ក្នាល់គ្នាជាកន់នេកចំណី បើអ្នកណាមាន ថ្វីដៃបាញ់ត្រង់ជាង ហើយក៏ទ្រង់និយាយលេងឡកចំអកចំអន់សប្បាយ សើចលេងនឹងគ្នាជាប្រក្រតី ។ ដូនជាគ្រានោះ មានស្រីបំរើនាងកែកេសី នោះឈ្មោះនាងខុជ្ជគម ១ សម្រាប់តែងតែទៅបេះផ្កាជាប្រក្រតី លុះដល់ វេលាហើយខ្មី នាងគមនោះក៏តែងខ្លួនប្រាណសិតសក់លាបម្សៅមុខមាត់ ធ្វើបុក បរិតកិរិយា ស្រេចហើយក៏ដើរកែក្រាយញៀងញៀងញ៉ាំញើដើរទៅ សួនមាលី ។ លុះមកដល់ទីមុខព្រះលានកាលណា ក៏ឃើញរាជកុមារ ទាំង ៤ អង្គទ្រង់បាញ់ធ្នូលេងក្នាល់គ្នា អែសមនុស្សម្នាដែលមើលនោះដេរ ដាសពាសពេញនៅឈរមើលគួចក្តាំងទាំងវិញ្ញាណស្មារតី ឯនាងខុជ្ជ នោះនឹងហួសទៅសួនមាលីក៏ទេ ឈប់មើលលេងនឹងគេជាទីសប្បាយ

កំសាន្តសំរាន្តចិត្ត ហើយក៏អង្គុយៈធ្វើជាញញឹមញញែមព្រងើយ ៗ កាលណោះ រីអង្គរាជកុមារគឺព្រះរាមធិបតីក៏ស្តេចលេងកំសាន្តនៅទីមុខព្រះលានអញ្ជ្យបន្ទំ អង្គព្រះសោភ័ណក៏ទ្រង់បាញ់ធ្នូលេងនៅទីនោះ ស្តេចក៏ទស្សនាទតទៅឃើញនាងគមនោះ ស្លៀកសំពត់ពណ៌តាណី ដណ្តប់ផាហ៊ុំថ្មីពណ៌ទទឹមក្រហមដូចស៊ុមាន់ ហើយក៏សំខាន់ធ្វើឫកពា មុខមាត់ ដើងដៃ នោះល្អូតល្អន់ដូច្នោះ បំពោះស្តេចត្រាស់ទៅនឹងព្រះអនុជទាំងបីថា ម្នាលអនុជប្អូនទាំងបីប្រាណអ្នកចាំមើលចុះ ចាំហើយព្រះទ្រង់យសក៏បាញ់ទៅ១រំពេច ហេតុតែតេជះអានុភាពអង្គព្រះនារាយណ៍ក៏បាញ់ត្រូវដូចបំណងប៉ងមិនខុស លុះត្រូវគម ពីខ្នងនោះបំពោះត្រឡប់ទៅគមពីខាងមុខវិញ ដុះត្រង់ដើមទ្រូង រួចហើយព្រះអង្គក៏ទ្រង់បាញ់ថែមទៅទៀត រីគមនោះក៏ត្រឡប់មកដុះឯខ្នងវិញដូចដើម រីនាងគមនោះក៏ពុំដឹងខ្លួនសោះ ព្រោះដ្បិតព្រះអង្គទ្រង់បាញ់នោះ ត្រង់ក៏ត្រង់រហ័សក៏រហ័សណាស់ តែបាញ់តម្រង់ត្រង់ណាហើយក៏ត្រូវត្រង់ណោះគ្រប់ៗគ្រាមិនដែលខុស ក្នុងគ្រានោះទាំងបងទាំងប្អូនក៏ទះដៃសើចលេងសប្បាយនឹងគ្នា រីពួកមហាតលិកក្មេងទាំងអស់នោះខ្លះក៏សើចលេងឡកចំអកផ្តោះផ្តងនឹងគ្នា ជាហេហា ៗ ឡារកឹកកងរំពងហោង ៗ គ្រានោះ រីនាងខុជ្ជីទាសីក៏បានសេចក្តីខ្មាសអៀនអន់ទឹងគណនាពុំបានឡើយ ហើយក៏ស្រែកទឹកភ្នែកយកដៃជូតទឹកភ្នែកហើយស្រែកយំថា បើទុកជារូបាអញគមគាក់ខ្ទាក់ខ្ទើយដូចម្តេចក៏មិនគួរគប្បីធ្វើ

បាបអញដល់ម្ល៉េះ ខ្លួនអញនេះ ក៏ទៅជាខ្ញុំបំរើនាងកៃកេសីជាមនុស្ស ចាស់ទឹងគៃជរ ៗ មិនគួរទេ ព្រះកាមលោភមកធ្វើដូច្នេះ អើជាបើអញនេះស្លាប់ទៅក៏ហើយទៅ បើជីវិតអញនៅរស់ទេ គង់តែទឹងឃើញគ្នា នាងគិតហើយក៏វែងក្តៅក្តួលណែនកន្ទុំដើមទ្រូងដួងចិត្តថ្មើម ដកដង្ហើមធំ ហើយក៏ហៀរហូរទឹកភ្នែកស្រក់ធ្លាក់ចុះមកលើកាយា ញ័រជើងដៃដោយសេចក្តីក្តៅណាស់ ហើយក៏ក្រោករលាស់ខ្លួនដើរចាកចេញទៅពីទីនោះ ចំពោះដើរកៃងគោងកិកះទៅ ៗ កាលណោះ វិកុមារទាំង ៤ អង្គទ្រង់ហាត់បាញ់ធ្នូលេងមកៈនោះជានិច្ចនិរន្តរ៍ ហើយក៏ហាត់ដៃហាត់ភ្នែកឲ្យបានចំណានចំណាប់ជំនាញជាញជ័យ ហើយឧស្សាហ៍រៀនតម្រាសៃយក្បួនពិជ័យសង្គ្រាមតាមជំរេះ រៀនជិះសេះបំបោលបត់គេចបែរដោយកលកិច្ច-ការ ហើយរៀនជិះគជសាររលេងកំសាន្ត ឲ្យបានស្ទាត់វៃវក្លូនមែនទែនមាំមួន ៗ លុះព្រះរាជកុមារទាំង ៤ នោះ ចម្រើនធំវឡ្យនាការ ព្រះជន្ម-វស្សាបាន ១៤ ឆ្នាំ ៗ វីកិច្ចរាជការអ្វីទាំងពួង ក្រសួងក្នាក់ងាររាជកុមារក៏ជំនួសតាងព្រះនេត្រតាងព្រះអង្គព្រះបិតា ហើយរាជកុមារនោះ ចំពោះតែដល់មោ៉ងពេលកាលណា ក៏នាំគ្នាលីលាឡើយគាល់សម្តេចព្រះបិតុរេត ៗ កាលណោះ ព្រះចមមកុដកេតុទតរដ្ឋធិបតីចក្រឃើញ ៤ ព្រះរាជកុមារមកគាល់ហើយ ព្រះអង្គទ្រង់ស្នេហាបំយោរសទើបព្រះទសពលក៏មានព្រះឧត្តារថា ម្នាលបុត្រាសំឡាញ់អាពុកអើយ កូន

ហើយ អ្នកនឹងបានជាកំពូលពិនត្រៃលោកា នឹងបានតពង្សវង្សទៅមុខ ឥឡូវនេះឪពុកចង់ឲ្យអ្នកទៅរៀនសិល្បសាស្ត្រមន្តវិជ្ជា នឹងអង្គព្រះមហាឥសីសៃយរៀនត្រៃភេទត្រៃភូមិត្រៃយុគត្រៃកា តាមព្រះវេណីពីបូរាបូរាណរាជមហាក្សត្រ ៗ កាលណោះ ទាំង ៤ ព្រះរាជឱរសាបានស្តាប់ព្រះបិតុរេតហើយ ក៏ក្រាបក្រោមព្រះបាទហើយទូលថា ដែលទ្រង់ព្រះករុណាការុណ្យព្រះគុណធ្ងន់ជាទីបំផុត ឯចិត្តបុត្រសោតក៏ប៉ងបំណងនឹកចង់ឲ្យមានឫទ្ធាអានុភាពប្រាស់ តែថាព្រះមាតាបិតាមិនទាន់មានព្រះឧង្ការ ហើយកូនក៏នឹងទៅពុំគួរឡើយ ទូលហើយក៏ក្រាបថ្វាយបង្គំលាវរជយចេញមក ហើយក៏នាំគ្នាទៅក្រាបថ្វាយបង្គំលាព្រះមាតាទាំងពីរព្រះអង្គស្រេចហើយ ពុំលង់ឡើយព្រះរាជកុមារទាំង ៤ អង្គ ទ្រង់យានចាកចេញពីនិវេសន៍វាំងហោង ៗ លុះកុមារយានរំលងនាទីបន្តិចទៅ ស្តេចក៏ទតមើលអស់រុក្ខជាតិផលាផល ដោយមាគ៌ានុមគ្គជាកំសាន្តសប្បាយព្រះទ័យហើយស្តេចទតមើលអស់សត្វព្រៃបក្សាបក្សីម្រឹគម្រឹគារៀង ៗ មកដោយផងមាគ៌ា លុះបានដល់នាអាស្រមបរមសាលាកុដិ ក៏ខ្ញុំនាំគ្នាយាត្រាចូលទៅនមស្សការ ក្រាបបង្គំព្រះមុនីឥសី ៗ កាលណោះ ព្រះមហាឥសីនោះ លុះក្រឡេកឃើញព្រះរាជកុមារបុត្រព្រះបាទទសរដ្ឋមកដល់ដូច្នោះហើយ អង្គព្រះត្រាណត្រ័យឥសីក៏មានពុទ្ធដីកាសួរទៅថា ដូចម្តេចចៅតាមកតែ ៤ អង្គ គ្មានពួកពលចតុរង្គសោះឡើយ ចៅអើយឬមានកើតហេតុភេទការប្រការអ្វី ជីតានៅសង្ស័យណាស់ ៗ (នៅមានត)

# អធិប្បាយភាសិត

សាស្ត្រាចារ្យ ឈឹម-ស៊ុម តែងជាកាព្យ

( ពាក្យ ៧ តពីលេខ ១៣ )

តមកសម្ដេចព្រះចមពង្ស　　ស្ដេចទ្រង់ទទួលតែគឿនគ្រើន
សូមឲ្យស្រុកខ្មែរបានចម្រើន　　បានកើនកិត្តិនាមជាឯកភព　　ៗ
ប៉ុន្តែបានត្រឹមតែស្វ័យភាព　　បាត់ដំបងសៀមរាបមានអំណាច
យើងមានអំណាចអរប្រសាច　　តែឯកភពពុំទាន់ពេញ　　ៗ
ព្រះអង្គស្ដាប់សួរទ្រង់កស្ទៀត　　សឹកហើយសឹកទៀតតែងទន្ទេញ
សុំឲ្យឯកភពបានពេញលេញ　　ទ្រង់ចេញប្រកាសគ្រប់ប្រទេស　　ៗ
ទៅស្រុកអាមេរិកស្រុកជប៉ុន　　ប្រកាសថ្លៃគុណបាក់ងសេស
ដែលឲ្យឯកភពដល់ប្រទេស　　តែធ្វេសពុំឲ្យពេញបរិបូណ៌　　ៗ
ព្រះសូរសៀងទ្រង់ឮពេញទ្វីប　　ភ្លឺដូចប្រទីបអ្នកផងជួរ
ជួយស្រែកជួយថាដូចទឹកហូរ　　បាក់ងក៏ជួរដង្ហើមធំ
អង្គការសហប្រជាជាតិ　　ផ្ដើមហាសន្និបាតជំនុំ
នៅក្រុងញ៉ូវ៉ៃណាដាក្រុងធំ　　បុរីបរមនៃរដ្ឋស្វីស　　ៗ
សម្ដេចទ្រង់ចែងថ្លែងយោបល់　　ដែលទ្រង់ឈ្វេងយល់តាមតម្រិះ
ជម្រាបអង្គការនៅស្រុកស្វីស　　ទើបអង្គការនេះសម្រេចថា　　ៗ
ប្រទេសខ្មែរយួនលាវទាំងបី　　ត្រូវមានសេរីជាអ្នកជា
ឯកភពបរិបូណ៌តាមចិន្ដា　　ឥតគេត្រួតត្រាដូចពីមុន　　ៗ

រឿងនេះគួរតែលាវនិងយួន　កុំបំភ្លេចក្បួនគួរដឹងគុណ
សម្ដេចឪយើងដែលមានបុណ្យ　ដោះខ្លួនពីកុនឡុងថ្កើងថ្កាន ។
នេះហៅថាប្រាជ្ញផ្ដើមផែនដី　បេះដល់ចាប់ត្រីទាល់តែបាន
ទឹកកម្មិនល្អក់កើតទុស្ថាន　ចាប់បានជំនួយបារាំងទៀត ។
គួរបើដៃរប្ដូរស្រុកទាំងរដ្ឋ　ដូចនៅក្នុងមាត់ខ្លាចង្អៀត
ធ្វើឲ្យចង្អោរអស់បង់ម្បៀត　ខ្លាឆ្កៀតឲ្យទាំងអំពាវផង ។
គឺថាសម្ដេចឪយើងនេះ　ទ្រង់បេះដោះខ្មែរពីចំណង
ជាប់យ៉ាងចំណាប់បារាំងចង　ដោយគេប៉ុនប៉ងទុកហុតឈាម ។
ទ្រង់ចេញស្រួលដោយប្រាជ្ញា　បារាំងដូចខ្លាព្រមលែងភ្លាម
ឥតមានទាក់ទិននៅទីមទាម　គម្រាមរករឿងតទៅទៀត ។
ថែមថ្វាយជំនួយដ៏ច្រើនផង　កំពង់បម្សង់នៅគ្រលៀត
ឈូងកំពង់សោមដែលចង្អៀត　បារាំងខំឆ្កៀតថ្វាយយន្តហោះ ។
ធ្វើទាំងគ្រឹះស្ថានពីមានមេឃ　ជំល្អក្រៃពេកឥតមានខ្ចោះ
ធ្វើទាំងកន្លែងចុះយន្តហោះ　ថ្វាយមកបំពោះព្រះភូធរ ។
នេះហៅចាប់ត្រីបានទាំងស្រះ　ទឹកថ្លាត្របះគ្មានកករ
ព្រមទាំងប្រើសក្ដានកិសញ្ចរ　រត់តាមឈូងរកំដរត្រី ។
ខ្ញុំសូមសង្ខេបត្រឹមប៉ុណ្ណោះ　ឈប់ស្ទះក្រែងវែងឆ្ងាយសេចក្ដី

គឺរឿងអួសទូកទឹងចាប់ត្រី     សង្ខេបយ៉ាងខ្ញុំចប់ប៉ុណ្ណេះ ។៚—

## ដំបូន្មានដល់យុវជន

– អួសទូកឡើងទួល ច្រើនតែពុំស្រួល ព្រោះតែងតែមាន
ឧបស័គ្គកំផែក ឲ្យទុស្ដាន ខំអួសបំពាន បែកធ្លាយអសារ ។
អួសតាមលំអាន តម្រាយបុរាណ ទើបបានកើតការ កាក់កបតបះ
តេជះសម្ភារ ជាទ:យសង្ហារ កេរ្តិ៍ឈ្មោះស្រស់ឆើត ។

– ការគ្រប់ជំពូក បំណាច់ហានលូក ចាប់កាន់ឲ្យកើត កុំបើក-
កុំជោរ ផ្ដោៗសស្ងើត ឃើញគេធ្វើកើត ថាខ្លួនកើតដែរ ។

— ការគេកើតស្រាប់ កុំធ្វើសាប់ឡាប់ បំបត់បំបែរ បង្វែង-
ផានដើម អាងធ្មេញគ្រាន់ដែរ ប្រយ័ត្នកូនខ្មែរ ប្រែទៅជាខោច ។

— តម្រាយម៉ែឪ គន្លងណាត្រូវ កុំប្រឹងបោះពេប ត្រូវព្រួត-
បន្ថែម កុំឲ្យហិនហោច ធ្វើដូចស្រមោច គ្រាន់បើជាងរ៉ៃ ។

— ដើរកុំលុបផ្លូវ ទោះបីខុសត្រូវ កុំអាងជ្រកព្រៃ នៅស្រុក-
មានគ្នា ប្រឹក្សាសព្វថ្ងៃ លុបផ្លូវចូលព្រៃ ទឹងទៅជាប្រើស ។
ព្រើលអួតថាប្រាជ្ញ ប្រឹងអាងអំណាច និយាយបំផ្លើស តែងតែមាន-
ភ្នាត់ ធ្លាក់ខ្លួនជាប្រើស ព្រោះតែក្ដីល្មើស រកស៊ីលុបផ្លូវ ។

- ចាប់ត្រីផ្ទាល់ដៃ គង់តែមានថ្ងៃ ណាមួយអាស្រូវ បើចង់-

ចាប់ត្រី គេត្រូវធ្វើផ្លូវ ធ្វើស៊ងគម្រូវ ឲ្យត្រីវាចូល ។

ចប់

អួសទូកកុំឲ្យល្អាន ចាប់ឲ្យត្រីបានកុំឲ្យល្អក់ទឹក
តែប៉ុណ្ណោះ

## ៤- គ្នាច្រើនអន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ

បទពាក្យ ៧

ពាក្យថាគ្នាច្រើនអន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ
ប្រាជ្ញព្រឹទ្ធប្រឌិតទុកប្រដៅ ដល់កូនដល់ចៅនៅឯក្រោយ ។
ខ្ញុំសូមអធិប្បាយស្រាយសេចក្តី ប្រយោជន៍ដើម្បីកុំឲ្យធ្លោយ
កុំឲ្យថ្វស់ការទៅខាងក្រោយ កុំឲ្យដូចពាក្យខាងដើមនេះ ។
ការនេះធ្លាប់មានពីព្រេងនាយ ជាហេតុអន្តរាយទើបអ្នកបេះ
ពោលពាក្យផ្ដេញផ្ដាល់ជូនយ៉ាងនេះ ដើម្បីឲ្យបេះបាំតទៅ ។
ពាក្យនេះមានន័យជាពីរយ៉ាង គឺម្ខាងមានន័យត្រង់ស្លុងស្លៅ
ម្ខាងទៀតប្រដូចទុកប្រដៅ ប្រែទៅថាគ្រប់ទាំងករណីយ៍ ។
តូចធំទាំងឡាយទាំងតិចច្រើន ដែលត្រូវក្រើនទាំងប្រុសស្រី
ត្រូវប្រឹងរឹងប្រឹតរឹតឃ្មាតខ្មី ប្រុសស្រីប្រស្រ័យគ្នាច្រើនធ្វើ ។
ន័យត្រង់ត្រង់ពាក្យថាអន្សម នំបត់នំគមដែលត្រូវធ្វើ
ត្រូវស្ងោររម្ងាស់តាមអំពើ ត្រូវធ្វើឲ្យឆ្អិនដោយកំដៅ ។

អគ្គីកន្ទុកក្នក់បង្ក្រាន ឲ្យបានឆ្អិនល្អបរិភោគទៅ
បើប្រេងណាស់តែខានក្រែងនៅ ឥតគិតដល់ទៅខាងខ្មោចសោះ ៗ
ប្រឹងរកប្រឹងគរអុសទាំងគល់ ផ្ដល់ហើយថែមផ្ដល់ឥតបន្ទោះ
មានម្នាក់រកអុសពីខាងនុះ ម្នាក់ទៀតសៀតបុះពីខាងនេះ ៗ
មិនព្រមទាញពេចបោចបង្គោយ ប្រឹងថែមញយៗឲ្យតែឆេះ
ទាល់តែអន្សមទៅជាផេះ ខ្មោចអស់យ៉ាងនេះទៅជាខូច ៗ
ការខូចនាំឲ្យមានការខាត ព្រោះឥតមារយាទតាំងពីតូច
ចិត្តរឹងម្នោម្នះមិនខ្លាចខូច ទទូចតែធ្វើមិនស្ដាប់គ្នា ៗ
មួយទៀតគ្នាច្រើនស្ងោរអន្សម ទំបត់ទំគមតាមវេលា
អាងតែគ្នាច្រើនប្រចាំគ្នា ម្នាក់ថាអានេះគេឥតខំ ៗ
ម្នាក់ថាអាញធ្វើឥតទំនេរ មើលបុះហ្នះគេៗសម្ងំ
ឯងធ្វើឥតឈប់គេឥតខំ អញគេចសម្ងំនឹងគេដែរ ៗ
យ៉ាងនេះអន្សមទំគមនៅ ស្ងោរច្រើនដងទៅឥតផ្លូវកែ
ដូចជាដំឡូងប្ដូគ្រាវដែរ ចាស់ខ្មែរហៅថាខ្ទាវខាំ ៗ
គឺថាដំឡូងប្ដូមួយគ្រាវ ស្ងោរម្ដងឲ្យនៅខុសចំណាំ
ស្ងោរម្ដងទៀតទៅខ្ទាវខាំ ពោលតាមចំណាំអៅលែងឆ្អិន ៗ
អន្សមទំគមក៏ដូចគ្នា មនុស្សច្រើនយ៉ាងណាតែមិនប៉ុន

មិនប្រឹងស្វែងរៀនទាល់តែឆ្អិន　　តែក្រិនទៅម្តងឥតបានការ ៗ
ដូច្នេះឃើញថាខ្ចោចប្តូរនៅ　　យើងបរិភោគទៅពុំពីសារ
បាត់ជាបំណាំខូចឥតការ　　អសារមកពីគ្នាច្រើនធ្វើ ៗ
ពុំព្រមស្តាប់អ្នកបញ្ជាការ　　ទើបខ្ចោចអសារឥតអំពើ
មួយទៀតអាងតែគ្នាច្រើនធ្វើ　　ពុំសូវអើពើទាល់តែនៅ ៗ
មួយទាស់ពីពុំព្រមស្តាប់គ្នា　　មួយទាស់មាយាពុតគេចវេ
ហេតុនេះអន្សមខ្ចោចប្តូរនៅ　　កំហុសខុសនៅលើគ្នាច្រើន ៗ
ន័យមួយទៀតជាពាក្យឧបមា　　អន្សមទុកជាការចម្រើន
យើងធ្វើការងាររៀងបានច្រើន　　ទើបបានចម្រើនដល់អាត្មា ៗ
ដល់ប្រទេសជាតិទាំងសាកល　　ចម្រើនមានដល់ព្រះសាស្នា
ចម្រើនរហូតដល់ក្សត្រា　　គ្រប់គ្រងភារៈដ៏ធ្ងន់ធ្ងរ ៗ
ការងារទាំងនោះទោះតូចធំ　　ដែលយើងខិតខំទាំងប៉ុន្មាន
បើមានគ្នាច្រើនជួយជ្រោងប្រាន　　ការក្រប៉ុន្មានបានជាងាយ ៗ
ប៉ុន្តែទាល់តែជនច្រើនគ្នា　　ស្តាប់បទបញ្ជាចៅហ្វាយនាយ
ទើបបានការក្រទៅជាងាយ　　ចម្រើនសប្បាយទាំងអស់គ្នា ៗ
ប្រសិនបើមានការរើងរូស　　ប្រទូស្តមិនតាមបទបញ្ជា
ប្រឆាំងអហង្ការគ្រប់គ្នា　　ការងាររើងនេះខ្ចោចអន្តរាយ ៗ

មួយទៀតក្នុងពួកក្រុមអ្នកធ្វើ　បើមិនអើពើធ្វើពាយផាយ
គ្រលីសគ្រលសច្រើនពាយមាយ　ការងារទាំងឡាយនៅសល់ទៅ ៗ
ការងារនៃជនពីរប្រភេទ　ដូចថ្លែងតាមហេតុមានសំណៅ
គឺការមួយនេះការមួយនៅ　ខូចខាតអស់ទៅទាំងពីរយ៉ាង ៗ
សរុបសេចក្ដីថាព្រោះគ្មាន　សាមគ្គីជាយានជាសំអាង
ជនច្រើនច្រើនធ្វើបុកអាងខ្លាំង　ច្រើនអាងចំណេះបេះកល់ខ្លួន ៗ
ប្រកាន់ឥស្សិមានៈរឹង　សំដីទទឹងឥតស្របជួន
បែកពួកបែកក្រុមគ្នាបីបួន　រុកកួនរករឿងតែគ្នាឯង ៗ
ដូច្នេះទឹងនេះពេញជាភ្លើង　ពេលពលជាលឡើងគ្រប់កន្លែង
នេះទ្រព្យរបស់ផ្ទះសម្បែង　សម្បត្តិគេឯងខូចអសារ ៗ
នេះហៅគ្នាច្រើនអន្សមខ្លាច　ទាល់តែហិនហោចខ្ទេចខូចការ
ខូចក្ដីចម្រើនបង់អសារ　ខូចពង្សាវតារប្រទេសជាតិ ៗ
ឧទាហរណ៍ដូចស្រុកយើងនេះ　ពីមុនដែលប្រេះឆារាត
បែកគ្នារវាងប្រជាជាតិ　ប្រដែងឡឹងឃ្លាតបាកសុខសាន្ត ៗ
គឺឆ្នាំមួយពាន់ប្រាំបួនរយ　ថែមដោយសែសិបប្រាំមួយមាន
មេគណៈបក្សជាប្រធាន　ទ្រង់មានព្រះជាតិជាពង្សវង្ស ៗ
គបដោយវិជ្ជាចេះជ្រៅជ្រះ　រុងរឿងរះលើសពូជពង្ស

មានសញ្ញាប័ត្រខ្ពស់លើសវង្ស លើសពង្សខេមរកម្ពុជរដ្ឋ ។
ទ្រង់បានបង្កើតគណៈបក្ស ដោយការយល់ជាក់ជាប្រាកដ
ថាមុខជាជនកម្ពុជរដ្ឋ ប្រាកដជាបានក្តីចម្រើន ។
ប៉ុន្តែផ្ទុយប្រាសស្រឡះផេង នាំឲ្យវង្វេងដល់ជនច្រើន
ជ្រួលជ្រើមប្រាសប្រាល់ចង់ចម្រើន គណៈបក្សកើនដល់បួនប្រាំ ។
ខំប្រឹងប្រជែងតំណែងគ្នា អួតអាងវិជ្ជាជាយូរឆ្នាំ
ខ្វះឆ្មើមឆ្មីមធំសម្ចាំ ឃើញហេតុសាំញ៉ាំខាំគ្រញិច ។
ក្រញីគ្នាឯងដូចជាខ្លា ឬដូចមហិង្សាប៉ោលទង្គិច
ទង្គុកគ្នាឯងសែងពន្ទិប ពន្ទើសកលកិច្ចកើតបែកបាក់ ។
បែកបែរក្នុងរដ្ឋាភិបាល រាលដាលដួចដល់ទៅអស់អ្នក
ស្រុកស្រែចំការក៏ថ្នាំងថ្នាក់ អន់អាក់ឯងអញខ្ញាញ់រៀងខ្លួន ។
ឥស្សរៈយៀកមិញក៏ផុះប្រុង ដូចជាចម្រុងទាំងខ្មែរយួន
យុកឃាក់យោកគ្នាទាំងបីបួន ក្រុមគ្រប់ចំនួនបួនប្រាំកុក ។
ដើមឡើយមានឈ្មោះថាជាបឈ្លួន ខ្មែរកើតជិតយួននៅនាស្រុក
ស្នាយរៀងកូនក្រស្ត្ររស់ជាសុខ ស្រណុកក្នុងក្រុមទាហានខ្មែរ ។
ស្រាប់តែខ្ចីឃ្លាតស្នាតខ្លាំង ធ្វើឬកម៉ាំងខាំងតាំងបែកបែរ
រត់ទៅស្រុកសៀមបោលស្រុកខ្មែរ ហើយបែរតាំងទ័ពឥស្សរៈឡើង ។

ក្នុងខែត្រសៀមរាបកំពង់ធំ ពីតកែបន្ទំក្តៅដូចភ្លើង
ប៉ៃប៉ូនបំផ្លាញតែខ្មែរយើង រលើងរលីងទ្រព្យច្រើនគ្នា ៗ

តមកនាមទ្រង់ចន្ទូរង្សី ព្រះនាមមានល្បីខាងស្នេហា
ចំពោះជនជាតិនិងសាស្នា ចេញពីភាពតាំងទ័ពថ្មី ៗ
បានគ្នាច្រើនទៅកំពង់ស្ពឺ ទ័ពទីងរទ្ធិគងពិសី
សំពេងទងទៀតកំពូលល្បី ទ័ពចន្ទូរង្សីខ្មែរជួយជាតិ ៗ
ជួយជនខ្មែរយើងឲ្យរួចគ្រោះ ជួយស្រាយជួយដោះឲ្យរពត
ពីការជិះជាន់ជនបរជាតិ ទាល់តែក្លាយឃ្លាតរលីងស្រុក ៗ

តមកមានឈ្មោះលោកហ៊ូនិញ ខឹងនឹងយៀកមិញមកអុកឡុក
កំពតតាកែវកើតកលិយុគ និញរត់ចោលស្រុកត្រុកព្រៃ ៗ
និញជាអនុសេនីយ៍ទោ ដើមឡើយចិត្តជោជាយវៀនវៃ
បានជាចោលស្រុកត្រុកព្រៃ ព្រោះចង់ប្រល័យយួនយៀកមិញ ៗ

តមកមានឈ្មោះលោកសាវ៉ាង តាំងធ្វើក្បួនក្បានដូចលោកនិញ
ថាចង់បំបាត់ពួកយៀកមិញ សាវ៉ាងតាមនិញទៅនៅព្រៃ ៗ
ខាងស្រុកលើកដែកលោកពុត-ធាយ ល្បីព្រូរខ្លាយខាងវៀនវៃ
ប៉ុនរកគ្នារត់ទៅនៅព្រៃ លកលៃតាំងក្រុមឥស្សរៈដែរ ៗ

កាលនោះទុក្ខាមកើតពេញស្រុក ជនជាតិអុកឡុកឥតមានល្ហែ

ព្រោះគេប្រដែងគ្នាជួយខ្មែរ មិនខ្មេះពាល់តែខ្មែរជាខ្មោច ។
នេះត្រូវលើពាក្យបុរាណថា គ្នាច្រើនត្រៀបត្រាអន្សមខ្លោច
ឬមួយគ្នាច្រើនដូចស្រមោច ថយហួសពីខ្លោចមកជាឆៅ ។
កំហុសទាំងនេះយើងស្រាវជ្រាវ យើងស្លាបយើងរាវរកគល់ទៅ
ទើត្រឹមទេសកាល(១)ត្រូវខ្លោចឆៅ ផ្ទុយទៅព្រោះខ្វះអារ្យធម៌ ។
ខ្មែរធ្លាប់កាន់ពុទ្ធសាសនា ព្រះប្រដៅថាត្រូវអបអរ
ព្រមព្រៀងទទឹងគ្នាជាសាទរ ហៅតាមពាក្យធម៌សាមគ្គី ។
ស្រាប់តែអ្នកបេះហួសជាតិខ្មែរ វិលបែរមកដល់មណ្ឌលទី
ប្ដូរអារ្យធម៌ប្រពៃណី ឲ្យខ្មែរសាមគ្គីមានពួកបក្ស ។
ពួកឯងពួកអញខ្នាញ់កល់ខ្លួន រកកួនបង្កើតការបែកបាក់
បែកបងបែកប្អូនដូនតាជាក់ ដល់ច្រាសគ្នាហាក់មានលាបផ្សង ។
គឺជាសត្វមាន់មេតែមួយ ញាស់ចេញរង្គើយគ្នាទាំងហ្វូង
ធំឡើងគេចាប់ទៅលាបផ្សង ហើយបញ្ចូលហ្វូងដដែលវិញ ។
វាតែងតែជល់គ្នាជានិច្ច វាដាក់ទង្គិចចេញឈាមព្រិញ
បើមិនប្រញាប់ចាប់យកវិញ ស្លាប់រលីងធិញស្ទើរមិនសល់ ។
មិនតែប៉ុណ្ណោះគ្រានោះឯង ពួកបក្សខំស្វែងរកកិច្ចកល

១ អានថា "ទេសកាល" កុំថា "ទេសៈកាលៈ" ។

គាស់រំលំគ្នាឥតយោគយល់　　ការងារនៅសល់ច្រើនអន្ទើ ៗ
ព្រោះត្បិតពួកបក្សមួយផ្តើមឡើង　　ថានឹងតម្កើងគ្រប់អំពើ
គ្រាន់តែផ្តួចផ្តើមមិនទាន់ធ្វើ　　ទីទើទីទើរលំទៅ ៗ
នេះហៅគ្នាច្រើនអន្ទ្រមខ្មោច　　គ្នាដូចស្រមោចអន្ទ្រមនៅ
ការខ្វះជាផេះការខ្វះនៅ　　តំណតទៅត្រូវតែគិត ៗ
ខ្ញុំសូមបញ្ចប់ឈប់អធិប្បាយ　　បរិយាយតាមពាក្យសុភាសិត
ស្តីពីគ្នាច្រើនខ្វះគំនិត　　ភាសិតនេះចប់ប៉ុណ្ណោះហោង ។ ០៙—

## ដម្បូន្មានដល់យុវជន

— គ្នាច្រើនមានកម្លាំង　　អាចតតាំងនឹងការងារ
ប៉ុន្តែត្រូវការពារ　　កុំឲ្យបែកសាមគ្គី ៗ
— គ្នាច្រើនឥតអំពើ　　បើមិនធ្វើគិតតែស៊ី
សម្រឹងប្រឹងសំភី　　រកផ្លូវស៊ីឥតអៀនខ្មាស ៗ
— គ្នាច្រើនគិតតែស៊ី　　ខុសវេណីនឹងវិនាស
អ្នកទាល់ទៅជាទាស　　គឺជាក្រស្តជាខ្ញុំគេ ៗ
— គ្នាច្រើនចម្រើនរដ្ឋ　　បើប្រាកដជាមានមេ
ឥតមានមោះមៃទេ　　តាំងស្តាប់មេបញ្ជាការ ៗ
— គ្នាច្រើនបើបែកប្រេះ　　នោះនឹងផេះស្រុកអសារ

គ្នាច្រើនបើចេះការ    ស្រុះខៀវខ្វាចម្រើនពិត ។

– គ្នាតិចល្បិចមហោសថ    នឹងរួចទោសរស់ជីវិត

ទោះបីគេបោមជិត    គង់ជីវិតពុំមរណា ។

– គ្នាតិចល្បិចឲ្យមាន    ដូចបុកណាបានពោលថា

ផ្លូវត្រង់កុំយាត្រា    វៀចក្តីណាប្រថយទៅ ។ ប៉ុន្តែដើរផ្លូវវៀច(១)

ដូចប្រដៀច(២)រកស៊ីនៅ បឹងធំមានទឹកជ្រៅ    ប្រយ័ត្នត្រីត្ដោតត្រូវបាក់ ។

– គ្នាតិចឥតល្បិចល្បង    តែងតែរងនូវគ្រោះថ្នាក់

ដូចជាស(៣)ជាប់អន្ទាក់    ដែលគេដាក់នៅមាត់រន្ធ ។

– គ្នាតិចល្បិចទន្សាយ    គឺដក់ស្រោយរួចពីពន្ធន៍

ស្បិតមើលស្រែងគ្រន់    វិលជាប់ពន្ធន៍ស្លាប់ក្អែកស៊ីង ។

ចប់

គ្នាច្រើនឥតល្បិចខ្លាច    គ្នាតិចស្រមោចឥតល្បិចនៅ

តែប៉ុណ្ណោះ

---

(១) ផ្លូវវៀច គឺផ្លូវទុច្ចរិត ដែលបណ្ឌិតមិនដែលគោចរ ។ (២) ប្រដៀច ជាឈ្មោះបក្សីតូចមួយ មានជើងវែង ចំពុះវែងស្រួច សម្បុរស្វាយប្រផេះ ស្រដៀងសម្បុរនៃសត្វទទា ជាសត្វទិវាចរ ពុំសូវរហ័សរហួនទេ តែងចិញ្ចឹមជីវិតតែលើខ្លួនទួល ។ (៣) ជាស ជាឈ្មោះសត្វមួយយ៉ាង សណ្ឋានបង្គួយ ធ្វើរន្ធនៅក្នុងដី ។    (មានភាសិតទី ៥ តទៅទៀត)

# ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង

*ដែលមាននៅវិជ្ជាស្ថាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

( តពីលេខ ៣ ឆ្នាំ ១៩៦៦ )

បំណងជើង    *"សាស្ត្រា កាលកបណ្ឌិត*[១]*"*

អ្នកនិពន្ធ    *រកពុំបានឃើញ ។*

កាលបរិច្ឆេទ    *គ្មានបញ្ជាក់កំណត់ទុក ។*

របៀបនិពន្ធ    *ពាក្យកាយ : របៀបដំណាលរឿង ។*

ប្រភពរឿង    *រឿងព្រេងខ្មែរពីបុរាណ ។*

លក្ខណៈឯកសារ *សាស្ត្រាស្លឹករឹត ១ ខ្សែមាន ២៩ សន្លឹកចប់និទានៗ*

*ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តបឹងខ្យាង ខេត្តកណ្ដាល ចុះលេខ ១០១៨ ។*

---

(១) រឿងព្រេងនេះ ទោះបីមានអច្ឆរិយៈផ្សេងៗ បិតនៅក្នុងផ្ទៃរឿងក៏ដោយ ក៏នៅមានអត្ថន័យ និងអត្ថរសគួរឲ្យចាប់អារម្មណ៍ច្រើន ប្រកបដោយគំនិត និងឧត្ដមគតិ គួរឲ្យសរសើរ ។

រឿងនេះតួឯកប្រុសបានទទួលជោគជ័យ និងសុភមង្គល ដោយសារជំនួយអំពីតួឯកស្រីជាភរិយា មានប្រាជ្ញា មានឧបាយដោះស្រាយវិបត្តិដែលកើតឡើង បានសម្រេចជោគជ័យដោយសន្តិវិធី ។ អត្ថន័យផ្ទៃរឿងនេះ មានគោលដៅដូចរឿងមាយើងដែរ ហើយស្របនិងពាក្យស្លោកបុរាណមួយដែលតែងពោលថា "សំណាបយោងដី ស្រីយោងប្រុស" ។

អត្ថបទផ្ដើម កាលដើមឡើយ មានបុរសប្ដីនិងប្រពន្ធពីរនាក់រកស៊ីក្នុងស្រុកនោះ តែស្រុកនោះខ្ញុំពុំចាំឈ្មោះ ។ កំបុរសប្ដីនិងប្រពន្ធរកស៊ីក្នុងស្រុកនោះយូរទៅ ប្រពន្ធចៅបុរសមានផ្ទៃពោះគ្រប់១០ខែ សម្រាលបានកូនប្រុសមួយ កំចៅបុរសនិងនាងប្រពន្ធចិញ្ចឹមបីបាច់កូនដល់អាយុបាន ៣ ឆ្នាំ ចៅបុរសនិងនាងប្រពន្ធក៏សន្មត កត់នាមកូននោះឲ្យឈ្មោះ «កុលុកបណ្ឌិត» ។ អាពុកនិងម្ដាយមានជម្ងឺឈឺស្លាប់ទៅទាំងពីរនាក់ នៅតែចៅកុលុកបណ្ឌិតម្នាក់ឯង តែងកំព្រាឥតអ្នកឯណាជាទីពឹង ។

. . . . . ។ល។ . .

អត្ថបទបញ្ចប់ ឯស្ដេចកណ្ដុរស នាំបរិវារស៊ីចំណីអាហារត្រាតែឆ្អែតស្កប់ស្កល់អស់ ៧ យប់ ៧ ថ្ងៃ ។ ឯកុលុកបណ្ឌិត កំបានរួចពីអន្តរាយ បានទ្រព្យរបស់ទាំងអស់មកវិញ ព្រមទាំងបានជួបជុំប្រពន្ធផង ។ ឯនាងជាប្រពន្ធបាននឹករលឹកដល់សារិកាកាលណាតែងយំសោកសព្វវេលាពេល ។ លុះសារិកាផុះស្ទាបល្មមហើរបាន កំបានហើរទៅរកនាង ។ បានឃើញមានសេចក្ដីត្រេកអរណាស់ បានសួរដើងសេចក្ដីសព្វគ្រប់ ។

ក្រោយស្ដេចទ្រង់បានព្រះរាជទានមាសប្រាក់ ទ្រព្យរបស់

ដាក់ពេញសំពៅ ទើបបបួលប្តីបើកសំពៅចេញទៅស្រុកនគរ ខ្លួនវិញ រកស៊ីជាមួយគ្នាជាសុខសប្បាយតរៀងទៅ ៗ ឯរំ ចប់។

X X X

បំណាងដើង « សាស្ត្រា វិជ្ជាធរ ជាតក(១)»

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ កុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាយ លំនាំទេសនា ។

ប្រភពរឿង រឿងជាតក ១

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែមាន ២៥ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្ត បឹងខ្យាង ខេត្តកណ្តាល ចុះលេខ ១០១៨ ។

---

១) តាមចំណាងជើងសាស្ត្រាស្លឹករឹតដាក់ថា «នេះសេចក្តីវិជ្ជាធរ" ប៉ុន្តែក្នុងផ្ទៃរឿងជាជាតកមួយ ហើយនៅទីបញ្ចប់ អ្នកនិពន្ធបានបញ្ជាក់ថា "វិជ្ជាធរជាតកំ និដ្ឋិតំ" ប្រែថាវិជ្ជាធរជាតកចប់ហើយ ។ ដូច្នេះ ខ្ញុំបានកែតម្រូវបំណាងជើងតាមអត្ថបទផ្ទៃរឿង ។ រឿងនេះប្រហែលជារឿងជាតក ១ ក្នុងបញ្ញាសជាតក ។

ជាតកនេះ ថ្លែងពីព្រះពោធិសត្វកសាងទានបរមត្ថបារមីដូចជាតកខ្លះ ក្នុងបញ្ញាសជាតកដែរ។

អត្ថបទផ្ដើម នមោ តស្ស ។ ឯកស្មឹ កិរ សមយេ ពុទ្ធោ
លោកនាថោ មហាយសោ វិហាសិ . . . ។
គោសាធរោ បពិត្រសាធុសប្បុរសផងទាំងឡាយអើយ ។
ឯកស្មឹ កិរ សមយេ មានកាលសម័យថ្ងៃមួយ ។ ពុទ្ធោ
រីព្រះពុទ្ធ លោកនាថោ ជាទីពំនាក់នៃទេវតា មនុស្សសត្វផង
ទាំងឡាយ នៅព្ធដត្រៃកាលនេះ ។ វិហាសិ ព្រះអង្គសំរេច
សំរាន្តខាននូវព្រះឥរិយាបថមាន ៤ ។ . . ។ល។ . .

អត្ថបទបញ្ចប់ បពិត្រព្រះមហាពជអើយ កាលភពជាតិកន្លងរំលងទៅ
ហើយ កាលណោះ តថាគតបានត្រាច់រង្គាត់ក្នុងវដ្ដសង្សារ
ត្រអាលយោនយកកំណើតកើតជាពោធិសត្វមួយអង្គ ទ្រង់ព្រះ
នាមឈ្មោះព្រះបាទវិជ្ជាធររាជ អាចពុះទ្រូងរូងយកថ្លើម អារ
សាច់សម្រក់ឈាម ឲ្យទៅជាទានប្រេតនោះមិញ ។ ន អញ្ញោ
មិនគឺអ្នកដទៃឡើយ ។ អហមេវ គឺអង្គអញតថាគតនេះឯង ។
សម្ពុទ្ធោ បានត្រាស់ប្រាជ្ញាសាពេជ្ញតាញាណ ជាព្រះពុទ្ធពំនាក់
អស់លោកផងទាំងពួង ឥឡូវនេះហោង ។
វិជ្ជាធរជាតកំ និដ្ឋិតំ បពិត្រអើយ រីទេះស្រដីសរសើរដំណាល
និយាយព្រះបាទវិជ្ជាធរនេះមិញ សម្រេចនូវប្រការទាំងអម្បាល
ណោះហោង ។ ដរាំ ចប់ ។ (នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

នូ-កាន

ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ  អ្នករាជវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន  ទាំងមានសគ្គានស្នេហាជាតិ

យូរ—អ៊ិន

## សេចក្ដីបញ្ជាក់

*រឿងសាមកុក ដែលយើងចុះផ្សាយរួចមកហើយ ក្នុងទស្សនាវដ្ដីលេខ ២ និងលេខ ៣ ឆ្នាំ ១៩៦៦ នោះ មានការច្រឡំផ្ទុយមុនជាក្រោយៗ ជាមុន គឺអត្ថបទដែលត្រូវចុះក្នុងលេខ ២ ទៅជាចុះក្នុងលេខ ៣ ហើយដែលត្រូវចុះក្នុងលេខ ៣ ត្រឡប់ជាចុះក្នុងលេខ ២ ទៅវិញ ។ ឥឡូវនេះ អត្ថបទក្នុងលេខ ២-៣ នោះ យើងសូមបដិសេធបោលទុកជាមោឃៈ ហើយសូមកែតម្រូវ ដោយយកសេចក្ដីក្នុងលេខទាំងពីរនោះ មកចុះសាឡើងវិញរួមជាមួយគ្នា ក្នុងលេខ ៤ នេះឲ្យបានហូរហែតាមដំណើររឿង ។ ដូច្នេះ លោកអ្នកអានកាលបើមើលរឿងសាមកុកនេះ ក្នុងសៀវភៅលេខ ១ ឆ្នាំ ១៩៦៦ ចប់ហើយ សូមអញ្ជើញមើលតមកក្នុងសៀវភៅលេខ ៤ នេះតែម្ដង, ហើយចាប់ពីលេខ ៥ តទៅ យើងនឹងចុះផ្សាយបន្តៗ ជាលំដាប់ ។*

*សូមលោកអ្នកអានមេត្តាអភ័យទោស ចំពោះការភាន់ច្រឡំដោយអចេតនានេះឲ្យបាន ។*

ខណៈនោះមានទាហានទៅប្ដឹងគួនអ៊ូថា គួនបេងដែលលើកទៅត
ដៃនឹងបាំងតេកនោះ មិនទាន់បាញ់ឈ្នះគ្នាទេ គួនអ៊ូឮដូច្នោះខឹងណាស់
ទើបបង្គាប់លៀវហ៊ូ ឲ្យចូលវាយយកស្រុកអ៊ួនសៀ ឯគួនអ៊ូក៏លើកទ័ពស្រុត
តាមគួនបេងចេញទៅ គួនបេងឃើញគួនអ៊ូទៅដល់ក៏ជំរាបថា ខ្ញុំបាទច្បាំង
នឹងបាំងតេកបាន ៣០ ថ្ងៃមិនទាន់បាញ់ឈ្នះ បាំងតេកក៏ថយទ័ពត្រឡប់
ទៅ ខណៈនោះគួនអ៊ូក៏បរពលចូលទៅប្រជាប់គ្នានឹងបន្ទាយបាំងតេកហើយ
ស្រែកថា យើងឈ្មោះគួនអ៊ូអ្នកឯងចូរមកប្រញាប់យកជីវិតមកឲ្យយើងចុះៗ

បាំងតេកឮដូច្នោះ ក៏ចេញមកស្រែកថា ព្រះចៅវុយអង់ប្រើយើង
ឲ្យមកយកក្បាលអ្នកឯង បើមិនជឿមើលមឈូសនេះចុះ បើខ្លាចសេចក្ដី
ស្លាប់ ត្រូវប្រញាប់ចុះពីលើសេះមកចំណុះចុះចូលយើងៗនឹងទុកជីវិតឲ្យ
រស់នៅតទៅ គួនអ៊ូថា ពាក្យដែលឯងថានោះ អញស្ដាប់មើលទៅ
ឃើញលើសហួសនិស្ស័យពេកណាស់ អញនឹងសម្លាប់ឯង ក៏ដូចសម្លាប់
ជ្រូកតូច១ អញគិតស្ដាយមុខដាវរបស់អញណាស់ គួនអ៊ូថាដូច្នោះហើយ
ក៏បំបោលសេះកាន់ដាវចូលច្បាំង នឹងបាំងតេកបាន ១០០ ប៉ាយ ក៏នៅ
មិនទាន់បាញ់ឈ្នះគ្នា ទាហានខាងបាំងតេក នឹកខ្លាចក្រែងនាយទ័ពបាញ់
ក៏ឲ្យវាយឃ្មោះជាសំគាល់ឡើងឲ្យថយទៅ គួនបេងឃើញថា បិតាដក
ក្រែងជួសការ ក៏ឲ្យវាយឃ្មោះថយទ័ព ទាំងសងខាងក៏ថយទៅឈប់ ៗ

ឯប៉ាំងតេកនោះ លុះទៅដល់បន្ទាយហើយ ក៏និយាយនឹងទាហានទាំងពួងថា គេនិយាយឮល្បីល្បាញថា គួនអ៊ូមានថ្វីដៃខ្លាំងពូកែណាស់ យើងទើបនឹងបានប្រទះថ្ងៃនេះ ឃើញថាពិតប្រាកដមែន ខណៈនោះ អ៊ុគិមនិយាយនឹងប៉ាំងតេកថា អ្នកប្ដូរបញ្ចាំងគ្នានឹងគួនអ៊ូដល់ ១០០ ក្បួន ហើយហេតុម្ដេចបានជាអ្នកមិនថយទ័ពចេញ នឹងមិនខុសអំពីព្រះតម្រាស់ទេឬ ប៉ាំងតេកតបថា ព្រះចៅរុយអង់តាំងលោកជាមេទ័ពធំ ហេតុម្ដេចលោកមកខ្លាចញញើតដល់សត្រូវដូច្នេះ មិនសមគួរសោះ វេលាព្រឹកស្អែកខ្ញុំចេញតបញ្ចាំងនឹងគួនអ៊ូម្ដងទៀត ត្រាតែអស់ជីវិតមិនគិតថយក្រោយឡើយ អ៊ុគិមមិនអាចនឹងទទឹងរាំងបាន ក៏ត្រឡប់ទៅបន្ទាយរបស់ខ្លួនវិញ ។

ឯគួនអ៊ូនោះ លុះត្រឡប់ទៅដល់បន្ទាយក៏និយាយនឹងគួនប៉េងថា ប៉ាំងតេកនេះ គេក៏ត្រាន់បើមែន ក្នុងគុនអាវុធថ្វីដៃក៏ល្មម ប្រហែលនឹងយើងដែរ ។ គួនប៉េងនិយាយនឹងបិតាថា ទោះបីលោកអាពុកនឹងតបញ្ចាំងសម្លាប់ប៉ាំងតេកបាន បើឈ្មោះក៏ដូចឈ្មោះស្រី បើត្រឡប់ជាផុងស្មារតីឲ្យចាញ់ប៉ាំងតេកវិញ ក៏នឹងអាស្រូវដល់កិត្តិយសរបស់ព្រះចៅហាន់តុង មិនគួរសោះ គួនអ៊ូថា បើបិតាមិនសម្លាប់អាប៉ាំងតេកចេញឲ្យបាន ក៏អស់រំខាននឹងចិត្តក្ដៅ ហៅកុំថាដូច្នោះឡើយ លុះវេលាព្រឹកឡើង គួនអ៊ូក៏លើកទ័ពចេញទៅទៀត ចំណែកខាងប៉ាំងតេកក៏ចេញតស៊ូបញ្ចាំងគ្នាបាន

១០ ភ្លេង ចាំងតេកក្លែងធ្វើជាចាញ់ទំលាក់លំពែងចុះ ហើយរត់ទៅក្រោយ គួនអ៊ូក៏ដេញបណ្ដោយទៅតាម ហើយស្រែកដេរថា អាឯងកុំអាលក្លែងធ្វើក្បួនរត់ដូច្នេះឡើយ អញដឹងដល់គំនិតអាឯងហើយមិនខ្លាចទេ ។

គួនបេងខ្លាចបិតានឹងជួបការអន្តរាយ ក៏ដេញតាមទៅទៀត ទទួលក្រឡេកឃើញចាំងតេកយកដាវប្រេកក្នុងសោម កន្ត្រាក់យកធ្នូចេញទឹងបាញ់ ហើយគួនបេងស្រែកដេរទៅថា អាសត្វកុំអាលបាញ់បិតាអញ គួនអ៊ូឮក៏ងាកមុខមើលក្រោយ ចាំងតេកក៏បាញ់បណ្ដោយមក ការមិនទាន់ក៏ត្រូវចុងស្មាគួនអ៊ូខាងស្ដាំ គួនបេងក៏ស្ទុះទៅជួយគ្រាហ៍យកបិតាមកបន្ទាយបាន អុិគិមនៅក្នុងបន្ទាយឃើញចាំងតេកបាញ់ត្រូវគួនអ៊ូក៏គិតថាក្រែងចាំងតេកនឹងមានជ័យ បានសេចក្ដីគាប់ប្រសើរ ក៏ក្លែងវាយឃ្មោះ ឲ្យសញ្ញាពថយទ័ព ។

ចាំងតេកឮស្គរឃ្មោះក៏គិតថា មានកើតហេតុមិនស្រួល ទើបថយត្រឡប់ចូលបន្ទាយហើយសួរអុិគិមថា ខ្ញុំមានជ័យជំនះនឹងដេញសត្រូវទៅហេតុម្ដេចបានជាវាយឃ្មោះ ? អុិគិមតបថា មានព្រះតម្រាស់ព្រះចៅរ៉ុយអនឹបង្គាប់ថា គួនអ៊ូជាមនុស្សមានប្រាជ្ញាប្រើកលឧបាយក៏ច្រើន ដែលត្រូវព្រួញប៉ុណ្ណោះក្រែងនឹងបញ្ឆោត បានជាយើងវាយឃ្មោះឃាត់ហាមចាំងតេកថា បើកុំតែលោកឃាត់ហាមខ្ញុំ ៗ ក៏នឹងតាមសម្លាប់គួនអ៊ូឲ

បាន អ៊ុំគិតថា ដែលនឹងធ្វើចិត្តរហ័សនោះមិនស្រួលទេ ក្រែងមានភ័យដល់ខ្លួន យើងត្រូវតែគិតមើលមុខមើលក្រោយឲ្យស្រួលបួលសិន ប៉ាំង-តេកមិនមានជឹងចិត្តអ៊ុំគិតសោះ ចេះតែគិតស្តាយការ ដែលបានបំណាច់ហើយនោះមិនអស់ហើយក្នុងចិត្តសោះ ។

ឯគួនអ៊ូលុះត្រឡប់ទៅដល់បន្ទាយហើយ ក៏ឲ្យកន្ត្រាក់ដកយកព្រួញដែលជាប់នៅចុងស្មាចេញបាន ហើយឲ្យយកថ្នាំទៅលាបបិតមុខរបួសនោះ នៅតែនឹកខឹងក្តៅមិនមានសោយ ទើបនិយាយប្រាប់ទាហានទាំងឡាយថា អស់អ្នកពល់គ្នាចូរធ្វើជាសាក្សីយើងផង យើងនឹងសងថ្វីដៃអាប៉ាំងតេកឲ្យទាល់តែបានវិញ បើសងសឹកពុំមិនបានទេ យើងក៏មិនធ្វើសឹកសង្គ្រាមតទៅឡើយ ទាហានទាំងពួងឆ្លើយថា លោកត្រូវខំព្យាបាលរបួសក្នុងខ្លួនលោកឲ្យជាទៅសិនចុះ រួចសឹមលើកទ័ពទៅច្បាំងនឹងសត្រូវទៀត ។

លុះវេលាព្រឹកគួនអ៊ូដឹងថា ប៉ាំងតេកនឹងចេញមកច្បាំងទៀត គួន-អ៊ូក៏ចេញទៅច្បាំងនឹងប៉ាំងតេក ទាហានទាំងពួងក៏និយាយឃាត់ហាម ប៉ាំងតេកក៏ឲ្យទាហានទៅស្រែកជេរ ប្រាថ្នានឹងឲ្យគួនអ៊ូខឹងលើកទ័ពចេញមកច្បាំងទៀត គួនអ៊ូក៏មិនបានចេញច្បាំង នោះគួនបេងជាបុត្រក៏បាត់ឲ្យត្រួតត្រារក្សាបន្ទាយដោយមាំមួន ហើយទើបបង្គាប់ទាហានមិនឲ្យយក

ដំណឹងចូលទៅជំរាបគួនអ៊ូសោះ ប៉ាំងតេកចេះតែលើកទៅបញ្ឆិត គួនអ៊ូរាល់ថ្ងៃគំរប់ ១០ ថ្ងៃ លុះមិនឃើញទ័ពគួនអ៊ូចេញមកច្បាំង ក៏ប្រឹក្សានឹងអ៊ុគិមថា ប្រហែលគួនអ៊ូត្រូវព្រួញនៅឈឺធ្ងន់ ទើបមិនឃើញមកច្បាំងនឹងយើង ឥឡូវគួរយើងនឹងពួកទាំង ៧ កង ចូលវាយយកបន្ទាយគួនអ៊ូចុះ ទើបនឹងកែខៃយកស្រុកអ៊ូនសៀបាន អ៊ុគិមខ្លាចក្រែងប៉ាំងតេកនឹងបានសេចក្ដីគាប់ប្រសើរ ក៏និយាយទទឹងទាស់ព្រោះតម្រាស់មិនព្រមឲ្យលើកទ័ពទៅ តាំងតែហាមឃាត់ច្រើនគ្រាណាស់ ឯអ៊ុគិមនោះ ក៏លើកទាហាន ទៅស្កាត់ផ្លូវធំនៅទីពលចាន់ទៅ ឆ្ងាយពីស្រុកអ៊ូនសៀប្រហែល ១០០ សិន (៤គិ) ហើយប៉ាំងតេកទៅតាំងពួនបង្កប់នៅខាងក្រៅប្រា-ប្ចាំមិនឲ្យចេញច្បាំង ។

បំណែកខាងគួនបេងលុះដឹងដំណឹងហើយ ក៏ចូលទៅជំរាបគួនអ៊ូថា ឥឡូវអ៊ុគិមនិងប៉ាំងតេក លើកទ័ពទៅតាំងនៅទីប្រហាបក្ន មិនដឹងថា នឹងគិតធ្វើប្រការម្ដេច គួនអ៊ូក៏រក្សារបួសចង់ជាហើយ បានឮដំណឹងដូច្នោះ ក៏ឡើងសេះ នាំទាហានទៅឈរនៅលើភ្នំមួយអន្ទើ ក្រឡេកទៅឃើញកងស្រុកអ៊ូនសៀ មានខទង់ជ័យនឹងទាហានក៏រៀបរាយស្កួចស្គើងមិនប្រុងប្រៀបរៀបជាក្បួនទ័ព ទើបក្រឡេកទៅឃើញកល ១ មានត្រង់ចន្លោះភ្នំនៅទិសខាងជើង ឃើញពួកអ៊ុគិមនិងប៉ាំងតេកតាំងទ័ពនៅចម្ងាយពី-

ស្រុកប្រហែល ១០០ ស៊ិន (៤គី) ហើយឃើញទន្លេសុងកាំងហូរទឹកធ្លាក់ទៅតាមកំឡាំងទំនាប ទើបឲ្យពួកអ្នកស្រុកចេញមក ហើយសួរថាវាលនោះឈ្មោះអ្វី ? អ្នកស្រុកឆ្លើយថា វាលចាន់ខៅ គួនអ៊ូមានអំណរណាស់ថា អ៊ុគិមគ្រានេះមុខជាមិនរួចពីកណ្ដាប់ដៃយើងទេ ទាហានជំពបសួរថា លោកឃើញហេតុប្រការម្ដេច ? គួនអ៊ូឆ្លើយថា សត្រូវចូលទៅតាំងនៅទីចង្អៀត យើងគិតធ្វើការបានស្រួល ហើយក៏នាំទាហានមកបន្ទាយវិញ ទើបបង្គាប់ឲ្យទាហានធ្វើទូកចម្បាំងទាំងតូចទាំងធំបំរុងទុកជាច្រើន ៗ

គួនបេងសួរគួនអ៊ូថា ឥឡូវធ្វើម្ដេច យើងនឹងបានលើកដោយក្បួនទ័ពគោកទៀត ប៉េលោកអាពុកឲ្យបំរុងទូកចម្បាំងដូច្នេះ គួនអ៊ូប្រាប់ថា ព្រោះវេលានេះ អ៊ុគិម នឹងបាំងតេកលើកថយចេញទៅតាំងបន្ទាយនៅវាលចាន់ខៅក្នុងប្រហបភ្នំ បិតាឃើញថាទីនោះជាទីទំនាប តំបន់យើងជាទីទួល ឃើញថាក្នុងរវាងខែកទ្របទ នឹងមានភ្លៀងជ្រាំធ្លាក់មកពល់វេលា គង់នឹងដក់ទឹកឡើងច្រើនលិចបន្ទាយនោះ មនុស្សទាំងឡាយក៏គង់នឹងលំបាករកទីស្នាក់អាស្រ័យមិនបាន យើងនឹងលើកទ័ពទូកចូលទៅច្បាំង គង់នឹងវាយយកបានដោយងាយ គួនបេងស្ដាប់ឮដូច្នោះ ក៏ចុះទៅក្រាបសំពះសរសើរគំនិតបិតា ៗ

បណ្ដាទាហានទាំងអស់ ដែលបានទៅតាំងបន្ទាយនៅទីនោះ លុះឃើញភ្លៀងរលាំមិនដែលដាច់សោះ ទឹកក៏កាន់តែឡើងខ្ពស់គ្រប់ថ្ងៃ សេនហោក៏និយាយនឹងអ៊ុគិមថា ដែលយើងតាំងបន្ទាយនៅទីនេះ គឺជាទីចង្អៀត ទីទំនាប នៅក្នុងចន្លោះភ្នំ ឥឡូវក៏ត្រូវភ្លៀងជ្រាំធ្លាក់មកមិនដាច់គ្រប់យប់ថ្ងៃ ទាហានដែលនៅអាស្រ័យក៏បានសេចក្ដីព្រួយលំបាកណាស់ ឥឡូវឮដំណឹងថា គួរអ៊ីឲ្យតាំងបន្ទាយនៅលើភ្នំខ្ពស់ ហើយឲ្យបំរុងទាហានទូកចម្បាំងធំ-តូចទុកច្រើនណាស់ បើទឹកឡើងមកច្រើនមុខជាពួកយើងនឹងលំបាកដោយទឹករកទីឈប់អាស្រ័យពុំបាន យើងនឹងគិតប្រការម្ដេច អ៊ុគិមក៏ស្រែកគំហកថា អាពោលម្សៀត ឯងមកនិយាយយ៉ាងនេះ ប្រាថ្នានឹងឲ្យទាហានយើងខូចចិត្តគំនិតអស់ទៅឬ ឯងកុំនិយាយដូច្នេះទៀត បើមិនស្ដាប់អញនឹងសម្លាប់ចេញ ។

សេនហោឮដូច្នោះ ក៏ភ័យស្លុតស្មារតី បានសេចក្ដីខ្មាសណាស់ ថយចុះចេញទៅ ហើយក៏ទៅនិយាយប្រាប់ប៉ាំងតេកតាមពាក្យរបស់ខ្លួន នឹងពាក្យដែលអ៊ុគិមខឹងថានោះ ប៉ាំងតេកថា អ្នកនិយាយនោះត្រូវណាស់ តែបើអ៊ុគិមជាមេទ័ពធំ គេមិនព្រមប្រែប្រួលចេញទេ ក៏តាមគំនិតផងគេចុះ តែវេលាព្រឹកស្អែក យើងនឹងលើកទៅតាំងទ័ពទីដទៃទៀត លុះប្រឹក្សាគ្នាហើយ វេលាយប់នោះ ទទួលធ្លាក់ខ្យល់ព្យុះភ្លៀងរលាំធំណាស់

ប៉ាំងតេកបានឮស្គរខ្យល់ព្យុះនឹងឃើញភ្លៀងសន្ធឹកសន្ធាប់មកដូច្នោះក៏ភ័យខ្លាំងណាស់ ទើបឡើងសេះទៅឈរនៅមុខបន្ទាយ ក្រឡេកមើលទៅតាំង ៨ ទិស ក៏ឃើញទឹកឡើងមកជាច្រើន លិចបន្ទាយនោះជម្រៅ៦ហត្ថ ទាហានបានសេចក្ដីលំបាកលង់ទឹកស្លាប់ជាច្រើន អ៊ុគិមនិងប៉ាំងតេកនៅអស់ទាហានដែលសល់ពីស្លាប់នោះតាំងអស់គ្នា ក៏រត់ឡើងទៅអាស្រ័យនៅលើកំពូលភ្នំតូច១ តែអ៊ុគិមនិងប៉ាំងតេកនោះ មិនបាននៅជាមួយគ្នាទេ លុះដល់ព្រឹកឡើង គួនអ៊ូក៏ឲ្យទាហានស្រែកហោលើកទង់គ្រវីយោះគងទូងស្គរ ហើយលើកទ័ពទូកចូលទៅ ។

អ៊ុគិមឃើញគួនអ៊ូលើកទ័ពមកក៏ភ័យណាស់ ព្រោះមានទាហាននៅជាមួយ ប្រមាណតែ ៥០ ឬ ៦០ នាក់ប៉ុណ្ណោះ ឃើញថាតស៊ូមិនបាន ទើបស្រែកទៅថា គ្រានេះខ្ញុំបាទមិនតច្បាំងទេ នឹងសុំចំណុះចុះចូលទៅ នៅជាខ្ញុំរាជការលោកហើយ គួនអ៊ូឲ្យអ៊ុគិមដោះអាវ បោលគ្រឿងសស្ត្រាវុធតាំងអស់ ហើយយកទូកចម្បាំងទៅទទួលឲ្យចុះមកក្នុងទូកតាំងអស់គ្នា គួនអ៊ូក៏លើកទៅចាប់ខ្លួនប៉ាំងតេក ។

ឯប៉ាំងតេក, តាំងហេង, តាំងឈៀវ, សេងហោ មានទាហាននៅជាមួយប្រហែល ៥០០ នាក់ ឈរនៅលើកំពូលភ្នំក្រឡេកឃើញគួនអ៊ូក៏មិនមានខ្លាច គួនអ៊ូក៏ឲ្យយកទូកចម្បាំងព័ទ្ធជុំវិញ ហើយឲ្យលើកធ្នូបាញ់

ចម្រុះទៅត្រូវទាហានចាំងគេកស្លាប់អស់ប្រហែល ២ ភាគ ។

ឯតាំងហេង, តាំងឈៀវ លុះឃើញទ័ពដល់ទីអាប់ចុនហើយ ក៏និយាយនឹងចាំងគេកថា ទាហានយើងស្លាប់ជាងពាក់កណ្ដាលទៅហើយ សូម្បីផ្លូវប្រកល្ហកក៏រកនឹងរត់ទៅពុំរួច គួរយើងនឹងព្រមចុះចាញ់គួនអ៊ូ យកតែជីវិតឲ្យរួចទៅចុះ ចាំងគេកឮដូច្នោះខឹងណាស់ថា យើងជាខ្ញុំព្រះចៅវុយអង យើងបានឲ្យសេចក្ដីសត្យពិតត្រង់ទុកទៅហើយ ដែលនឹងព្រមចំណុះចុះចាញ់ទៅធ្វើជាខ្ញុំគួនអ៊ូវិញនោះមិនត្រូវសោះ លុះនិយាយដូច្នោះហើយក៏ស្ទុះទៅកាប់តាំងហេង, តាំងឈៀវស្លាប់នៅទីនោះ ហើយក៏និយាយនឹងទាហានទាំងពួងថា បើនរណានៅតែនិយាយដូច្នេះ យើងត្រូវធ្វើទោសដូចអាទាំង ២ នាក់ ដូច្នោះ ពួកទាហានទាំងអស់ឮហើយក៏ខំប្រឹងចូលទៅច្បាំងគួនអ៊ូមិនបានគោតញញើត តាំងពីពេលព្រឹកទាល់ដល់ថ្ងៃត្រង់ គួនអ៊ូក៏ឲ្យទាហានបាញ់ធ្នូនឹងចោលដុំថ្មតម្រង់ទៅបីដូចគ្រាប់ភ្លៀង ។

ឯចាំងគេកនោះ ក៏ឲ្យពលចូលច្បាំងមិនរាថយសោះ ហើយនិយាយនឹងសេងហោថា យើងបានឮគេនិយាយមកពីដើមថា ដែលនឹងឡើងឈ្មោះពេញជាទាហាននោះ លុះតែបានចូលក្នុងសង្គ្រាមមិនបានគោតញញើតនឹងសត្រូវសោះ មានចិត្តស្មោះឧស្សាហ៍ធ្វើការច្បាំងតាំងយកជ័យជំនះឲ្យបាន ដូចយើងវេលានេះ ក៏អាប់ចុនស៊ុនខ្វួននៅក្នុងបំណោមទ័ព យើងត្រូវ

តែស្លាប់   ប៉ុន្តែត្រូវមានមានះទាំងអស់គ្នាកុំពថយឡើយ   ចូលស៊ូច្បាំងឲ្យទាល់តែស្លាប់ឲ្យហើយទៅចុះ   សេងហោឮដូច្នោះក៏គិតមានះស្ទុះកាន់ដាវចេញទៅមុខ   ចូលគ្រលុកតទឹងគួនអ៊ូក៏ត្រូវធ្នូស្លាប់ ។

បណ្តាទាហានទាំងពួង   ឃើញសេងហោស្លាប់   ក៏ត្រឡប់ចិត្តគិតញញើតទាំងអស់គ្នា   បបួលគ្នាទៅបំណុះចុះចូលជាពួកគួនអ៊ូទាំងអស់ ឯប៉ាំងតេកនោះនៅតែម្នាក់ឯង   ក្រឡេកឃើញទូកតូច ១ មានមនុស្ស ១០ នាក់ចែវចូលទៅជិត ប៉ាំងតេកកាន់ដាវម៉ិតរត់ចុះទៅក្នុងទូកបាន ហើយបង្ខំទាហានដើងចែវទាំងនោះឲ្យចែវរត់ទៅ   ប៉ាំងតេកនៅឈរលើទូក ដៃ ១ កាន់ដាវហៅបង្ខំពួកដើងចែវ ៗ តម្រង់ទៅស្រុកអ៊ួនសៀ ។

ខណៈនោះដាវឆេងទាហានគួនអ៊ូមានកម្លាំងចំណានតស៊ូច្បាំងក្នុងក្បួនទូក   លុះក្រឡេកឃើញប៉ាំងតេកឲ្យចែវទូករត់ទៅដូច្នោះ   ក៏បង្ខំទាហានឲ្យចែវទូកចម្បាំងដេញទៅប្រកើលលើទូកប៉ាំងតេកលិចទៅ   ប៉ាំងតេកក៏បោះបោលដាវចេញ ហើយលោតចុះទឹកហែលទៅ   ដាវឆេងក៏ព្រួតគ្នាចាប់បាន   ហើយចងនាំយកទៅជូនគួនអ៊ូ ៗ ក៏លើកទ័ពត្រឡប់ចូលបន្ទាយវិញ   ទើបឲ្យនាំយកខ្លួនអ៊ុគិមឡើងមកពីក្នុងទូកហើយសួរថា   ហេតុម្តេចបានជាខ្លួនហ៊ានទ្រទង់អង់អាចមកច្បាំងនឹងយើង អ៊ុគិមឆ្លើយថា ខ្ញុំបាទជាខ្ញុំព្រះចៅរ៉ុយអង់ៗ ត្រាស់ប្រើហើយទឹងទទឹងម្តេចបាន ដែលមកច្បាំងនឹង

លោកនោះមានទោសខុសណាស់ទៅហើយ សូមឲ្យលោកអនុគ្រោះលោះជីវិតទុកឲ្យបានចុះ ខ្ញុំបាទនឹងសុំនៅធ្វើកជការសងគុណលោកតទៅ ។

គួនអ៊ិឮដូច្នោះក៏អស់សំណើចហើយថា យើងនឹងសម្លាប់ជីវិតខ្លួនចេញក៏បីដូចជាសម្លាប់ក្អែ ១ ប៉ុណ្ណោះ ទើបបង្គាប់ទាហានឲ្យចងខ្លួនអ៊ុតិមនាំត្រឡប់ទៅដាក់គុកទុក ឯស្រុកកេនជីវទំពាំងនឹងស្រេចការណ៍ធ្វើសង្គ្រាម ហើយបង្គាប់ឲ្យយកខ្លួនប៉ាំងតេកចូលមកទៀតសួរថា ឥឡូវយើងចាប់ខ្លួនឯងបាន តើឯងនឹងគិតប្រការម្តេច ?

ប៉ាំងតេកមានសេចក្តីមានះឈរនៅមិនគំនាប់គួនអ៊ិសោះ គួនអ៊ិសួរថាប៉ាំងហ៊ីវបងឯង ហើយនឹងម៉ាឈៀវជានាយទៅហ្វាយបាស់នោះក៏ទៅនៅជាខ្ញុំកជការព្រះចៅឡាវពឹងស្រុកសៃពន្លួន ឥឡូវយើងលើកទ័ពមកបង្ក្រាបសត្រូវ ហេតុម្តេចខ្លួនឯងទើបមិនសុំត្រមកនៅនឹងយើង ប៉ាំងតេកឆ្លើយថា យើងជាខ្ញុំព្រះចៅវុយអង ។ ប្រើមកឲ្យយើងច្បាំងនឹងខ្លួន ។ ចាប់យើងបានហើយត្រូវធ្វើតាមចិត្តចុះ ដែលមកល្បួងឲ្យយើងព្រមចំណុះធ្វើជាកជការផងនោះ យើងមិនត្រូវការទេ ព្រោះយើងដឹងថា ព្រះចៅវុយអងមានព្រះគុណជាទម្ងន់ណាស់ យើងសុំតែស្លាប់នឹងមុខដាវមុខលំពែង ហើយមិនបានជាអាល័យស្តាយរូបកាយនេះប៉ុន្មានទេ ហើយក៏

និយាយទ្រគោះអស្សុរកេះជេរប្រមាថគួនអ៊ូជាច្រើន គួនអ៊ូខឹងណាស់ក៏បង្គាប់ឲ្យទាហាននាំខ្លួនបាំងតេកទៅប្រហារជីវិត ហើយក៏ត្រឡប់គិតអាណិតអនាថពន់ប្រមាណ បានឲ្យយកសពទៅកប់តាមប្រពៃណី ។

ឯះចាយិនដែលនៅក្នុងស្រុកអ៊ួនសៀនោះ លុះឃើញទឹកជំនន់ឡើងច្រើន ក៏បង្ខំឲ្យទាហាននឹងបណ្ដាអ្នកស្រុកបិតរង្វះព្រែកទាំងអស់ ទឹកនោះក៏ហូរបាក់ធ្លាយរលាយទំនប់ចូលទៅក្នុងស្រុកបាន ប្រជាជនក្នុងភូមិឋានក៏បានសេចក្ដីលំបាកណាស់ ចោយិននិយាយនឹងទាហានទាំងពួងថា គ្រានេះមុខជាយើងនឹងមានអន្ដរាយជាប្រាកដហើយ ព្រោះទឹកឡើងច្រើនណាស់ មនុស្សទាំងពួងបានសេចក្ដីលំបាកវេទនា បើសត្រូវចូលមកពាធាក៏តទល់ពុំឈ្នះ គួរយើងនឹងលះបង់ចោលស្រុកនេះវេះរត់ទៅរក្សាអាយុជីវិតសិនចុះ ទើបបង្គាប់ឲ្យប្រុងប្រៀបរៀបទូកនឹងធ្ងងរត់ទៅ ។

ខណៈនោះ ប៊ួខចុងទីប្រឹក្សាហាមឃាត់ចោយិនថា ដែលនឹងលះបង់ចោលស្រុកអ៊ួនសៀនោះមិនគួរសោះ ព្រោះនៅតែ ២-៣ ថ្ងៃទៀតទឹកនឹងស្រកចុះទៅវិញហើយ ខ្ញុំបាទយល់ឃើញថា ចគួនអ៊ូដែលនឹងលើកទ័ពមកច្បាំងក្នុងគ្រានេះក៏ឃើញថាមុខជាមិនមកទេ មុខជានឹងឲ្យតែទាហានទៅទាំងទ័ពនៅកៀបហៃ ដែលជាផ្លូវនឹងចូលមកក្នុងស្រុកអ៊ួនសៀ ព្រោះខ្លាចពួកយើងនឹងលើកទៅលុកពីក្រោយ ឯស្រុកអ៊ួនសៀនេះជា

បង្គោលមាំជាងអាណាខែត្រទិសខាងត្បូងទាំងអស់ បើបោលស្រុកអ៊ួន-
សៀបង់ហើយ ស្រុកទៀងអាន់ក៏នឹងរលំទៅ ។

ហោយិនឆ្លើយតបទៅនឹងប្អូនចុងថា អ្នកឯងនិយាយនេះយើងក៏យល់ឃើញផងដែរ បើប្រសិនជាអ្នកមិនបានឃាត់ឃាំងយើងមុខជាខូចការរាជការទៅទទេឥតប្រយោជន៍ និយាយហើយក៏ឡើងជិះសេះសបរទៅបញ្ជូរពាសើនបន្ទាយ ហើយស្រែកប្រកាសប្រាប់ទាហានទាំងពួងថា គ្រានេះយើងកាន់ព្រះតម្រាស់ព្រះចៅវ៉ុយអង់មក បើនរណាធ្វើដការគោតញ-ញើតចេញពាក្យថានឹងបោលស្រុកអ៊ួនសៀទៀត យើងនឹងកាត់ក្បាលអ្នកនោះចេញ ទាហានទាំងពួងក៏ស្រែកឡើងព្រមគ្នាថា យើងខ្ញុំរក្សាស្រុកនេះទុកត្រាតែអស់ជីវិត ហោយិនឮដូច្នោះពេញចិត្តណាស់ ទើបប្រុងប្រៀបរៀបទាហានឲ្យមានគ្រឿងសាស្ត្រាវុធ និង ធ្នូស្នាព្រួញត្រាទាំងយប់ទាំងថ្ងៃ លុះរំលងមក ២ - ៣ ថ្ងៃ ទឹកក៏ស្រកចុះទៅអស់ ឯគួនអ៊ុកាលមានជ័យជំនះក៏ល្បីព្រុះខ្ទរខ្ទារ ឈ្មោះទូទៅ ដល់មនុស្សទាំងពួងលើសជាងពីដើម ។

ឯគួនហ៊ុនជាបុត្រទី ២ នៃគួនអ៊ុដែលនៅស្រុកកេងជីរក៏លើកពលមកសួរបិតា គួនអ៊ុក៏ប្រើគួនហ៊ុនឲ្យកាន់សំបុត្រ ១ ច្បាប់ទៅក្រាបទូលព្រះចៅហាន់តុងឯស្រុកសេងតោថា ឥឡូវគួនអ៊ុទូលបង្គំវាយយកបានស្រុកស៊ុងយ៉ុងហើយ ចាប់បានទាំងខួនអ៊ុគិមបញ្ជូនទៅស្រុកកេងជីរ ឯបាំង-

តេកនោះទូលព្រះបង្គំក៏ហាប់បានសម្លាប់ចោលទៅហើយ បណ្ដាទាហាន ដែលទៅធ្វើពជការសង្គ្រាមគ្រានេះ ក៏មានសេចក្ដីគាប់ប្រសើរជាច្រើនណាស់ គួនហិនទទួលយកសំបុត្រនោះហើយ ក៏លាបិតាចេញទៅស្រុកសេងគោ ។

ខណៈនោះ គួនអ៊ូក៏បែងទាហានទៅតាំងនៅទីដំបន់កៀបហែងជាផ្លូវដែលចូលទៅកង់ស្រុកអ៊ួនសៀ ហើយក៏លើកទាហានចូលទៅនឹងវាយទំលាយយកស្រុកអ៊ួនសៀ គួនអ៊ូជិះសេះបញ្ឈរនៅត្រង់ទ្វារទិសឯជើង ហើយយកស៊ែចង្អុលមុខហោយិនស្រែកថា អាពួកជ្រូក ហេតុម្ដេចឯងទើបមិននាំគ្នាចេញមកស្ម័គ្រព្រមចំណុះចុះចូលអញ ទឹងបង្អង់ចាំដល់កាលណាទៅទៀត ។

ហោយិននៅឈរលើសើនក្រឡេកឃើញគួនអ៊ូពាក់អាវមានតែក្រោះបិទទ្រូងមកឈរនៅដូច្នោះ ក៏ឲ្យទាហាន ៥០០ យកធ្នូបាញ់ចម្រេះចុះមកគួនអ៊ូ គេបាត់មិនទាន់ព្រួញធ្នូក៏លឿនទៅត្រូវចុងស្មាខាងឆ្វេងធ្លាក់ពីលើខ្នងសេះ ហោយិនក្រឡេកឃើញគួនអ៊ូត្រូវព្រួញធ្លាក់ពីលើសេះដូច្នោះ ក៏ឲ្យទាហានលើកចេញច្បាំង ។

ឯគួនប៉េងជាបុត្រក៏ឲ្យទាហានចូលច្បាំងនិងទាហានហោយិន ។ ក៏ជយត្រឡប់ទៅវិញចូលស្រុក គួនប៉េងក៏នាំយកបិតាវិលទៅបន្ទាយ ហើយឲ្យមនុស្សទាញកន្ត្រាក់ដកយកព្រួញចេញបាន ឯព្រួញនោះលាប

ចុងដោយថ្នាំពិស ជ្រាបចូលទៅដល់ឆ្អឹងមានពិសពេកបាប់ជាខ្លាំងណាស់ គួនអ៊ូទឹងកំរើកខ្លួនស្ទើរពុំបាន គួនបេងនិងតាហានទាំងពួងឃើញថា គួន-អ៊ូឈឺខ្លាំងដូច្នោះ ក៏នាំគ្នាចូលទៅនិយាយនឹងគួនអ៊ូថា ឥឡូវនេះលោកក៏មានរបួសឈឺ ដែលនឹងធ្វើការតទៅនោះ ឃើញថាលោកបានសេចក្ដីលំ-បាកណាស់ ខ្ញុំបានប្រឹក្សាព្រមគ្នានឹងសុំលើកទ័ពត្រឡប់ទៅស្រុកកេងជីវរក្សារបួសលោកឲ្យសះជាសិនសឹមធ្វើការតទៅ ។

គួនអ៊ូបានឮក៏មានសេចក្ដីខឹងខ្លាំងណាស់ថា យើងនឹងខ្លាចអ៊ូដល់សេចក្ដីឈឺចាប់បន្ដិចបន្តួចប៉ុណ្ណោះ យើងនឹងវាយយកស្រុកអ៊ួនសៀឡបាន ហើយនឹងលើកទៅវាយយកស្រុកហ៊ូតោទៀត ដើម្បីកំចាត់កូប៊ូចេញឲ្យព្រះចៅហៀនគេបានសេចក្ដីសុខ ចៅកុំថាដូច្នេះតទៅទៀតឡើយ អស់អាណាប្រជាជនទាំងពួងក៏នឹងបានសេចក្ដីត្ដូបចិត្ត គួនបេងនិងតាហានទាំងពួងបានឮគួនអ៊ូថាក៏មិនអាចនឹងតាស់ដែងបាន ទាំងអស់គ្នាក៏លាថយមក ក្នុងថ្ងៃនោះស្រាប់តែពេទ្យហ៊ូតោជាគ្រូឯកពួកស្រុកចៅកុនមកដល់បន្ទាយ តាហានទាំងពួងក៏ទៅប្រាប់គួនបេង ៗ ក៏ឲ្យអញ្ជើញពេទ្យហ៊ួតោចូលទៅ ពេទ្យហ៊ូតោសួរថាខ្ញុំបានឮថាបិតាអ្នកត្រូវព្រួញរបួសធ្ងន់ បានជាខ្ញុំស្ទះស្វែងមកនឹងជួយព្យាបាលរក្សា គួនបេងថា កាលគ្រូរក្សារបួសជីវថាយក្នុង ស្រុកកាំងតាំងនោះតើលោកនេះឯងឬ ពេទ្យហ៊ួតោឆ្លើយថា គឺខ្ញុំ

នេះឯងហើយ គួនប៉េងពួដូច្នោះ ក៏មានអំណរណាស់ ទើបឲ្យទាហាន នាំពេទ្យហ៊ូគោចូលទៅក្នុងបន្ទាយ ។

ឯគួនអ៊ូបានសេចក្ដីឈឺចាប់ជាខ្លាំងណាស់ តែគិតក្រែងទាហាន ទាំងពួងដឹងនឹងនាំឲ្យខូចចិត្តគំនិត បានជាខំ១ស្វាហ៍អត់ទ្រាំធ្វើជាបែប សប្បាយ ហើយហៅម៉ាលៀងចូលលេងបាសកា ប្រាថ្នានឹងឲ្យទាហាន ទាំងពួងមានចិត្តស្រើបស្រាល ស្រាប់តែឃើញពេទ្យហ៊ូគោចូលទៅដល់ ក៏មពេញ្ញាឲ្យពិសាតែ ហើយឲ្យពិចារណាមើលរបួសខ្លួន ពេទ្យហ៊ូគោ ថា របួសព្រួញនេះលាបដោយថ្នាំពិសជ្រាបចូលទៅក្នុងឆ្អឹង បើមិនប្រញាប់ មើលឲ្យឆាប់ យូរទៅនឹងខូចស្មានោះអសារ គួនអ៊ូថា លោកនឹងប្រកប ថ្នាំមើលបានឬទេ? ពេទ្យហ៊ូគោថា ខ្ញុំនឹងមើលជូនបាន តែខ្លាចលោក អត់ធន់ពុំបាន គួនអ៊ូថា លោកត្រូវធ្វើដូចម្ដេចក៏ធ្វើចុះ ហ៊ូគោថា ខ្ញុំបាទ នឹងឲ្យ (ប្បាស) រុំលោកជាប់នឹងសសរមិនឲ្យកម្រើកខ្លួនបាន ។

គួនអ៊ូអស់សំណើចហើយថា ខ្ញុំមិនខ្លាចទេ កុំបាច់យក(ប្បាស) រុំឡើយ លោកនឹងធ្វើយ៉ាងម្ដេចក៏តាមតែធ្វើចុះ ខ្ញុំនៅស្ងៀមឲ្យធ្វើ ទើប បបួលហ៊ូគោផឹកស្រា លុះស្រវឹងហើយក៏ហៅម៉ាលៀងឲ្យចូលមកលេង បាសកា ហើយក៏ផ្ទៀងស្មាម្ខាងឲ្យហ៊ូគោៗក៏យកកាំបិតមុតវះសាច់អាក្រក់ ចេញអស់ហើយក៏យកថ្នាំលាប ហើយទើបយក (ម្ជុល) មកដេររុំទុក

មនុស្សទាំងពួងឃើញដូច្នោះស្ទើរនឹងមិនហ៊ានមើល គួនអ៊ូក៏ក្រោកឡើងស្រែកថា យើងមិនមានឈឺទេ ជាអស់ហើយ ៗ សរសើរថា ពេទ្យនេះវិសេសណាស់ បីដូចជាទេវតាក៏ថាបាន ហ៊ូតោថា តាំងពីខ្ញុំបានចេះមើលរបួសដម្បៅមនុស្សក៏ច្រើនណាស់មកហើយ មិនមាននរណាដូចលោកនេះទេ ឯលោកនេះចិត្តជាអ្នកពូកែអត់ធន់ទ្រាំដម្បៅ មិនតក់ស្លុតរន្ធត់ខ្លាចអ្វីសោះ ល្អណាស់ ៗ ។

ឯគួនអ៊ូ លុះសះជាដម្បៅរបួសនោះហើយក៏អរណាស់ ទើបឲ្យលើកគុអាហារនិងស្រាបាយមកឲ្យហ៊ូតោបរិភោគតាមសប្បាយ ហ៊ូតោក៏និយាយនឹងគួនអ៊ូថា របួសនេះទើបនឹងសះជា លោកត្រូវរម្ងាប់សេចក្ដីក៏ហឹងត្រាតែគ្រប់ ១០០ ថ្ងៃ ទើបពិសព្រួញនោះនឹងជាអស់ស្និទ្ធ គួនអ៊ូក៏ទទួលពាក្យនិងមានអំណរអរគុណហ៊ូតោច្រើនណាស់ ទើបយកមាសទម្ងន់ ៣ ជញ្ជីង ១០ បាតឲ្យហ៊ូតោជាបំណាច់រង្វាន់ ហ៊ូតោថា ដែលខ្ញុំបាទបានមកព្យាបាលដម្បៅរបួសលោកទាំងនេះ និងបានតាំងចិត្តប្រាថ្នាដោយរង្វាន់បំណាច់នោះក៏ទេ ខ្ញុំបាទឃើញលោកនេះប្រកបដោយសេចក្ដីសត្យពិតត្រង់ បានជាមកជួយព្យាបាល ដើម្បីមិនឲ្យមានអន្តរាយ ដែលលោកនឹងឲ្យតានបំណាច់រង្វាន់មកខ្ញុំបាទ ៗ មិនយកទេ សូមបង្វិលទុកជូនលោកវិញ ថាតែប៉ុណ្ណោះហើយក៏យកថ្នាំលាបរបួសម្ដងទៀត ហើយក៏លាចេញទៅ ។

(នៅមានត)

# ឯកសារ កម្ពុជសុរិយា

(ត)

លោក ឌឹក-គាម ប្រមូលរៀបរៀង

បតិណ្ណកកថា : ព្រះមហា ជោត-យ៉ឹម, ទ.ក ៥, ទំព័រ ៤០៣, ឆ្នាំ ១៩៥៤ (ម.៥២/២៦) ។ ខេមររង្សី, ទ.ក១, ទំព័រ ១, ឆ្នាំ ១៩៤០ (ម.៥២/១២) ។

បញ្ចុះសីមាវត្តអង្គសិត្តលិ : ព្រះសាសនមុនី កឹម-តួរ, ទ ក.៨, ទំព័រ ៩៦៣ ឆ្នាំ ១៩៦២ (ម.៥២/៣៤) ។

បញ្ញាសជាតកភាគទី ២ : បណ្ឌិតមហា ឈឹម-ស៊ុម, ទ.ក.៤, ទំព័រ ២៦៤, ឆ្នាំ ១៩៥៤ (ម.៥២/២៥) ។

បណ្តាំពាលី (កាព្យ) : ហ៊ឹន-មាស, ទ.ក ៦, ទំព័រ ៣០៩, ឆ្នាំ ១៩៤៣ (ម.៥២/១៥) ។

បណ្ណាល័យពុទ្ធសាសនាមួយនៃប្រទេសកម្ពុជា នៅ រដ្ឋ ឱ (ភូមា) : ទ.ក ៣, ទំព័រ ៣៥៧, ឆ្នាំ ១៩៦២ (ម.៥២/៣៤) ។

បញ្ហាជីវិត : លោក ផល-ទិត, ទ.ក.១, ទំព័រ ៣០, ឆ្នាំ ១ ៦៤ (ម.៥២/៣៦) ។

បញ្ហាភាសិតជប់តីរ : លោក ប៊ូ ប៉ូ, ទ.ក. ៤, ទំព័រ ២៨៧,
ឆ្នាំ ១៩៥១ (ម. ៥២/២៣) ។

បញ្ហាស្មុគ្រស្មាញក្នុងពុទ្ធសាសនា : ទ.ក. ៤-៥-៦, ទំព័រ
១៨១, ឆ្នាំ ១៩៣៨ (ម. ៥២/១០) ។

បញ្ហាអក្សរសាស្ត្រនៅបច្ចុប្បន្ន : លោក លីធាម-តេង, ទ.ក.
៣, ទំព័រ ៣០៦, ឆ្នាំ១៩៦២ (ម. ៥២/៣៤) ។

បដាចកថា : ព្រះទេពមុនី យូ-ប៉ុណ្ណ. ទ ក. ១, ទំព័រ ៣, ឆ្នាំ
១៩៥៤ (ម.៥២/២៦) ។

បភាកថា : អាចារ្យខាល-ប្រាក់, ទ.ក. ៥, ទំព័រ ៣៣៤ ឆ្នាំ
១៩៥១ (ម.៥២/២៣) ។

បរមាធិប្បាយអំពីស្រុក : កុសលាទុរត្ថគោភិក្ខុ ឡាយ-គ្រី, ទ.ក
៣, ទំព័រ ២៦៤, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

បរិយាយសាមគ្គី : ព្រះទេពមុនី យូ-ប៉ុណ្ណ, ទ.ក.៦, ទំព័រ ៤៥៤,
ឆ្នាំ ១៩៤៨ (ម ៥២/២០) ។

បល្លង្កទិព្វ : លោកប៉ាយ-ប៊ុក, ទ.ក ១០, ទំព័រ ៧២៣, ឆ្នាំ ១៩៥៤
(ម.៥២/២៦) ។

ចាប់កាថា (ក្រុមព្រះបំរុង៍កជាទុកាត អំពីមូលហេតុនៃការព្រះសាសនាស្រុកសៀម) : ព្រះមហាពិទូរ ក្រសេម, ទ.ក. ៤, ទំព័រ ២១, ឆ្នាំ ១៩៣០ (ម.៤៤២/៣០)។

ចាប់កាថា : ប-វជីរញ្ញាណត្ថេរ. ទ.ក ១-២-៣, ទំព័រ ១៨១, ឆ្នាំ ១៩៣០ (ម.៥២/១១) ។

ចាប់កាថា រឿងពុទ្ធសាសនានៅប្រទេសកម្ពុជា : លោក សម-ញាណ, ទ.ក. ២, ទំព័រ ១០៣, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

ចាណក្យជាតក (កាព្យ) : ព្រះគ្រូសទ្ធវិទូ ពាង សុខ, ទ.ក. ៥, ទំព័រ ២២៥, ឆ្នាំ ១៩៤៤ (ម.៥២/១៦) ។

ចាតសមុទ្រ (និយាយអំពី) : ទ.ក. ៨, ទំព័រ ៣, ឆ្នាំ ១៩៤១ (ម. ៥២/១៣) ។

ចាតុកម្មទាងព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា : ទ.ក. ៩, ទំព័រ ៩៨០, ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

ចាយាសិកជញ្ញាសូត្រ : ព្រះមហាអានន្ទ, ទ.ក ៧ ១២, ទំព័រ ២១៤, ឆ្នាំ ១៩៤១ (ម.៥២/៤) ។

ធាវេរកកាថា : លោក គុយ-សុត្រ. ទ.ក ១, ទំព័រ ៩ ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

បិសាចនិងចចក : ជេង-ជ្រីវ, ទ.ក ១១, ទំព័រ ១៣០១ ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

បិសាចស្នេហា . យុទ្ធទិពន្ធមន្ត្រី ញ៉ក-ថែម, ទ.ក. ១៥-១៦, ទំព័រ ១, ឆ្នាំ ១៩៤២ (ម ៥២/១៨) ។

បឹងអូលីវីយេរ (រឿងព្រេង) : លោក ព៉យ-ប៊ុក, ទ.ក ៦, ទំព័រ ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

បុញ្ញកិសន្ធកថា : លោកចាប-ពិន, ទ.ក. ៧-១២, ទំព័រ ៥០, ឆ្នាំ ១៩៣៣ (ម.៥២/៥) ។

បុណ្យកំសាន្តស្រុក : លោកស្រ៊-អ៊ូ ទ.ក. ២, ទំព័រ ២៧០, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

បុណ្យចូលឆ្នាំថ្មី (តិជ) : លោកស្រ៊-អ៊ូ, ទ.ក ៤, ទំព័រ ៤៥១, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

បុណ្យចម្រើនព្រះជន្មវស្សា សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយព្រះនាម

កុល-ទេស : ទ.ក. ១១, ទំព័រ ១១៦, ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

បុណ្យឆ្លងគំរប់ ២០ ឆ្នាំសាលាបាលីជាន់ខ្ពស់, ១០ ឆ្នាំ ព្រះរាជបណ្ណាល័យនិង ៥ ឆ្នាំពុទ្ធសាសនបណ្ឌិត្យ ទ.ក. ៧-៨-៩, ទំព័រ ៨២, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

បុណ្យឆ្លងវត្តរវៀង : ព្រះគ្រូអនុគណ ថោង-គិម, ទ.ក ៧, ទំព័រ ៦៧៥, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

បុណ្យឈាបនកិច្ចឧបាសិការុត : ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ សម្ភាជ, ទ.ក. ១, ទំព័រ ៧៨, ឆ្នាំ ១៩៥៤ (ម ៥២/២៦) ។

បុណ្យដង្ហែនិងអភិសេកព្រះពុទ្ធរូបសិរីទ្ធិ : លោក អៀ-តូលុប, ទ.ក. ៦, ទំព័រ ៥៨៨, ឆ្នាំ ១៩៥៧(ម. ៥២/២៩) ។

បុណ្យនមស្សការព្រះសាក្យមុនីចេតិយ : លោក ថាប-ពិន, ទ.ក. ៥, ទំព័រ ៥៧៤, ឆ្នាំ ១៩៥៩ (ម. ៥២/៣១) ។ ទ,ក. ៥, ទំព័រ ៥៣៦, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

បុណ្យនៅភ្នំព្រះវិហារ (ពិធី) : ទ.ក. ១, ទំព័រ ៩៧, ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

បុណ្យបញ្ចុះព្រះពុទ្ធរូបក្នុង ចេតិយ (តិដី) : លោក ហុក-
ហ៊ុម, ទ.ក. ២១, ទំព័រ ១៤៣ , ឆ្នាំ១៩៤៩ (ម.៥២/៣១) ។

បុណ្យបញ្ចុះសីមា នៅវត្ត ឋមរាជិការាម នៅឃុំគគង់ស្បឺ
រវៀង (ក្លូងលើ) : ព្រះមហា ហ៊ួត, ទ.ក. ៧-៨-៩,
ទំព័រ ១៣៧, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

បុណ្យបញ្ចុះសីមាវត្តឧណ្ណាលោម : ទ.ក. ៦, ទំព័រ ៦៤៧,
ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

បុណ្យបូជាសពមង្គលទេពាចារ្យ ស៊ុក : ហ៊ឹម បណ្ណទុក្ស
ប៊ូ-ប៊ូ, ទ.ក. ៧, ទំព័រ ៤១៦, ឆ្នាំ ១៩៤៣ (ម.៥៦/១៥) ។

បុណ្យបូជាសពលោកគ្រូចៅអធិការវត្តពោធិព្រឹក្ស :
ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ (ជួន-ណាត), ទ.ក. ៧,
ទំព័រ ៤១២, ឆ្នាំ១៩៤៣ (ម.៥២/១៥) ។

បុណ្យផ្កាជួយឧបត្ថម្ភសមណនិស្សិត នៅពុទ្ធិកបា
វិទ្យាល័យព្រះសីហនុរាជ : ទ.ក. ៩, ទំព័រ ១០៧០,
ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

បុណ្យព.ស. ២៥០០ នៅខេត្តកំពង់ឆ្នាំង : ព្រះភិក្ខុ ទេព-
សារុន, ទ.ក. ៧, ទំព័រ ៦៨៩, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

បុណ្យពុទ្ធជយន្តិ (ពិធី ប្រទេសជប៉ុន) : ទ ក. ៣, ទំព័រ ៣៤៧, ឆ្នាំ ១៩៥៩ (ម. ៥២/៣១) ។

បុណ្យមាឃបូជានៅស្រុកក្រូចឆ្មា : ព្រះមហា ជា-អៀន, ទ.ក ៦, ទំព័រ ៤៧៦, ឆ្នាំ ១៩៥៤ (ម.៥២/២៦) ។

បុណ្យរំលឹកដល់រតនជមិ : ទ.ក ៧.៨ ៩, ទំព័រ ៨៧, ឆ្នាំ១៩៣៥ (ម.៥២/៧) ។

បុណ្យរំលឹកព្រះគុណសម្តេចព្រះសុគន្ធាធិបតី ព្រះនាម ប៉ាន : ទ.ក. ៤, ទំព័រ ២១៩, ឆ្នាំ ១៩៦៣ (ម.៥២/៣៥)។

បុណ្យសម្ពោធឆ្លងព្រះត្រៃបិដក : ទ.ក. ១-៦ ទំព័រ ៥, ឆ្នាំ ១៩៣៣ (ម.៥២/៥) ។

បុណ្យសម្ពោធឆ្លងសាលាធាលីវង់នៅវត្តសំបួរមាស ឃុំជើងក្រៀង ស្រុកការហោប្អៀរ កំពង់ឆ្នាំង : ទ.ក. ១០-១១ ១២, ទំព័រ ៣១, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

បុរសកាស ៣០ ទ.ក. ១០-១១-១២, ទំព័រ ១១៧, ឆ្នាំ ១៩៣៩ (ម.៥២/១១) ។

បុរសកំជិលមានប្រពន្ធគ្រប់លក្ខណ៍ : ទ.ក.៧-៨-៩ ទំព័រ ១៧៦, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

បុរសពាក់ស្នៀត : ទ.ក. ២-៣, ទំព័រ ៦៩, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

បុរសជីកក្តាម (រឿងព្រេង : ទ.ក ៤-៥-៦, ទំព័រ ២៥៧, ឆ្នាំ ១៩៣៩ (ម.៥២/១៥) ។

បុរសចាញ់ឧុង : (រឿងព្រេង) ទ.ក ១៣-១៤, ទំព័រ ៦១, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

បុរសមិនរង្គខ្យល់ (រឿងព្រេង) : លោក ជេង-ជ្រើ; ទ.ក ១២, ទំព័រ ១៤២៣, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

បុរស ៣ នាក់ឈ្មោះគ្នា : (រឿងព្រេង) ទ.ក ២, ទំព័រ ៣៧, ឆ្នាំ ១៩៣១ (ម ៥២/៤) ។

បុរស ៣ នាក់ម្នាក់ដក់កញ្ចា ម្នាក់អាកៀង ម្នាក់ ជីកស្រា (រឿងព្រេង) : ទ.ក ១០-១១-១២, ទំព័រ ៤១, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

បុរស៥នាក់ ទី១ក្បាលទំពែក ទី២សំបោរបៀរ ទី៣ ពាព្រៀកក្អែក, ទី ៤ សំរងក់ជើង (រឿងព្រេង) : ទ.ក ៧-៨-៩, ទំព័រ ១៧៣, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

[illegible]

[illegible]
[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

បុរសរៀនសិល្ប (រឿងព្រេង): ឧកញ៉ាប្រាជ្ញាធិបតី យិន, ទ.ក ១០-១១-១២, ទំព័រ , ឆ្នាំ ១៩៣៩ (ម.៥២/១១) ។

បុរាណភាសិត : ទ.ក. ៨, ទំព័រ ៣៩៣, ឆ្នាំ ១៩៤៦ (ម.៥២/១៨) ។

បុស្តិកាំពង់ជំ (អំពី) : ទ.ក. ៧-៨-៩, ទំព័រ ៨១, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

ប៉ូលនិងវីរស៊ីនី (រឿង) : សាស្ត្រាចារ្យ ផេង-ជ្រើ, ទ.ក. ៣, ទំព័រ ២២០, ឆ្នាំ ១៩៥២ (ម.៥២/២៤) ។

បែបអក្សរខ្មែរសម័យសិលាចារឹកបាង់ជ័យ : លោក ឌឹក-គាម, ទ.ក. ៩, ទំព័រ ១០១៩, ឆ្នាំ១៩៦២ (ម.៥២/៣៤) ។

ប៉ោងជានេសាទុប្បករណ៍ខ្មែរ : លោក ឌឹក-គាម, ទ.ក. ១២, ទំព័រ ១៤២០, ឆ្នាំ ១៩៦២ ម.៧២/៣៤ ។

ប្រកាសតែងប្រកួតរឿងភ្ជុំបិណ្ឌ : ទ.ក. ១៤, ទំព័រ ៦១៧, ឆ្នាំ ១៩៤៤ (ម.៦២/១៦) ។

ប្រជុំកាង់ជមិឧបាសកា : ព្រះទេពសត្ថា, កឹម-គូរ, ទ.ក. ៦, ទំព័រ ៥១៩, ឆ្នាំ ១៩៦៥ (ម.៥៦/២៨) ។

ប្រជុំកាព្យភាគទី៣ពួកស្រីក្នុងវាំង : ទ.ក ១០-១១២ ១២, ទំព័រ ២៤៥, ឆ្នាំ ១៩៣៩ (ម.៥២/១១) ។

ប្រជុំពាក្យកាព្យភាគទី១ : ព្រះបាទសម្តេចព្រះស្រីធម្មរាជា ទ.ក ៧ ៨-៩, ទំព័រ ៩៩, ឆ្នាំ ១៩៣៨ (ម.៥២/១០) ។

ប្រជុំពាក្យព្រេង និងទាវចណាទារាំងផ្សេងៗ : លោកហ៊យ-ប៊ុក, ទ.ក. ៣, ទំព័រ ១៩៦, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។

ប្រជុំមហាសន្និបាតនៃពុទ្ធសាសនបណ្ឌិត្យ : ទ.ក. ៥, ទំព័រ ៣០, ឆ្នាំ ១៩៤៣ (ម.៥២/១៥) ។

ប្រជុំសុភាសិតខ្មែរតាមលំដាប់អក្សរ : ឃុនទិពន្ធមន្ត្រី ញ៉ុក ថែម; ទ.ក ១២, ទំព័រ ៦៦៦, ឆ្នាំ ១៩៤៣ (ម.៥២/១៥) ។

ប្រជុំសុភាសិតអ្នកនិពន្ធក្រោក : លោកហ៊យ-ប៊ុក, ទ.ក ១, ទំព័រ ៩, ឆ្នាំ១៩៤៩ ម.៥២/២១) ។

ប្រជុំសុភាសិតអ្នកនិពន្ធរួមាំង : លោកហ៊យ ប៊ុក, ទ.ក ១០, ទំព័រ ៧៣៧, ឆ្នាំ ១៩៤៨ (ម.៥២/២៦) ។

ប្រដៅចិត្ត (កាព្យ) : លោកឧកញ៉ាចេស្តាវិទិច្ច័យ កែវ-ហង្ស ទ.ក ១-២-៣, ទំព័រ ៥៨, ឆ្នាំ ១៩៤៣ (ម.៥២/១៥) ។

ប្រដៅមនុស្សដោយកាយមួយរយរំពាត់ (រឿងព្រេង) :
លោកស៊ុន-ហ៊ាន ទ.ក៦, ទំព័រ៦៤២, ឆ្នាំ១៩៥៩ (ម.៥២/៣១)។

ប្រទេសលាវជាស្រុកនៅក្នុងឧបទ្វីបឥណ្ឌូចិន
ស៊ី : លោកលាកេទយ, ទ.ក ៤, ទំព័រ ៣, ឆ្នាំ ១៩៤១
(ម.៥២/១៣) ។

ប្រវត្តិការណ៍ខ្មែរច្បាប់ណា : លោក មាស-នាន, ទ.ក ១០, ទំព័រ
៩៣១, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

ប្រវត្តិទង់ប្រចាំជាតិខ្មែរ : ទ.ក ២, ទំព័រ ២៩, ឆ្នាំ ១៩៤២
(ម.៥២/១៤) ។

ប្រវត្តិនៃវត្តប្រាង្គ : ព្រះពោធិវង្ស ហ-តាត, ទ.ក. ២, ទំព័រ ២១៥,
ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

ប្រវត្តិនៃសត្វរ : អ្នកឧកញ៉ាឥស្សរវង្ស សំ-ស៊ុន, ទ.ក. ៨, ទំព័រ
៤១៩, ឆ្នាំ ១៩៤៧ (ម.៥២/១៩) ។

វត្តបទុមវតីរាជវរារាម : ឃុនបណ្ណាទុរក្ស ប៊ូ-ប៊ូ, ទ.ក. ៨, ទំព័រ
២៦.៩, ឆ្នាំ ១៩៥៥ (ម.៥២/២៧) ។

ប្រវត្តិបីជលេង : លោកក្រមការ សក់-ខាត់, ទ.ក ៩, ទំព័រ ៤៨៣,
ឆ្នាំ ១៩៤៧ (ម.៥២/១៩) ។

ប្រវត្តិពួកឧបាសក-ឧបាសិកា សាវក-សាវិកា របស់ព្រះពុទ្ធជាម្ចាស់ ទី១ ប្រវត្តិបុស្សៈ ទិផកល្លិកៈ ទ.ក. ១, ទំព័រ ៣៨, ឆ្នាំ១៩៤២ (ម. ៥២/១៤) ។ ទី ៣ ប្រវត្តិចិត្តគហបតី ទ.ក ៣, ទំព័រ ៧, ឆ្នាំ១៩៤២ (ម.៥២/១៤)។ ទី៤ ប្រវត្តិរបស់ហត្ថក-អាឡវក ទ.ក. ៤, ទំព័រ ១៨, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។ ទី៥-៦ ប្រវត្តិរបស់មហានាម-សក្យរាជនិងឧគ្គគហបតី ទ.ក ៥, ទំព័រ ២៤, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។ ទី ៧-៨ ប្រវត្តិរបស់ឧគ្គគហបតីគាមក និង អម្ពដ្ឋ ទ.ក.៨, ទំព័រ ១៤, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។ ទី៩ ប្រវត្តិជីវក កោមារភច្ច, ទី ១០ នកុលបិតាគហបតី ទ.ក. ១១-១២, ទំព័រ ៤៨, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។ ប្រវត្តិនាងសុជាតាសេនិយធីតា ទ.ក. ១៣-១៤, ទំព័រ ២១, ឆ្នាំ ១៩៤២ (ម. ៥២/១៤) ។ ប្រវត្តិនាងវិសាខាមិគារមាតា ទ.ក ១៥-១៦, ទំព័រ ៤៩, ឆ្នាំ ១៩៤២ (ម.៥២/១៤)។ ប្រវត្តិនាងខុជ្ជុត្តរាឧបាសិកា ប្រវត្តិនាងសាមាវតីរាជទេវី ទ.ក. ២១-២២, ទំព័រ ៣៧, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។ ប្រវត្តិនាង

ឧត្តម-នន្ទមាតា នាងសុប្បវាសា កោលិយធីតា ទ.ក. ២៣-២៤, ទំព័រ ៤៥.៤៨, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

ប្រវត្តិព្រះកោរមរកត : អ្នកឧកញ៉ាទេពពិទូរ ឈឹម.ក្រសេម, ទ.ក. ៩, ទំព័រ ៦៩៦, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

ប្រវត្តិព្រាហ្មណ៍ចាស់ : លោកអ៊ុម-គយ, ទ.ក. ៩, ទំព័រ៧១៤, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

ប្រវត្តិព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា : ម – សង្ខិតន័យពីប្រវត្តិព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា នាអតីតកាល (ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ។

ប្រវត្តិព្រះមហា រស់.កោ : ភិក្ខុខៀង ឈួន, ទ.ក ៥, ទំព័រ ៣៨១, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។

ប្រវត្តិព្រះអនុរុទ្ធត្ថេរ : ហ្លួងនិពន្ធមន្ត្រី ញ៉ុក ថែម, ទ.ក. ៩, ទំព័រ ៧០៤, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

ប្រវត្តិព្រះអានន្ទត្ថេរ : ហ្លួងនិពន្ធមន្ត្រី ញ៉ុក.ថែម, ទ.ក. ១៤, ទំព័រ ៩៣៥, ឆ្នាំ ១៩៤៨ (ម.៥២/២១) ។

ប្រវត្តិរបស់អេសុប : លោក ផេង ជ្រើវ, ទ.ក. ៩, ទំព័រ ៦៩០, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌា : ហ្លួងទិពន្ធមន្ត្រី ញ៉ុក-
ថែម, ទ.ក. ២, ទំព័រ ១០០, ឆ្នាំ ១៩៤៩ (ម ៥២/១៦) ។

ប្រវត្តិសាស្ត្រស៊ីវិល័យខ្មែរសម័យបុរាណ : ព៉យ·ប៊ុក, ទ.ក.
៤, ទំព័រ ២៨៣, ឆ្នាំ១៩៥០ (ម. ៥២/២២) ។

ប្រវត្តិអក្សរសាស្ត្រខ្មែរ (សង្ខេប) : លោក សឺ ដេស, ទ.ក.
១, ទំព័រ ៣១, ឆ្នាំ ១៩៤២ (ម. ៥២/១៤) ។

ប្រស្នាជមិ : យុទបណ្ណាទុក្យ ប៊ូ-ប៉ូ, ទ.ក ១១, ទំព័រ ៨១៩, ឆ្នាំ
១៩៥៤ (ម.៥២/២៧)

ប្រស្នាជមិ ជ ១ : យុទបណ្ណាទុក្យ ប៊ូ-ប៉ូ, ទ.ក ៩, ទំព័រ ៦៥២,
ឆ្នាំ ១៩៥៥ (ម ៥២/២៧) ។

ប្រស្នាពិធីបុណ្យឡោច : លោក ប៊ូ-ប៉ូ, ទ.ក ១១, ទំព័រ ៨១៨,
ឆ្នាំ ១៩៥១ (ម.៥២/២៣) ។

ប្រស្នាព្រះចាតុចាយ៉ាសិកជញ្ញា : : លោក ប៊ូ-ប៉ូ ទ.ក ៦, ទំព័រ
៥៥៨, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

ប្រាជ្ញា-សំណាង-ដលនាំង ៣ អ្នកប្តុក្ខិតែសត្វខ្ទង : ទ.ក
១, ទំព័រ ៧១, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

ប្រាសាទខ្មែរ ក ដែលលោក ដាឡេត៍ ទើបរកឃើញ

ក្នុងខេត្តកំពង់ឆ្នាំង : ក្រមការ ជុំ-មៅ, ទ.ក ៤-៥-៦,
ទំព័រ ៦៧, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

ប្រាសាទបាយ័ន : ទ.ក. ៤, ទំព័រ ១, ឆ្នាំ ១៩៤១ (ម.៥២/១៣)។

ប្រាសាទបុរាណនៅស្រុកខ្មែរ : សឺ.ជែស, ទ.ក. ៤-៥-៦,
ទំព័រ ៥, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

ប្រាសាទភ្នំជីសូរ : លោក ល៊ីឆាម-គេង, ទ.ក ១០, ទំព័រ ១១០០,
ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

ប្រាសាទវត្តធឹកឆា : ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ទ.ក៩, ទំព័រ
៥៤៨, ឆ្នាំ ១៩៦៤ (ម ៥២/៣៦) ។

ប្រាសាទវត្តអង្គរ (កំពង់ចាម) : ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ
ទ.ក. ១, ទំព័រ ៨៦, ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

ព្រោះខ្លាដាប់ (រឿង) : ទ.ក. ១០ ១១-១២, ទំព័រ ២២៥, ឆ្នាំ
១៩៣៦ (ម.៥២/៨) ។

ផលប្រយោជន៍នៃឧស្សាហវត្ត : ព្រះអង្គម្ចាស់ក្រុមព្រះនរោត្តម
កាណុវង្ស, ទ.ក ១, ទំព័រ ១, ឆ្នាំ ១៩២៦-២៧ (ម.៥២/១) ។

ផ្ចិតផ្ចង់ក្រែងខ្មាសនៈ : ដែលមានរចនាជារូបខាងព្រាហ្មណសា
សនានិងពុទ្ធសាសនា, ទ.ក ៨, ទំព័រ ១, ឆ្នាំ ១៩២៧
(ម.៥២/២) ។ (នៅមានត)

THEQUE NATIONALE DU … BODGE